ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ គម្រោងយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឆ្នាំ២០០៩-២០១១

◆ សហគម្ពុជាក្រិដ្ឋកម្មរួម និងការកាត់ទោសខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១០៨ ខែធ្នូ ឆ្នាំ២០០៨

# ស្វែងរកការពិត

លេខ១០៨ ខែធ្នូ ឆ្នាំ២០០៨


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា
## មាតិកា


◆ គម្រោងយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ....................១

**ផ្នែកឯកសារ**

◆ ប្រទេសកម្ពុជា ៖ ភាពចាំបាច់ក្នុងការញែកឲ្យឃើញពីភាពខុសប្លែកគ្នា ........៣

◆ កិច្ចការផ្ទៃក្នុងសន្និសីទផ្នែកវេជ្ជសាស្ត្រថ្នាក់ជាតិលើកទី១ ....................៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ទីបំផុតនៅរស់តែម្នាក់ឯង ....................៩

◆ អំពើល្អរបស់ សៅ វ៉ាន់ ....................១២

◆ វេទិកាប្រជុំពិភាក្សាថ្នាក់ភូមិរំសាយការឈឺចាប់របស់ប្រជាជន ....................១៤

**ផ្នែកច្បាប់**

◆ សវនាការអង្គបុរេជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ....................១៦

◆ សវនាការថ្ងៃទី៤ ខែធ្នូ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ ....................១៨

◆ សហកម្មឧក្រិដ្ឋកម្មរួម និងការកាត់ទោសខ្មែរក្រហម ....................២១

**វេទិកាពិភាក្សាសាធារណៈ**

◆ ការវិភាគទៅលើអំពើពុករលួយ ភាពលម្អៀង ....................៣៨

◆ ការវិលត្រឡប់របស់ ហ្គុនណា បឺយស្ត្រម មកកម្ពុជា ....................៤៥

◆ ការផ្សះផ្សាចិត្តរបស់ ហ្គុនណា បឺយស្ត្រម ....................៤៨

◆ កំហុសកាលពីសាមសិបឆ្នាំមុន ....................៥១

◆ ហ្គុនណា ជួបជាមួយ ប៉ុល ពត និង អៀង សារី ....................៥៤

◆ សិក្ខាសាលា និងការតាំងពិព័រណ៍រូបថត ....................៥៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ប្រវត្តិជីវិតរបស់ឪពុកម្តាយខ្ញុំ ....................៥៩







## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ ៖** ហ៊ិន សុផានី, សុខ វណ្ណៈ, ស៊ីវ សាវីណា, វ៉ាន់ថាន់ ពៅដារ៉ា, ចន ឆរធីអារី, គ្រីស្តូហ្វ័រ, សារ៉ា ចូន ឌីកឃិន, អេង កុកថាយ, លី សុខឃាង, ជា ធីតា **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** តាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែៈ** ជា ផល្លា **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រៈ**ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ឆេង វេង Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍កម្ពុជាក្នុងបរិបទពិភពលោក គម្រោងយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឆ្នាំ២០០៩-២០១១

រយៈពេល៣០ឆ្នាំក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យជាផ្លូវការមក ប្រទេសកម្ពុជានៅតែកំពុងធ្វើការដោះស្រាយជាមួយនឹងសំណល់ដ៏ឈឺចាប់នៃអំពើប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម និងការសម្លាប់ដ៏ឃោរឃៅជានិច្ច ។ ក្នុងពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាមធ្យោបាយមួយក្នុងការចាប់ផ្ដើមធ្វើការដោះស្រាយទៅនឹងអតីតកាលរបស់ប្រទេសកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាក៏កំពុងតែដំណើរការស្ថាបនាយន្តការមួយទៀតដើម្បីលើកស្ទួយការផ្សះផ្សាជាតិដែរ ។ ដើម្បីរំឭកដល់ជនរងគ្រោះដែលបានស្លាប់ក្នុងសម័យខ្មែរក្រហម គឺមានសារសំខាន់ណាស់ដើម្បីទំនាក់ទំនងនិងធ្វើកិច្ចការមួយចំនួនដល់អ្នកដែលនៅរស់ពីរបបខ្មែរក្រហម និងកូនចៅជំនាន់ក្រោយដែលមិនត្រឹមតែរស់នៅលើទឹកដីកម្ពុជានោះទេ គឺនៅទូទាំងពិភពលោក ។ គម្រោងយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០០៩-២០១១ របស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺបង្ហាញពីរបៀបដែលមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានបំណងបង្កើតយន្តការដ៏យូរអង្វែងមួយដើម្បីលើកស្ទួយការផ្សះផ្សាជាតិក្នុងប្រទេសកម្ពុជា ។

## ១) កេរដំណែលរូបិយ

***មជ្ឈមណ្ឌលអចិន្ត្រៃយ៍*** : មជ្ឈមណ្ឌលឯកសារកម្ពុជាស្ថិតនៅក្នុងដំណាក់ដំបូងនៃការសាងសង់មជ្ឈមណ្ឌលអចិន្ត្រៃយ៍ថ្មីមួយរបស់ខ្លួនដែលនឹងរួចរាល់ជាស្ថាពរនៅក្នុងឆ្នាំ២០១០ ។ អគារថ្មីមួយនេះនឹងបម្រើឲ្យមុខងារបីយ៉ាង ។ ទី១) មជ្ឈមណ្ឌលអចិន្ត្រៃយ៍នឹងក្លាយទៅជាបូជនីយដ្ឋានរូបិយមួយដើម្បីចងចាំជនរងគ្រោះក្រោមរបបខ្មែរក្រហម ជាពិសេសគឺជាកន្លែងស្ដុកទុកការចងចាំជារួម និងបុគ្គលរបស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ ទី២) អគារនេះក៏ផ្ដល់នូវឱកាសសម្រាប់ប្រជាជនបច្ចុប្បន្ននិងក្មេងជំនាន់ក្រោយដើម្បីរៀនអំពីអតីតកាលដ៏ឈឺចាប់របស់កម្ពុជា ដូច្នោះប្រជាជនទាំងអស់នឹងមិនអាចបំភ្លេចបាននូវជនរងគ្រោះដែលត្រូវស្លាប់ដោយវេទនានិងយ៉ាងអយុត្តិធម៌នោះទេ ។ ចុងក្រោយមជ្ឈមណ្ឌលមានមុខនាទីដូចជាវិទ្យាស្ថានមួយអីចឹង គឺធ្វើឡើងដើម្បីបង្កើតជាប្រព័ន្ធសិក្សាលើអំពើប្រល័យពូជសាសន៍ដំបូងបំផុតសម្រាប់អាស៊ីអាគ្នេយ៍ដែលនឹងភ្ជាប់ទំនាក់ទំនងជាមួយនឹងវិទ្យាស្ថានដទៃទៀតនៅទូទាំងពិភពលោក ។

## ២) កេរដំណែលនៃការចងចាំ

***ការសិក្សាពីអំពើប្រល័យពូជសាសន៍៖*** ការសិក្សាពីអំពើប្រល័យពូជសាសន៍ជាវិធីដ៏សំខាន់មួយក្នុងការថែរក្សាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាដើម្បីស្វែងយល់អំពីមូលហេតុនិងវិធីដែលធ្វើឲ្យអំពើនេះកើតឡើង ជាពិសេសគឺរៀនអំពីផលវិបាកនិងការជះឥទ្ធិពលនៃអំពើប្រល័យពូជសាសន៍កម្ពុជា ។ ប៉ុន្តែអ្វីដែលសំខាន់នោះគឺការសិក្សាពីអំពើប្រល័យពូជសាសន៍បានធ្វើឲ្យយើងទាំងអស់គ្នាចងចាំ និងទទួលស្គាល់ជនរងគ្រោះដែលបានរងទុក្ខវេទនានិងស្លាប់ក្នុងកណ្ដាប់ដៃរបស់ខ្មែរក្រហម ។ ទន្ទឹមនឹងនេះផងដែរ ការសិក្សានេះក៏បង្រៀនឲ្យប្រជាជនដឹងអំពីឥទ្ធិពលអាក្រក់នៃការធ្វើទារុណកម្ម ការធ្វើបាប អំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មដទៃទៀតដែលប្រឆាំងទៅនឹងមនុស្សជាតិ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាថ្មីៗនេះកំពុងតែស្ថិតក្នុងដំណាក់កាលសហការជាមួយនឹងក្រសួងអប់រំដើម្បីបង្កើតកម្មវិធីគោលមួយដែលនឹងរៀបចំបង្រៀនសិស្សនៅចុងឆ្នាំ២០០៩ ។ កម្មវិធីសិក្សានេះនឹងប្រើប្រាស់សៀវភៅមេរៀនប្រវត្តិសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាគោល គឺសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលរកបាននៅក្នុងអ៊ិនធឺណិត អាស្រ័យហេតុនេះយើងអាចផ្សាយព័ត៌មានទៅកាន់សហគមន៍ទូទាំងពិភពលោក ។

***សៀវភៅរាយឈ្មោះ*** : មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានគម្រោងរៀបរៀងនិងបោះពុម្ពសៀវភៅរាយឈ្មោះជនរងគ្រោះម្នាក់ៗដែលស្លាប់ក្នុងរបបខ្មែរក្រហម ។ សៀវភៅនេះមានព័ត៌មាន

ពេញលេញ និងច្បាស់លាស់ដែលអាចធ្វើឲ្យប្រជាជនខ្មែរចងចាំ និងទទួលស្គាល់ជនរងគ្រោះដែលបានបាត់បង់ជីវិតទាំងអស់នោះ ។ សៀវភៅនេះនឹងចែកចាយទៅបណ្ដាឃុំទាំងអស់នៅក្នុងប្រទេសកម្ពុជា ហើយនឹងតម្កល់នៅសាលាឃុំ ។ ការធ្វើបែបនេះនឹងអាចធ្វើឲ្យក្មេងជំនាន់ក្រោយចងចាំយ៉ាងច្បាស់នូវជនរងគ្រោះដែលបានស្លាប់ទាំងអស់នោះ ។ ជាងនេះទៅទៀត សៀវភៅនេះអនុញ្ញាតឲ្យក្រុមគ្រួសារ និងក្មេងជំនាន់ក្រោយរបស់ជនរងគ្រោះអាចតាមដាននូវប្រវត្តិគ្រួសាររបស់ពួកគេបាន ការស្រាវជ្រាវមួយចំនួនទៀតនៅមិនទាន់បានបញ្ចប់នៅឡើយទេ ។ ព័ត៌មានទាំងនេះនឹងមានបញ្ចូលក្នុងអ៊ិនធឺណិតដើម្បីធ្វើទំនាក់ទំនងជាមួយសហគមន៍ពិភពលោក ។

## ៣) កេរដំណែលនៃយុត្តិធម៌

***ការបញ្ចូលឯកសារទៅក្នុងប្រព័ន្ធ*** : មធ្យោបាយមួយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រើប្រាស់ដើម្បីធ្វើទំនាក់ទំនងជាមួយនឹងសហគមន៍ពិភពលោក គឺការបញ្ចូលឯកសារហ្វីលជាង៩០០ជុំនៅក្នុងបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលដើម្បីធ្វើឲ្យកម្រងឯកសារទាំងនេះអាចរកបាននៅតាមអ៊ិនធឺណិត ។ សហការជាមួយនឹងមហាវិទ្យាល័យរ៉ាត់ហ្គើ នៅញូវវ៉ីក រដ្ឋញូវជឺស៊ី ដំណើរការនៃការបញ្ចូលឯកសារនឹងអនុញ្ញាតឲ្យអ្នកប្រាជ្ញ សិស្សានុសិស្ស អ្នកស្រាវជ្រាវ ប្រជាជនកម្ពុជាដែលរស់នៅប្រទេសក្រៅ អ្នកយកព័ត៌មានប្រព័ន្ធផ្សព្វផ្សាយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងប្រជាជនខ្មែរទូទៅមានឱកាសធ្វើការស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍ ។

***ការសិក្សាអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយអ្នកតូចតាច*** : មជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោងធ្វើការសិក្សាទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយកម្មាភិបាលខ្មែរក្រហមថ្នាក់ទាប ។ ការសិក្សានេះនឹងផ្ដោតជាសំខាន់លើសកម្មភាពឧក្រិដ្ឋកម្មផ្សេងៗដែលកើតឡើងក្រោមរបបខ្មែរក្រហម ហើយធ្វើការស្រាវជ្រាវនៅកន្លែងដែលមិនទាន់មានការស្រាវជ្រាវដិតដល់នៅឡើយ ។ ការសិក្សានេះ (វេទិកាបុគ្គលណៈកម្មការ) នឹងផ្ដល់ឱកាសឲ្យជនរងគ្រោះដែលមិនមានការផ្សារភ្ជាប់ទៅនឹងការកាត់ទោសនាពេលថ្មីៗនេះ ដើម្បីឲ្យពួកគាត់បង្ហាញនូវបទពិសោធន៍និងដោះស្រាយជាមួយនឹងអតីតកាលរបស់ខ្លួន ។ ដូចគ្នាទៅនឹងគណៈកម្មការផ្សះផ្សាជាតិនិងស្វែងរកការពិតរបស់អាហ្វ្រិចខាងត្បូង ការសិក្សានេះ (វេទិកាបុគ្គណៈកម្មការ) សង្ឃឹមថានឹងមិនផ្ដោតទៅលើការដាក់កំហុសដល់បុគ្គលម្នាក់ៗនោះទេ តែសំខាន់គឺដើម្បីឲ្យជនរងគ្រោះមានឱកាសនិយាយនិងស្ដាប់ ។ នេះជាជំហានមួយដ៏សំខាន់ក្នុងការផ្សះផ្សាជាតិនិងយុត្តិធម៌តាមរយៈមធ្យោបាយមិនមែនជាលក្ខណៈផ្លូវការ ។ ឈ្មោះទាំងអស់ និងចំណុចដែលបានកត់សម្គាល់ឡើង (ឧទាហរណ៍ ភូមិ ស្រុកកំណើត រូបរាង) នឹងមិនយកមកសិក្សានោះទេ អ្វីដែលផ្ដោតសំខាន់គឺឧក្រិដ្ឋកម្មនិងភ័ស្តុតាងដើម្បីបញ្ជាក់ពីភាពអយុត្តិធម៌ជាជាងការដាក់ទោសកំហុសដល់បុគ្គលម្នាក់ៗ ។ **ឆាំង យុ**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្ដីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្ដល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ឡើងវិញនៅលើគេហទំព័ររបស់ខ្លួននៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ខាងមុខនេះ ។

អ្នកទាំងអស់គ្នាអាចស្ដាប់ ថតចម្លង និងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រវិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ប្រទេសកម្ពុជា ៖ ភាពចាំបាច់ក្នុងការញែកឱ្យឃើញពីភាពខុសប្លែកគ្នារវាងសេចក្ដីស្នេហាជាតិនិងការក្បត់ជាតិ

***ភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨***

***អត្ថបទសម្រាប់ពិភាក្សានៅក្នុងកម្មវិធីអប់រំ***

វាពិតជាមានសារសំខាន់ខ្លាំងណាស់ក្នុងការកំណត់ខ្សែបន្ទាត់ឲ្យបានច្បាស់លាស់រវាងខ្លួនរបស់យើងនិងខ្មាំង និងឈរនៅលើគោលជំហររបស់យើងដើម្បីធ្វើបដិវត្តន៍ ។ ជាដំបូង ចូរយើងកំណត់ខ្លួនឯងថាតើខ្លួនយើងជានរណា? «ខ្លួនយើង» មានន័យថាប្រជាជាតិ ប្រជាជន វណ្ណៈកម្មករនិងកសិករ ការធ្វើបដិវត្តន៍ ប្រព័ន្ធសមូហភាពនៃវណ្ណៈអធន សហករណ៍ សហគមន៍ពាណិជ្ជកម្ម កងទ័ពបដិវត្តន៍ និងគណបក្សកុម្មុយនីស្តកម្ពុជារបស់យើង ។ «ខ្មាំង» រួមមានអ្នកឈ្លានពានចក្រពត្តិនិយមនិងបាវបម្រើគ្រប់កន្លែង ខ្មាំងដែលមានបំណងចូលមកលេបទឹកដីរបស់យើង ខ្មាំងដែលត្រូវគេបញ្ជូនចូលនៅក្នុងជួរបដិវត្តន៍របស់យើង ខ្មាំងនៅក្នុងទម្រង់ជាវណ្ណៈនាយទុននិងសក្តិភូមិ និងវណ្ណៈអ្នកជិះជាន់ដទៃទៀត ខ្មាំងនៅក្នុងទម្រង់ជាប្រព័ន្ធឯកជននិងឯកត្តជន ហើយជាពិសេសគឺខ្មាំងវៀតណាមដែលនិយមពង្រីកទឹកដីនិងវាតទីទឹកដី ។ ដូច្នេះ វាគឺមានសារសំខាន់ណាស់ក្នុងកំណត់ឲ្យបានច្បាស់នូវភាពខុសគ្នារវាងសេចក្ដីស្នេហាជាតិនិងការក្បត់ជាតិ រវាងសេចក្ដីស្រឡាញ់សម្រាប់ជាតិនិងប្រជាពលរដ្ឋ និងការក្បត់ប្រទេសជាតិនិងប្រជាជន រវាងវណ្ណៈកម្មករនិងកសិករ និងវណ្ណៈនាយទុននិងសក្តិភូមិ និងវណ្ណៈអ្នកជិះជាន់ដទៃទៀត រវាងបដិវត្តន៍និងបដិវត្តន៍ប្រឆាំង រវាងប្រព័ន្ធសមូហភាពនៃវណ្ណៈអធន និងប្រព័ន្ធឯកជននៃវណ្ណៈអធនប្រឆាំងដទៃទៀត និងរវាងគណបក្សកុម្មុយនីស្តកម្ពុជានិងគណបក្សប្រឆាំងនឹងជាតិ និងគណបក្សបដិវត្តន៍ប្រឆាំង ។ វាសំខាន់ខ្លាំងណាស់ក្នុងការកំណត់ឲ្យបានច្បាស់លាស់លើផ្នែកនយោបាយ មនោគមន៍វិជ្ជា ការរៀបចំផ្គត់គំនិតបែបមនោសញ្ចេតនានិងប្រពៃណីនិងគោលជំហរ ។ នេះជាមូលដ្ឋានដំបូងនិងគ្រឹះចម្បងក្នុងការដឹកនាំបដិវត្តន៍ដល់ទីបញ្ចប់ ។

ទីមួយ មូលហេតុអ្វីបានជាវាសំខាន់សម្រាប់យើងក្នុងការបង្កើតនិងពង្រីកគោលជំហរនៃការកំណត់ឲ្យច្បាស់រវាងយើងនិងខ្មាំង? យើងម្នាក់ៗបានចូលរួមក្នុងបដិវត្តន៍ដើម្បីប្រឆាំងនឹងខ្មាំងនៃជាតិ ប្រជាជន វណ្ណៈ និងបដិវត្តន៍របស់យើង ។ នេះមិនមែនមានន័យថា យើងទាំងអស់គ្នាដឹងពីខ្មាំងបានច្បាស់លាស់និងកំណត់ឲ្យបានច្បាស់លាស់រវាងខ្លួនយើងនិងខ្មាំងទេ ។ មានមនុស្សជាច្រើនបានចូលរួមធ្វើបដិវត្តន៍លើកដំបូង ហើយបន្ទាប់មកចូលដៃខាងខ្មាំងប្រឆាំងនឹងបដិវត្តន៍ ។ នេះដោយសារតែគេឈរលើមូលដ្ឋានទន់ខ្សោយក្នុងការកំណត់ខ្សែបន្ទាត់ឲ្យបានច្បាស់លាស់រវាងខ្លួនឯងនិងខ្មាំង ។ ដើម្បីឲ្យស្គាល់ច្បាស់ពីខ្មាំង យើងត្រូវមានគោលជំហរផ្នែកនយោបាយ មនោគមន៍វិជ្ជា និងការរៀបចំឲ្យបានរឹងមាំឆ្ពោះទៅរកការវាយប្រហារខ្មាំងនៅទីបំផុត ។ ប្រសិនបើគ្មានការប្ដេជ្ញាចិត្តទៅប្រយុទ្ធដល់ទីបំផុតជាមួយខ្មាំង នោះការស្គាល់ខ្មាំងគឺគ្មានប្រយោជន៍នោះទេ ។

ឧទាហរណ៍ យើងបច្ចុប្បន្នប្រឆាំងនឹងប្រព័ន្ធឯកជននិងកម្មសិទ្ធិឯកជន ។ យើងដឹងពីគោលបំណងរបស់យើងបានច្បាស់លាស់ ។ ទោះបីជាយ៉ាងណាក៏ដោយ ពេលខ្លះការឈរលើមូលដ្ឋាននយោបាយ អារម្មណ៍ និងមនោគមន៍វិជ្ជាគឺមិនសូវរឹងមាំទេ ខណៈពេលដែលយើងមិនទាន់បានវែកញែកឲ្យបានច្បាស់លាស់រវាងខ្លួនយើងនិងខ្មាំង ។ ពួកយើងភាគច្រើននៅក្នុងករណីនេះមិនទាន់ធ្វើវាឲ្យដល់ទីបញ្ចប់នៅឡើយទេ ហើយចាញ់ការឃោសនាដែលធ្វើឡើងដោយខ្មាំងខាងក្នុងនិងខាងក្រៅជួររបស់យើងដើម្បីបន្ថុចឈ្មោះបក្សនិងប្រព័ន្ធសមូហភាពនៃវណ្ណៈអធន និងដើម្បីសសើរប្រព័ន្ធម្ចាស់កម្មសិទ្ធិនិងឯកជន ។ វាអាចនឹងត្រូវយកចូលមកខាងក្នុងតាមរយៈការឃោសនារបស់ខ្មាំង ហើយបាត់បង់ទាំងសេចក្ដីទុកចិត្តនិងភក្ដីភាពទៅលើបុព្វហេតុរបស់យើង ។ ទាំងទស្សនៈគំនិតនិងនយោបាយនៃមនុស្សទាំងនោះអាចត្រូវបានយកឈ្នះដោយខ្មាំង ។ នេះមានន័យថា ពួកគេអាចត្រូវបានប្រើប្រាស់ដោយខ្មាំងដើម្បីវាយប្រហារទៅលើជាតិសាសន៍ខ្លួនឯង ប្រជាជន វណ្ណៈកម្មករនិងកសិករ បដិវត្តន៍ ប្រព័ន្ធសមូហភាពនៃវណ្ណៈអធន និងបក្សកុម្មុយ-

នីស្តកម្ពុជា ។

ឧទាហរណ៍មួយផ្សេងទៀតអាចត្រូវបានលើកយកមកបង្ហាញ គឺកាលពីអតីតកាលខ្មាំងលែងផ្អែកគ្រប់កន្លែងដើម្បីបង្កប់នៅក្នុងសហករណ៍របស់យើងដើម្បីបំផ្លាញគម្រោងការដែលបានរៀបចំឡើងបីគោនក្នុងមួយហិកតា ដោយបក្សរបស់យើងនិងសហករណ៍ ។ នេះគឺអាចទៅបាន ពីព្រោះកម្មាភិបាលនិងសមមិត្តរបស់យើងមួយចំនួនមិនបានយកចិត្តទុកដាក់ទៅលើការកម្ចាត់ខ្មាំង ។ និយាយម្យ៉ាងទៀតថា ចលនានេះបានវាយកម្ចាត់ខ្មាំងដែលបង្កប់នៅក្នុងសហករណ៍ មិនមែនតែដាំស្លគ្រប់គ្រាន់ទេ ។ នេះអាចអនុញ្ញាតឲ្យគាត់អនុវត្តទៅតាមសកម្មភាពរបស់គាត់ ។ ការពន្យល់សម្រាប់បាតុភូតនេះ គឺឈរលើគោលជំហរកំណត់ខ្សែបន្ទាត់មួយឲ្យច្បាស់លាស់រវាងសហករណ៍និងខ្មាំងបង្កប់នៅក្នុងសហករណ៍ដែលនៅមិនទាន់បែងចែកច្បាស់នៅឡើយ ។

យើងគួរតែមានការយល់ដឹងឲ្យបានច្បាស់អំពីបដិវត្តន៍ ។ វាត្រូវបានគេកត់សម្គាល់ឃើញថា យើងពិបាកសម្គាល់ពាក្យសម្តីរបស់ប្រជាជនយើង វណ្ណៈកម្មករនិងកសិករ បដិវត្តន៍ ប្រព័ន្ធសមូហភាពនៃវណ្ណៈអធន សហករណ៍ សហគមន៍ពាណិជ្ជកម្ម កងទ័ពបដិវត្តន៍ បក្សកុម្មុយនីស្តកម្ពុជានិងខ្សែបន្ទាត់នយោបាយ មនោគមន៍វិជ្ជា ការរៀបចំរបស់បក្សយើង ។ គួររំឭកម្តងទៀតថា យើងគួរតែលះបង់អ្វីគ្រប់យ៉ាងទាំងអស់ទៅខាងយើង យើងត្រូវតែឈរនៅខាងយើង នៅខាងក្រៅ ហើយមិនត្រូវឈរនៅខាងខ្មាំងទេ ។ សមមិត្តរបស់យើងមួយចំនួនប្រហែលជាគិតថា បើសិនជាគេឈរនៅខាងខ្មាំង ខ្មាំងនឹងបញ្ឈប់នូវភាពជាខ្មាំងមកលើគេ ។ គេគិតខុសទាំងស្រុងហើយ ។ នេះមិនមែនជាការពិតទេ គឺថាខ្មាំងនឹង



ចុងភៅចែករបបអាហារនៅរោងបាយ

នៅតែជាខ្មាំង ។ ទោះបីជាយ៉ាងណាក៏ដោយមានករណីជាច្រើន ដែលគោលជំហររបស់យើងអាចត្រូវបានបំផ្លាញនិងរង្គោះរង្គើ ដែលវាមិនមែនជាលទ្ធផលផ្ទាល់នៃសកម្មភាពរបស់ខ្មាំងទេ ប៉ុន្តែដោយសារកត្តាផ្សេងៗដទៃទៀត ។ បើសិនជាអ្នកមិនគោរពយ៉ាងមុតមាំនៅខាងយើងឲ្យពិតប្រាកដទេ អ្នកនឹងមិនត្រូវបានគេរាប់រកនិងចូលទៅខាងខ្មាំងវិញហើយ ។

ឧទាហរណ៍ នៅពេលដែលអ្នកប្រៀបធៀបបដិវត្តន៍របស់យើងជាមួយបដិវត្តន៍នៅប្រទេសដទៃទៀត អ្នកនឹងឃើញថាមានភាពខុសប្លែកគ្នាខ្លាំងណាស់រវាងយើងនិងប្រទេសដទៃទៀត ។ ឧទាហរណ៍ ប្រទេសដទៃទៀតនៅតែមានរូបិយប័ណ្ណ ប្រព័ន្ធប្រាក់ខែ ទីផ្សារនិងទ្រព្យសម្បត្តិឯកជន ។ និយាយមួយម៉ាត់ យើងមិនដូចប្រទេសដទៃទេ ។ នៅក្នុងករណីនេះ តើអ្នកឈរនៅខាងយើងឬក៏ឈរនៅខាងអ្នកដទៃ? បើសិនជាអ្នករើសយកពេលក្រោយ អ្នកស្មគ្រ័ចិត្តឬអត់ថាមិនរត់ចោលខាងយើង ។ ដូច្នេះបើគ្មានជំហរឲ្យច្បាស់លាស់រវាងខ្លួនយើងនិងអ្នកដទៃទេ បន្តិចម្តងៗគំនិតនិងមនោគមន៍វិជ្ជារបស់ខ្មាំងនឹងជ្រាបចូលទៅក្នុងសតិអារម្មណ៍របស់យើង ហើយនឹងធ្វើឲ្យយើងបាត់បង់វិញ្ញាណក្នុងការញែកឲ្យដាច់រវាងខ្លួនយើងនិងខ្មាំង ។ នេះវាជារឿងមួយគ្រោះថ្នាក់ណាស់ ។ វាអាចទៅរួចដែលថាសមមិត្តរបស់យើងមួយចំនួនបានធ្លាក់នៅក្នុងអន្ទាក់នេះ ។



យើងត្រូវតែយកចិត្តទុកដាក់ថែរក្សានូវជំហរនយោបាយនិងអត្តការ រវាងខ្លួនយើងនិងអ្នកដទៃ ហើយដោះស្រាយនូវរាល់កត្តាទាំងអស់ ។ ដូច្នេះវាបង្ហាញសម្រាប់ខ្លួនយើងក្នុងការឈរនៅខាងយើង ។ យើងត្រូវតែឈរនៅខាងយើងជាដៃគូទាំងខ្លាំងនិងអ្នកដទៃ ។ យើងក៏ត្រូវតែប្រកាន់ខ្ជាប់នៅខាងយើងក្នុងការដោះស្រាយជាមួយកត្តាទាំងអស់ផងដែរ ។ បើមិនអ៊ីចឹងទេ យើងមិនអាចសម្គាល់នូវកម្លាំងពិតរបស់ខ្មាំង ឬក៏កម្លាំងបដិវត្តន៍របស់យើងទេ ។ គឺមានតែសម្គាល់ឲ្យបានច្បាស់នូវកម្លាំងបដិវត្តន៍និងជាពិសេសកម្លាំងកម្មករនិងកសិករដែលយើងអាចប្រមូលបានសម្រាប់ជាកម្លាំងបដិវត្តន៍របស់យើង ដើម្បីកម្ទេចនិងយកឈ្នះទៅលើខ្មាំង ។ មានតែវិធីមួយប៉ុណ្ណោះដែលយើងអាចដឹកនាំបដិវត្តន៍បានជោគជ័យពីជំហានមួយទៅជំហានមួយដោយអនុញ្ញាតឲ្យមានការចូលរួមនៅក្នុងនយោបាយរបស់បក្សយើង ។

ទីពីរ តើយើងអាចកសាងនិងពង្រឹងជំហរដែលយើងបានរៀបរាប់ខាងលើនេះបានដោយរបៀបណា? ដោយមិនស្ថិតនៅក្រោមកាលៈទេសៈនៃការរងរបួស ឬទុក្ខសោក ការរាំងស្ទះឬក៏ជ័យជម្នះក៏ដោយថាតើយើងគួរតែបញ្ឈប់នូវការពង្រឹងគោលជំហរនេះឬទេ? យើងគួរតែកសាង និងពង្រឹងជំហរនេះឲ្យបានច្បាស់ ដោយបែងចែករវាងខ្លួនយើងនិងខ្មាំង និងឈរនៅខាងយើងដើម្បីធ្វើបដិវត្តន៍នេះនៅគ្រប់ដំណាក់បដិវត្តន៍ទាំងអស់ ។ ដើម្បីរក្សាជំហរនយោបាយនេះឲ្យមានភាពរឹងមាំ ស្ថិតស្ថេរ គ្មានពីរនិងច្បាស់លាស់ យើងគួរតែថែរក្សាឲ្យបានខ្ជាប់ខ្ជួននៅក្នុងគំនិតរបស់យើងដូចខាងក្រោម ៖

ទី១) ហេតុអ្វីបានជាយើងធ្វើបដិវត្តន៍? យើងមិនមែនមកធ្វើឲ្យបដិវត្តន៍ដោយផងឹតផងល់ទេ ។ គ្មាននរណាម្នាក់បង្ខំឲ្យយើងធ្វើបដិវត្តន៍ទេ ។ យើងបានយល់ព្រមលះបង់អ្វីៗគ្រប់យ៉ាងទាំងអស់សម្រាប់បុព្វហេតុនេះ ពីព្រោះយើងចង់ឲ្យរួចផុតពីការគ្រប់គ្រងការគាបសង្កត់ និងការបង្ក្រាបដោយខ្មាំង និងជួយរំដោះវណ្ណៈកម្មករនិងកសិករយើង ។ សម្រាប់ហេតុផលនេះ យើងបានចូលរួមជាមួយមនុស្សដទៃដើម្បីអនុវត្តន៍បដិវត្តនៅក្រោមភាពជាអ្នកដឹកនាំរបស់បក្ស ។

ទី២) តើយើងព្យាយាមប្រឆាំងនរណានៅក្នុងបដិវត្តន៍? វាជាខ្មាំងនៃខ្មាំងរបស់ជាតិ ប្រជាពលរដ្ឋ បដិវត្តន៍ វណ្ណៈ ប្រព័ន្ធសមូហភាពនៃវណ្ណៈអធននិងបក្សរបស់យើង ។ គ្មានផ្លូវដែលយើងចូលរួមជាមួយខ្មាំងដើម្បីវាយប្រហារមកលើជាតិយើងខ្លួនឯងប្រជាជន វណ្ណៈ បដិវត្តន៍ ប្រព័ន្ធនិងបក្សទេ ។ បើមិនអ៊ីចឹងទេ យើងនឹងជាប់ឈ្មោះថាជាជនក្បត់ជាតិ ប្រជាជន វណ្ណៈ បដិវត្តន៍ ប្រព័ន្ធសមូហភាពនៃវណ្ណៈអធននិងបក្ស ។

ទី៣) តើគោលបំណងនៃបដិវត្តន៍ជាអ្វី? វាគឺសម្រាប់រំដោះជាតិ ប្រជាជន វណ្ណៈជិះជាន់ និងជាពិសេសវណ្ណៈកម្មករនិងកសិករ សម្រាប់ជាការធ្វើឲ្យល្អឡើងនៃការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនិងសម្រាប់ការកសាងសង្គមនិយមឲ្យទៅជាកុម្មុយនីស្តនិយមដើម្បីធ្វើឲ្យជាតិមានឥទ្ធិពល ថ្កុំថ្កើង និងរុងរឿង ។ វាមិនមែនជាប្រយោជន៍នៃភាពរុងរឿងផ្ទាល់ខ្លួន អំណោយ តួនាទី តំណែងឬការចំណេញផ្ទាល់ខ្លួនទេ ។ គោលដៅនៃបដិវត្តន៍របស់យើងគឺដើម្បីធ្វើឲ្យមានសុភមង្គលនិងភាពសុខដុមសម្រាប់សង្គមនៃវណ្ណៈអធនទាំងមូល ។

ទី៤) តើបដិវត្តន៍នេះបម្រើឲ្យនរណា? បដិវត្តន៍នេះរំដោះជាតិ ប្រជាជន និងជាពិសេសវណ្ណៈកម្មករ កសិករនៅក្រោមភាពជាអ្នកដឹកនាំរបស់បក្ស ។

ចំណុចដែលបានរៀបរាប់អំពីគោលជំហរច្បាស់លាស់ខាងលើនេះគួរតែបង្កើតឡើង បណ្តុះបណ្តាល ហើយពង្រឹងជាប្រចាំ ។ បើសិនជាជំហរនេះត្រូវបានពង្រឹងនិងបញ្ជាក់ឲ្យបានច្បាស់ នោះវានឹងអាចធ្វើឲ្យយើងមានអារម្មណ៍ដូចជា ទី១) ស្អប់ខ្មាំងជារៀងរហូត ទី២) យល់ដឹងយ៉ាងជ្រៅពីបដិវត្តន៍ចំពោះវណ្ណៈជិះជាន់ និងទី៣) ស្រឡាញ់ជាតិ បដិវត្តន៍ ប្រព័ន្ធសហករណ៍និងបក្ស ។ អារម្មណ៍ទាំងបីនេះបង្កើតបានជាមូលដ្ឋាននៃស្មារតីប្រយុទ្ធជាប្រចាំ ។

ដើម្បីថែរក្សានូវស្មារតីប្រយុទ្ធជាប្រចាំ ម្នាក់ៗត្រូវតែបង្កើននូវអារម្មណ៍ស្អប់ខ្ពើមចំពោះសត្រូវរបស់ខ្លួនជាប្រចាំ មានស្មារតីបដិវត្តន៍រឹងមាំ និងសេចក្តីស្នេហាជាតិខ្លាំង បដិវត្តន៍ វណ្ណៈ ប្រព័ន្ធសហករណ៍ និងបក្ស ។

ឧទាហរណ៍ មានតែនៅពេលអ្នកស្អប់ខ្មាំង និងអ្នកឈរនៅលើអារម្មណ៍មូលដ្ឋានបដិវត្តន៍ និងការស្រឡាញ់សម្រាប់ជាតិ បដិវត្តន៍ វណ្ណៈ ប្រព័ន្ធសហករណ៍និងបក្សប៉ុណ្ណោះដែលអ្នកអាចនៅយកចិត្តទុកដាក់ប្រឹងប្រែងកម្ចាត់និងកម្ទេចខ្មាំងដែលបង្កប់នៅក្នុងសហករណ៍ សហគមន៍និងក្រុមពាណិជ្ជកម្ម និងអាចទទួលបានជោគជ័យទាំងស្រុងនៅក្នុងការខិតខំដោះស្រាយបញ្ហានៃការចិញ្ចឹមជីវិតរបស់ប្រជាជន ដោយខិតខំបំពេញគម្រោង៣តោនក្នុងមួយហិកតា និង៦តោនក្នុងមួយហិកតាដែលបញ្ជាដោយបក្សនិងដោយព្យាយាមអនុវត្តនូវគ្រប់ភារកិច្ចទាំងអស់ដែលប្រគល់ឲ្យដោយបក្ស ។

បទពិសោធន៍បានបង្ហាញឲ្យឃើញថា បើគ្មានជំហរបដិវត្តន៍រឹងមាំ ការខិតខំទាំងអស់ដើម្បីបំពេញភារកិច្ចសំខាន់ មិនអាចទទួលបានជោគជ័យទាំងស្រុងឡើយ ។ បទពិសោធន៍ពីអតីតកាលនៅក្នុងចលនាបដិវត្តន៍របស់យើងនៅគ្រប់ជំនាន់បានបង្ហាញឲ្យឃើញថា និន្នាការចំពោះកម្មសិទ្ធិឯកជននិងជាពិសេសចំពោះឱកាសនិយមឬស្តាំនិយម គឺជាលទ្ធផលនៃការបែងចែកមិនបានច្បាស់លាស់រវាងខ្លួនយើងនិងខ្មាំង ។ ដូច្នេះ វាងាយស្រួលសម្រាប់ខ្មាំងក្នុងការងាកទៅរកអ្នកដែលមិនអាចញែកឲ្យបានដាច់រវាងអ្នកដែលប្រឆាំងជាតិខ្លួនឯងនិងបដិវត្តន៍យើង ។ ទោះបីជាគេមិនអាចយកឈ្នះទាំងស្រុងទៅលើភាគីខាងខ្មាំង ប៉ុន្តែកត្តាទាំងនេះមិនមានប្រយោជន៍ដល់បដិវត្តន៍និងបក្សដូចដែលគេព្រួយបារម្ភតែអំពីផលប្រយោជន៍ឯកជននិងបុគ្គលទេ ។ គេគឺជាអ្នកឱកាសនិយម ដោយសារតែពួកគេមិនបានប្តេជ្ញាចិត្តទាំងស្រុងចំពោះបដិវត្តន៍ និងបោះជំហានទៅមុខ ដកថយ និងបោះជំហានទៅមុខមួយជំហានទៅខាងស្តាំឬខាងឆ្វេងដោយភាពងាយស្រួល ។ ជំហរបែបនេះត្រូវបានគេចាត់ទុកថាគ្រោះថ្នាក់ខ្លាំងណាស់ដល់បដិវត្តន៍និងត្រូវបានកម្ទេច ។

នៅក្នុងពិភពលោកនាបច្ចុប្បន្ននេះ ខ្មាំងមាននៅគ្រប់កន្លែងទាំងអស់ ដូចជាពួកចក្រពត្តិនិយម ពួកពង្រីកឬវាតទីនិយមវៀតណាម គឺបែរមកប្រើឧបាយកលគ្រប់ប្រភេទទាំងអស់ដើម្បីពន្លិចគោលជំហររបស់យើងដើម្បីកំណត់ខ្សែបន្ទាត់ឲ្យបានច្បាស់លាស់រវាងខ្លួនយើងនិងខ្មាំង ។ ក្នុងចំណោមឧបាយកលទាំងនេះ គឺមានទាំងឧបាយកលដោយសម្ងាត់និងបញ្ចេញឲ្យឃើញផ្ទាល់ កលល្បិចនិងផែនការដោយស្របច្បាប់និងខុសច្បាប់ដែលស្ថិតនៅក្នុងទម្រង់ជាកិច្ចព្រមព្រៀងដើម្បីផ្តល់ជំនួយនេះឬជំនួយនោះ និងថែមទាំងប្រើប្រាស់នូវស្លាកឈ្មោះ «មិត្តភាពល្អជានិរន្តរ៍» ក្នុងគោលបំណងឈ្លានពានប្រឆាំងនឹងប្រទេសដទៃនិងលេបជាតិដទៃ ។ ដូច្នេះយើងគួរតែលើកតម្កើងបដិវត្តន៍យ៉ាងប្រយ័ត្នប្រយែងប្រឆាំងទៅនឹងខ្មាំងខាងក្នុងនិងខាងក្រៅនៅគ្រប់កន្លែងទាំងអស់និងខំប្រឹងពង្រឹងជំហរក្នុងការកំណត់ ។

ខ្សែបន្ទាត់ឲ្យបានច្បាស់រវាងខ្លួនឯងនិងខ្មាំង ហើយយើងត្រូវគាំទ្រភាគីខាងយើងដើម្បីបន្តបដិវត្តន៍ស្របទៅតាមគោលជំហរនយោបាយ មនោគមន៍វិជ្ជា និងការរៀបចំរបស់បក្សកុម្មុយនីស្តកម្ពុជា ។ **ឯកសារ D៣០២៧៧**

# កិច្ចការផ្ទៃក្នុងសន្និសីទផ្នែកវេជ្ជសាស្ត្រថ្នាក់ជាតិលើកទីមួយ
# អត្ថបទរាយការណ៍នៃសន្និសីទ និងការដោះស្រាយ

សមាជិកកងវេជ្ជសាស្ត្រមកពីតាមភូមិភាគនិងតំបន់និង បុគ្គលិកពេទ្យមកពីសាខាបីនៃកងកម្លាំងប្រដាប់អាវុធ មកពីអគ្គសេនាធិការក្រសួង និងផ្នែកផ្សេងៗរបស់រដ្ឋាភិបាលបានជួបគ្នាពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែតុលានៅក្នុងសន្និសីទផ្នែកវេជ្ជសាស្ត្រថ្នាក់ជាតិលើកទីមួយចាប់តាំងពីថ្ងៃរំដោះ ទី១៧ ខែមេសា ។ លេខាធិការនៃបក្សកុម្មុយនីស្តកម្ពុជា សមមិត្ត ប៉ុល ពត បានបើកសន្និសីទមួយដោយផ្ទាល់ខ្លួននិងធ្វើរបាយការណ៍អំពីបញ្ហាសំខាន់ៗមួយចំនួនលើផ្នែកកិច្ចការសង្គមនិងសុខភាពដែលទាក់ទងទៅនឹងគោលជំហរឯករាជ្យ ភាពចេះដឹង និងការជឿជាក់លើខ្លួនឯងនៃបក្សកុម្មុយនីស្តកម្ពុជា ។

បន្ទាប់ពីកិច្ចពិភាក្សារអស់រយៈពេល៣ថ្ងៃនិងមួយព្រឹកបន្ថែមទៀត សន្និសីទនេះបានទទួលយកជាឯកច្ឆន្ទនូវដំណោះស្រាយដូចខាងក្រោម ៖

១) ប្រកាន់ខ្ជាប់យ៉ាងមុតមាំ និងនៅគ្រប់កាលៈទេសៈទាំងអស់ចំពោះគោលជំហរឯករាជ្យ ភាពចេះដឹង និងការជឿជាក់លើខ្លួនឯង និងដោះស្រាយដើម្បីប្រតិបត្តិយ៉ាងត្រឹមត្រូវលើគោលជំហររបស់បក្សផ្នែកកិច្ចការសង្គមនិងសុខភាពដោយ ៖ ក) ការពារនូវជំងឺទាំងអស់ និង ខ) ផ្តល់នូវឱសថព្យាបាលយ៉ាងយកចិត្តទុកដាក់ដល់អ្នកជំងឺ ។ ដើម្បីការពារជំងឺ យើងត្រូវតែយកចិត្តទុកដាក់លើផ្នែកអនាម័យនិងចំណីអាហារ ។ ទាំងអស់នេះត្រូវបានបង្កើតឡើងដើម្បីធ្វើឲ្យប្រសើរឡើងនូវសុខភាពរបស់ប្រជាពលរដ្ឋនិងដើម្បីបង្កើនចំនួនប្រជាជនពី១៥លានទៅ២០លាននាក់នៅក្នុងរយៈពេលពី១០ទៅ១៥ឆ្នាំខាងមុខ ។

២) ប្រកាន់ខ្ជាប់យ៉ាងមុតមាំ និងនៅគ្រប់កាលៈទេសៈទាំងអស់ចំពោះគោលជំហរឯករាជ្យ ភាពចេះដឹង និងការជឿជាក់លើខ្លួនឯងនៃបក្សកុម្មុយនីសកម្ពុជានិងដោះស្រាយដើម្បីថែរក្សានូវធនធានរបស់យើង ដោយកាត់បន្ថយការនាំចូលនៃឧបករណ៍វេជ្ជសាស្ត្របរទេសឲ្យមានចំនួនតិច ដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុកឲ្យបានច្រើន និងដោយការផលិត ការស្រាវជ្រាវ ការប្រើប្រាស់ឲ្យកាន់តែច្រើននិងធ្វើឲ្យកាន់តែប្រសើរឡើងនូវឱសថដែលផលិតក្នុងស្រុក ។

៣) ប្រកាន់ខ្ជាប់យ៉ាងមុតមាំ និងនៅគ្រប់កាលៈទេសៈទាំងអស់ចំពោះគោលជំហរឯករាជ្យ ភាពចេះដឹង និងការជឿជាក់លើខ្លួនឯងនៃបក្សកុម្មុយនីស្តកម្ពុជានិងដោះស្រាយដើម្បីប្រើប្រាស់ឱសថទំនើបៗជាមួយការយកចិត្តទុកដាក់សម្រាប់ជំងឺជាក់លាក់បន្ទាប់ពីពិនិត្យរោគរួចហើយដើម្បីធានាថាឱសថដែលយកមកព្យាបាលមានប្រសិទ្ធភាព ដើម្បីការពារសុខភាពរបស់សមមិត្តរួមប្រដាប់អាវុធយើង និងដើម្បីរក្សាឧបករណ៍ពេទ្យ ។

៤) ប្រកាន់ខ្ជាប់យ៉ាងមុតមាំ និងនៅគ្រប់កាលៈទេសៈទាំងអស់ចំពោះគោលជំហរឯករាជ្យ ភាពចេះដឹង និងការជឿជាក់លើខ្លួនឯងនៃបក្សកុម្មុយនីស្តកម្ពុជានិងដោះស្រាយដើម្បីធ្វើឲ្យឱសថព្យាបាលមានលក្ខណៈស្តង់ដារពាសពេញផ្ទៃប្រទេសតាមរយៈ ក) យកចិត្តទុកដាក់លើចំណីអាហារ ខ) យកចិត្តទុកដាក់លើអនាម័យ កិច្ចការនយោបាយនិងមនោគមន៍វិជ្ជា គ) ចងភ្ជាប់កិច្ចការសំខាន់ជាងគេបំផុតលើការប្រើប្រាស់ឱសថដែលផលិតក្នុងស្រុករួមទាំងដំណោះស្រាយលើថ្នាំសម្លាប់មេរោគ ឃ) ប្រើប្រាស់ឱសថទំនើបៗដែលមានអារម្មណ៍ខ្ពស់លើការទទួលខុសត្រូវនៃបដិវត្តន៍និងប្រើប្រាស់តែឱសថដែលបានអនុញ្ញាតឲ្យប្រើរួចហើយ ។

៥) ប្រកាន់ខ្ជាប់យ៉ាងមុតមាំ និងនៅគ្រប់កាលៈទេសៈទាំងអស់ចំពោះគោលជំហរឯករាជ្យ ភាពចេះដឹង និងការជឿជាក់លើខ្លួនឯងនៃបក្សកុម្មុយនីស្តកម្ពុជានិងដោះស្រាយដើម្បីប្រើប្រាស់ឱសថឲ្យមានលក្ខណៈស្តង់ដារពាសពេញផ្ទៃប្រទេសដោយយោងទៅលើទម្ងន់នៃករណីមួយៗ ។

៦) ប្រកាន់ខ្ជាប់យ៉ាងមុតមាំ និងនៅគ្រប់កាលៈទេសៈទាំងអស់ចំពោះគោលជំហរឯករាជ្យ ភាពចេះដឹង និងជឿជាក់លើ

ខ្លួនឯងនៃបក្សកុម្មុយនីស្តកម្ពុជា និងដោះស្រាយដើម្បី ក) សន្សំ និងការពារនូវឱសថដែលផលិតក្នុងស្រុកនិងឱសថទំនើបៗដែលនាំចូលទាំងអស់សម្រាប់ប្រើប្រាស់រយៈពេលយូរដើម្បីបម្រើប្រជាជនរបស់យើងនិងកងកម្លាំងប្រដាប់អាវុធបដិវត្តន៍កម្ពុជាឲ្យច្រើនបំផុត ខ) និងដើម្បីសន្សំនិងការពារឧបករណ៍ពេទ្យគ្រប់ប្រភេទសម្រាប់ប្រើប្រាស់រយៈពេលយូរ ដើម្បីធានាថាប្រជាជននិងកងកម្លាំងប្រដាប់អាវុធបដិវត្តន៍កម្ពុជាយើងច្រើនបំផុតមានសុខភាពល្អ ។

ទាំងអស់នេះ គឺរៀបចំឡើងដើម្បីសន្សំធនធានរបស់យើងសម្រាប់ធ្វើឲ្យលក្ខខណ្ឌរស់នៅ និងសុខភាពរបស់ប្រជាជនយើងកាន់តែប្រសើរឡើង និងដើម្បីកសាងប្រទេសឲ្យរីកចម្រើន ។

៧) សម្រេចការគ្រប់គ្រងលើជំងឺទាំងអស់និងការប្រើប្រាស់ឱសថ ។ សន្និសីទបានសម្រេចថា វាសំខាន់ខ្លាំងណាស់ ក) ដើម្បីផ្លាស់ប្តូរព័ត៌មានវេជ្ជសាស្ត្ររៀងរាល់២ខែម្តង ខ) និងធ្វើសិក្ខាសាលារៀងរាល់៦ខែម្តង ។

សន្និសីទផ្នែកវេជ្ជសាស្ត្របានបញ្ចប់ជាមួយនឹងសុទិដ្ឋិនិយមបដិវត្តន៍ និងបង្ហាញនូវភាពជឿជាក់ទាំងស្រុងនៅក្នុងអនាគតដ៏ត្រចះត្រចង់នៃផ្នែកកិច្ចការសង្គមនិងសុខភាពដែលត្រូវបានបញ្ចូលពាសពេញផ្ទៃប្រទេសដើម្បីធានាឲ្យមានសុខភាពល្អសម្រាប់ប្រជាជនរបស់យើង និងកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ដែលស្ថិតនៅក្រោមគោលជំហរឯករាជ្យ ភាពចេះដឹង និងជឿជាក់លើខ្លួនឯងនៃបក្សកុម្មុយនីស្តកម្ពុជា ។ **D ៣០៩៤២**

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តនៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនទ្រុសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

"ការិយាល័យព័ត៌មានសាធារណៈ" មានផ្តល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ឺ សារីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ទីបំផុតនៅរស់តែម្នាក់ឯង



ស៊ិន ផល

ស៊ិន ផល សព្វថ្ងៃមានអាយុ៥៥ ឆ្នាំ រស់នៅភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។ ផល មានស្រុកកំណើតនៅឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង។ ពេលដែល ផល ចាកចេញពីផ្ទះទៅធ្វើការនៅមន្ទីរស្រុកកំចាយមារ ប្រធានស្រុកមិនព្រមទទួលទេ ប៉ុន្តែ ផល ជាយុវនារីមានវ័យ១៦ឆ្នាំ ចង់ដឹង ចង់យល់ពីការអនុវត្តរបស់ខ្លួន។ ផល ពិតជាមានគំនិតចង់ធ្វើអ្វីៗឲ្យបានដូចជាមនុស្សធំដែរ និងធ្វើការឲ្យបានគ្រប់ទីកន្លែង។ ផល ខិតខំធ្វើការទៅតាមមាគ៌ាបដិវត្តន៍ និងបម្រើបដិវត្តន៍ដោយក្ដីស្មោះត្រង់។ តែនៅទីបំផុតរាល់ការតស៊ូរបស់ ផល ទាំងប៉ុន្មានបានត្រឹមតែរស់នៅម្នាក់ឯង ព្រោះឪពុកម្ដាយស្លាប់អស់។

នៅឆ្នាំ១៩៧២ ផល បានសម្រេចចិត្តឈប់រៀនត្រឹមថ្នាក់ទី១០(ចាស់) មកធ្វើការនៅផ្ទះជាមួយឪពុកម្ដាយវិញ។ ក្រោយពីទទួលការអនុញ្ញាតពីឪពុកម្ដាយឲ្យចូលធ្វើបដិវត្តន៍ ផល ក៏បានមកធ្វើការនៅសាលាស្រុកកំចាយមារ។ ប៉ុន្តែរយៈពេលពីរសប្ដាហ៍ក្រោយមក ឪពុករបស់ ផល បានមកសុំយកគាត់ឲ្យត្រឡប់មកផ្ទះវិញ ពីព្រោះតែឪពុករបស់គាត់ព្រួយបារម្ភពីសុវត្ថិភាពរបស់គាត់ខ្លាំងពេក។ ដោយសារការតាំងចិត្តកាលពីមុនថានឹងតស៊ូដើម្បីរំដោះប្រទេសឲ្យមានសន្តិភាព ផល បានបដិសេធមិនព្រមទៅជាមួយឪពុករបស់គាត់ទេ។ ពីរខែក្រោយពីការខិតខំប្រឹងប្រែងធ្វើការ ផល ក៏ទទួលបានលទ្ធផលល្អ ដោយគាត់ត្រូវបានឡើងតំណែងជាប្រធានយុវនារីប្រចាំមន្ទីរស្រុកកំចាយមារ។ នៅខែមករា ឆ្នាំ១៩៧៥ ផល បានសុំអនុញ្ញាតពីប្រធានស្រុកកំចាយមារឈ្មោះ បូរ ចូលធ្វើជាកងទ័ពនារីវិញ។ ដំបូងកងទ័ពនារីទាំងអស់ត្រូវឲ្យហ្វឹកហ្វឺនអំពីក្បួនយុទ្ធសាស្ត្រនៅភូមិគោកគង់ (ស្រុកកញ្ជ្រៀច) រយៈពេល៣ខែសិនមុននឹងចេញទៅសមរភូមិ។ នៅទីនេះ ផល ត្រូវបានតែងតាំងឲ្យធ្វើជាប្រធានកងហ ក្នុងកងពល ៥៥២ ក្រោមការគ្រប់គ្រងរបស់ វ៉ូវ ជាប្រធានកងទ័ពនារី។

បន្ទាប់ពីបញ្ចប់វគ្គហ្វឹកហ្វឺន ផល មិនដែលបានចេញប្រយុទ្ធនៅសមរភូមិទេ ព្រោះកងទ័ពខ្មែរក្រហមបានទទួលជ័យជម្នះទាំងស្រុងពេញប្រទេសកម្ពុជានៅឆ្នាំ១៩៧៥ហើយ។ ពេលនោះអង្គការបានបែងចែក ផល ឲ្យទៅធ្វើការនៅរោងចក្រតម្បាញ ត-១វិញ ដែលនៅទីនេះមានបែងចែកការងារជាច្រើនផ្នែកដូចជាផ្នែកតម្បាញអំបោះ ជ្រលក់ពណ៌ បច្ចេកទេសម៉ាស៊ីននិងការងារទូទៅក្រោមការគ្រប់គ្រងរបស់ តាចេង អន ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ហ៊ាន ជាប្រធានរោងចក្រដែលជាអ្នកស្រុកកំចាយមារ និង វ៉ុន (ស្រី) ជាអនុប្រធាន។ ផល ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានផ្នែកតម្បាញមានសមាជិកចំនួន៤០០នាក់។ ការងារនេះមិនសូវមានពេលទំនេរទេ ព្រោះធ្វើការទាំងយប់ទាំងថ្ងៃ ហើយផ្លាស់វេនគ្នាទៅតាមម៉ោងពេលដែលប្រធានរោងចក្របែងចែកទៀត ដូចជាត្រូវធ្វើការចាប់ពីម៉ោង៥ព្រឹកដល់ម៉ោង១១យប់។ ប៉ុន្តែក្នុងរយៈពេលមួយខែ កម្មករទាំងអស់អាចឈប់សម្រាកបានបីថ្ងៃដែរ គឺនៅថ្ងៃទី១០ ទី២០ និងទី៣០។ កម្មករទាំងអស់ចេះសាមគ្គីគ្នាល្អណាស់ ទោះជាមកពីភូមិភាគផ្សេងៗពីគ្នាក៏ដោយ។ ក្រៅពីការងារនេះ នៅពេលល្ងាចគាត់ត្រូវប្រជុំបូកសរុបសកម្មភាពការងារដែលធ្វើបាននិងគ្រប់គ្រងកម្មការិនីចំនួន១០០នាក់ក្នុងរោងចក្រតម្បាញត-១ ដើម្បីទទួលភ្ញៀវបរទេសដែលមកទស្សនកិច្ចនៅប្រទេសកម្ពុជាទៀត ដោយឲ្យមកជួបជុំគ្នានៅព្រលានយន្តហោះពោធិ៍ចិនតុង។ ទោះបីជា ផល ជាអ្នករៀបចំកម្មវិធីនេះក៏ដោយ ប៉ុន្តែគាត់មិនបានដឹងថាភ្ញៀវបរទេសទាំងនោះមកពីប្រទេសណាទេ ព្រោះអង្គការមិនដែលប្រាប់គាត់សោះ។

នៅឆ្នាំ១៩៧៨ ស្រាប់តែមានការចាប់ប្រធានរោងចក្រ និងប្រធានផ្នែកមួយចំនួនដែលសង្ស័យថាជាជនក្បត់អង្គការ ដូចជា ហ៊ាន ជាប្រធានរោងចក្រ វ៉ុន ជាអនុប្រធាន វង់ ជាប្រធានផ្នែកជ្រលក់អំបោះ សុផល និង ទៀង ដែលជាប្រធានផ្នែកផ្សេង

ទៀត ។ ក្រោយពេលដែលដឹងថាអ្នកទាំងនោះក្បត់ កម្មកររោងចក្រម្នាក់ៗមានអារម្មណ៍ខ្លាចណាស់ ព្រោះគិតថាទោះបីជាអ្នកទាំងនោះធ្វើការហ្មត់ចត់ ច្បាស់លាស់ សកម្ម និងខិតខំអនុវត្តតាមការចាត់តាំងរបស់អង្គការក៏ដោយ ក៏នៅតែត្រូវអង្គការចាប់ខ្លួនដដែល ។ ប៉ុន្តែ ផល ខុសពីអ្នកទាំងនេះ ដោយគាត់ត្រូវបានអង្គការទុកចិត្ត និងដំឡើងតំណែងឲ្យធ្វើជាប្រធានរោងចក្រតម្បាញត–១ជំនួសអ្នកចាស់វិញ ។ ដូច្នេះ ផល មិនដែលធ្វើអ្វីឲ្យមានកំហុសនោះទេ ហើយហ៊ានតវ៉ាប្រឆាំងនឹងអង្គការថែមទៀតប្រសិនបើគាត់យល់ថាវាមិនត្រឹមត្រូវ ។ ជាក់ស្តែង ពេលអង្គការចាប់ខ្លួនឈ្មោះ ណេន និង ផាន់ ដែលជាអ្នកបើកឡានឲ្យប្រធានរោងចក្រនិងកម្មករក្នុងរោងចក្រក្នុងថ្ងៃសម្រាក ផល បានទាមទារឲ្យមានការដោះលែងអ្នកទាំងពីរជាមួយតា ចេង អន ដែលជាអ្នកចេញបញ្ជាឲ្យចាប់ខ្លួនអ្នកទាំងពីរ ។ ផល និង នាង ដែលមានឋានៈដូចគាត់បានតវ៉ារឿងនេះចំនួន៣លើក ព្រោះ ផល មានការអាណិតអ្នកទាំងពីរដែលជាមនុស្សស្មោះត្រង់និងនៅវ័យក្មេង ។ លើកទី១ ផល បាននិយាយជាមួយតា ចេង អន ថា «ណេន និង ផាន់ មិនដែលធ្វើសកម្មភាពខុសឆ្គងក្នុងការងារទេ ហើយអ្នកទាំងពីរខំធ្វើការងារតាមផែនការអង្គការដាក់ឲ្យទៀត» ។ បន្ទាប់មក តាចេង អន សួរបញ្ជាក់ថា «ហេតុអ្វីបានជាហ៊ានឡើងនិយាយតវ៉ាជាមួយខ្ញុំ បើអ្នកខ្លះគេខ្លាច» ផល និយាយបន្តថា «ប្រសិនបើខ្ញុំធ្វើខុស ទើបខ្ញុំខ្លាច ប៉ុន្តែខ្ញុំមិនបានធ្វើអ្វីខុសផង ខ្ញុំគ្រាន់តែមកនិយាយជាមួយលោកអ៊ំ តើអ៊ំមានមតិយ៉ាងម៉េច? តើអ្នកទាំងពីរមានការខុសឆ្គងអ្វីខ្លះ?» ។ ផល ធ្លាប់បានរៀនសូត្រជាមួយ តាចេង អន ដូច្នេះគាត់ពុំសូវមានការភ័យខ្លាចប៉ុន្មានទេនៅពេលនិយាយរឿងនេះ ។ លើកទី២ ផល បានយកកន្ទេល មុង និង ភួយ ទៅឲ្យអ្នកទាំងពីរដល់កន្លែងឃុំខ្លួនក្នុងក្រសួងឧស្សាហកម្ម ។ លើកនេះ តាចេង អន បានប្រាប់ ផល ថា «រយៈពេល៣ថ្ងៃ ចាំមកម្តងទៀត» ។ ដល់ថ្ងៃកំណត់ ផល ទៅជួប តាចេង អន ដោយលើកហេតុផលថា «នៅក្នុងរោងចក្រអត់មានអ្នកជំនួសកន្លែងអ្នកបើកបររថយន្តសម្រាប់ដឹកកម្មករទៅធ្វើការនៅខាងក្រៅក្នុងថ្ងៃសម្រាកទេ» ។ តាចេង អន បានប្រាប់មកវិញថា «ចាំពិនិត្យលើការងារអ្នកទាំងពីរនេះរយៈពេល៣ទៅ៤ថ្ងៃទៀតសិន» ។ លើកទី៣ តាចេង អន ក៏អនុញ្ញាតឲ្យ ផល យកអ្នកទាំងពីរមកធ្វើការនៅរោងចក្រដូចធម្មតាវិញ ប៉ុន្តែផ្តាំថា ត្រូវពិនិត្យនិងតាមដានអ្នកទាំងពីរបន្ថែម ។ អ្នកទាំងពីរសប្បាយចិត្តណាស់ ហើយថែមទាំងអរគុណ ផល ដែលធ្វើឲ្យពួកគេមានជីវិតថ្មី រួចប្តេជ្ញាចិត្តថា «នឹងខំធ្វើការបម្រើរោងចក្រតទៅទៀត» ។ ពេលត្រឡប់មកវិញ ផល បានប្រជុំប្រាប់កម្មករទាំងអស់ថា «កុំឲ្យអស់ទឹកចិត្តធ្វើការ យើងត្រូវតាំងចិត្តខិតខំធ្វើការងារកុំឲ្យដំណើរការរោងចក្ររអាក់រអួល» ។

នៅឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមចាប់ផ្តើមវាយសម្រុកចូលទីក្រុងភ្នំពេញ ផល បានសម្រេចចិត្តរត់ឡើងភ្នំជាមួយកងទ័ពដែលប្រចាំការនៅព្រលានយន្តហោះពោធិ៍ចិនតុងនិងប្រធានកងទ័ពឈ្មោះ ខា ។ ផល សម្រេចចិត្តមិនត្រឡប់មកផ្ទះទេ ព្រោះតែមានពាក្យចចាមអារ៉ាមថា ប្រសិនបើកងទ័ពវៀតណាមចាប់បាននឹងអារ–កប្មសម្លាប់ចោល ។ ពេលរត់មកដល់ភ្នំ ក្រុមរបស់ ផល ដែលនៅសល់គ្នា១០នាក់ បានឃើញមនុស្សភាគច្រើន

ការដ្ឋានសាងសង់ទំនប់ប្រឡាយ (រូបថត ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)



អត់មានបាយហូបទេ ។ ឃើញដូច្នេះ ផល បានយកបាយដែលបានដាក់តាមខ្លួនមកឲ្យអ្នកទាំងនោះហូប ។ មួយរយៈក្រោយមក ក្រុមរបស់ ផល បានសម្រេចចិត្តបន្តដំណើរទៅមុខទៀត ។ ពេលធ្វើដំណើរ ផល បានជួបក្មេងប្រុសម្នាក់អាយុប្រហែល២ឆ្នាំដែលវង្វេងម្តាយនៅលើភ្នំ ។ ផល បានសួរថា *«ហេតុអីបានជាមកទីនេះ?»* ក្មេងនោះប្រាប់ថា *«ម៉ែទៅបាត់ហើយ»* ។ ពេលនោះ ផល សួរទៅកាន់សមាជិកក្រុមរបស់គាត់ថា *«តើយើងនាំក្មេងនេះទៅជាមួយដែរឬទេ?»* ក្រោយពីពិភាក្សាគ្នារួច ក្រុមរបស់គាត់បានសម្រេចចិត្តយកក្មេងនោះទៅជាមួយដែរ ។ ធ្វើដំណើរជិតដល់ជំរំក្លាំងយ៉ៃ ក្មេងនោះក៏បានជួបជាមួយម្តាយវាវិញ (ស្រុកកំណើតនៅខេត្តតាកែវ) ។ ដោយសារឆ្ងល់ថាតើហេតុអ្វីបានម្តាយរបស់ក្មេងនេះបោះបង់កូនចោល ផល បានស្តីបន្ទោសថា *«បើសិនខ្ញុំអត់ឃើញកូនរបស់អ្នក កូននេះច្បាស់ជាស្លាប់ហើយ ព្រោះគ្មានអ្នកណាមើល»* ។ គាត់បានប្រាប់ថា *«ប្តីខ្ញុំរត់ចោល គ្រួសារខ្ញុំពិបាកពេកទើបទុកកូននេះចោលទៅ»* ។ ផល ពន្យល់ប្រាប់ថា *«ទោះបីពិបាកយ៉ាងណាក៏ដោយ មិនត្រូវទុកកូនចោលដែរ ត្រូវតែតស៊ូចិញ្ចឹមវាឥឡូវបើសុំវិញ ខ្ញុំសុខចិត្តប្រគល់ឲ្យ តែកុំទុកកូនចោលទៀត»* ។ ទោះបីជាមានការលំបាកទាំងការធ្វើដំណើរនិងត្រូវមើលថែទាំក្មេងនេះក៏ដោយ ប៉ុន្តែ ផល មិនដែលត្អូញត្អែរថាពិបាកឡើយ ហើយថែមទាំងសប្បាយចិត្តទៀតផង ។ ផល រៀបរាប់ថា *«យើងមានជាតិសាសន៍ខ្មែរដូចគ្នា យើងត្រូវចេះជួយគ្នាទៅវិញទៅមក ក្រែងថ្ងៃក្រោយទៅយើងមានការអី គេអាចជួយយើងវិញ»* ។



នៅខែមិថុនា ឆ្នាំ១៩៧៩ ក្រុមរបស់ ផល បានចូលមកដល់ជំរំក្លាំងយ៉ៃ ។ ដោយសារតែនៅជំរំនេះមានទាហានថៃចាប់ស្ត្រីរំលោភលើរូបរាងកាយ មួយសប្តាហ៍ក្រោយមក ក្រុមរបស់គាត់ក៏សម្រេចចិត្តមករស់នៅអន្លង់ភាពចាស់នៅស្រុកកំណើតវិញ ដោយធ្វើដំណើររយៈពេលមួយខែ១០ថ្ងៃ ។ នៅខែកក្កដា ឆ្នាំ១៩៧៩ ផល ធ្វើការជាកងដឹកជញ្ជូនក្នុងវរសេនាធំលេខ៧០៥ វរសេនាតូចលេខ៧៥ទទួលបន្ទុកយោធា (ផ្សព្វផ្សាយអប់រំនយោបាយ) ។ ក្នុងពេលធ្វើការ ផល តែងតែព្យាយាមស៊ើបរកដំណឹង ណាន ជានិច្ច ។ មិនយូរប៉ុន្មាន ផល បានជួប ណាន នៅឃុំបឹងបេង ស្រុកម៉ាឡៃ ។ ប៉ុន្តែ ណាន មានជំងឺហើមជើង ។ ដោយសារហេតុនេះ ផល ក៏បញ្ជូនគាត់ទៅព្យាបាលមន្ទីរពេទ្យ និងជួយមើលថែទាំគាត់រហូតដល់ជាសះស្បើយ ។ បន្ទាប់មក ផល ណែនាំ ណាន ឲ្យរៀបការម្តងទៀត ។ ណាន និងប្រពន្ធខស្បាហ៍មកលេងជាមួយ ផល ញឹកញាប់ណាស់មកដល់សព្វថ្ងៃ ។ អ្នកទាំងពីរមិនអាចបំភ្លេចគុណដែល ផល បានជួយសង្គ្រោះជីវិត និងរៀបចំពិធីមង្គលការឲ្យទេ ។ ណាន និងប្រពន្ធសព្វថ្ងៃរស់នៅ ភូមិគីឡូ១៣ ស្រុកសំពៅលូន និងមានកូន៣នាក់ ។

សព្វថ្ងៃនេះ ផល មានមុខងារជាអនុភូមិស្វាយធំ និងធ្វើចម្ការបន្តិចបន្តួចដើម្បីចិញ្ចឹមកូន៣នាក់ ។ ប៉ុន្តែ ផល មិនសូវសប្បាយចិត្តទេ ព្រោះឪពុកម្តាយ ប្តីរបស់គាត់ស្លាប់អស់ហើយ ។ ទោះយ៉ាងណាក៏ដោយ ក៏ ផល នៅមាន ណាន និងប្រពន្ធដែលជាសាច់ញាតិដ៏ជិតស្និទ្ធបំផុតរបស់គាត់ដែរ ។

**ហ៊ិន សុធានី**

# អំពើល្អរបស់ សៅ វ៉ាន់

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើង ខ្មែរក្រហមបានជម្លៀសប្រជាជនឲ្យទៅកាន់ទីជនបទ ដោយបង្អត់អាហារ បង្ខំឲ្យធ្វើការហួសកម្លាំង និងយកមនុស្សទៅសម្លាប់ដោយគ្មានជំនុំជម្រះទោសតាមផ្លូវច្បាប់ឡើយ ។ អ្នកដែលធំដឹងក្តីនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនិងក្រោយរបបនេះសុទ្ធតែទទួលស្គាល់ថា របបខ្មែរក្រហមជារបបសាហាវឃោរឃៅព្រោះបានសម្លាប់មនុស្សអស់ជិតពីរលាននាក់ ។ ទោះយ៉ាងណាក៏ដោយក៏នៅមានកម្មាភិបាលខ្មែរក្រហមមួយចំនួនតូចព្យាយាមធ្វើអំពើល្អដែរ ដោយចេះជួយអាសាអ្នកដទៃនៅពេលដែលអ្នកណាម្នាក់ប្រព្រឹត្តខុសអង្គការវិន័យ ។

វ៉ាន់ មានស្រុកកំណើតនៅភូមិស្រែខ្វាវ ឃុំជាំទង ស្រុកត្រាំកក់ ខេត្តតាកែវ មានឪពុកឈ្មោះ សៅ មី ម្តាយឈ្មោះ សុខ ពេន ។ វ៉ាន់ ជាកូនទី៧ ក្នុងចំណោមបងប្អូន៨នាក់ (ប្រុស៣និងស្រី៥) ។ ដោយសាររដ្ឋប្រហារនៅឆ្នាំ១៩៧០ វ៉ាន់ បានសម្រេចចិត្តឈប់រៀន ត្រឹមថ្នាក់ទី១១ (សង្គមចាស់) មកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ ។ នៅឆ្នាំ១៩៧១ វ៉ាន់ បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ខាងផ្នែកសិល្បៈ ។ ដោយសារតែកម្មាភិបាលថ្នាក់ស្រុកពេញចិត្តការងាររបស់គាត់ដែលធ្វើបានល្អ វ៉ាន់ ក៏ត្រូវបានតែងតាំងឲ្យទៅធ្វើជានិរសារប្រចាំមន្ទីរ២៥០ តំបន់១៣ ។ នៅឆ្នាំ១៩៧៣ អង្គការផ្លាស់ វ៉ាន់ ឲ្យធ្វើជាប្រធាននារីឃុំពពេល ដើម្បីពង្រឹងប្រជាជននៅតាមមូលដ្ឋានវិញ ។


សៅ វ៉ាន់

នៅឆ្នាំ១៩៧៥ រយៈពេលមួយខែក្រោយពីកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះ អង្គការបានផ្លាស់ វ៉ាន់ ឲ្យទៅធ្វើស្រែអំបិលនៅភូមិកំពង់កណ្តាល ខេត្តកំពតវិញ ដោយមានតួនាទីជាប្រធានអនុសេនាធំគ្រប់គ្រងកម្មករចំនួន៧០នាក់ ក្រោយមក១០០នាក់ ។ នៅទីនេះ ភូមិសាស្ត្រមានលក្ខណៈអំណោយផលណាស់ព្រោះមានផ្ទៃដីធំទូលាយ និងមានផ្ទះចំនួន៥ខ្នងសម្រាប់ឲ្យកម្មករស្នាក់នៅ ។ លើសពីនេះ វ៉ាន់ មិនដែលព្រួយបារម្ភថាខ្វះបាយនិងម្ហូបសម្រាប់ហូបទេ ។ ប៉ុន្តែ វ៉ាន់ បែរជាមិនដែលទទួលបានការអនុញ្ញាតឲ្យត្រឡប់មកលេងស្រុកកំណើតទាល់តែសោះ ។ ព្រោះតែបាត់ដំណឹង វ៉ាន់ យូរពេក នៅឆ្នាំ១៩៧៧ ម្តាយរបស់គាត់ក៏មកលេងគាត់ដល់កន្លែងធ្វើការតែម្តង ហើយថែមទាំងបានរៀបរាប់រឿងរ៉ាវទាំងអស់ដែលកើតឡើងនៅក្នុងភូមិថានៅតាមជនបទខ្មែរក្រហមបានសម្លាប់ប្រជាជនជាច្រើន ហើយផ្តល់អាហារឲ្យប្រជាជនហូបមិនគ្រប់គ្រាន់ទេ ។ ប៉ុន្តែ វ៉ាន់ មិនជឿពីព្រោះគាត់ឃើញកន្លែងគាត់មានម្ហូបអាហារហូបគ្រប់គ្រាន់ ។ ម៉្យាងទៀត អង្គការក៏បាននិយាយប្រាប់នៅក្នុងអង្គប្រជុំដែរថា «ឪពុកម្តាយយើងនៅតាមស្រុកស្រែចម្ការហូបចុកអាហារដូចយើងដែរ យើងមានជីវភាពស្មើៗគ្នា គ្មានវណ្ណៈនាយទុននិងសក្តិភូមិទេ មានតែវណ្ណៈកម្មករនិងកសិករប៉ុណ្ណោះ» ។

នៅទីនេះ វ៉ាន់ តែងតែអនុគ្រោះចំពោះកម្មករណាដែលឈឺធ្វើការមិនកើត ដូចជាស្ត្រីមានជំងឺធ្លាក់សមិនអាចចុះត្រាំក្នុងទឹកបាននិងមានជំងឺប្រចាំកាយមិនអាចធ្វើការធ្ងន់ គាត់បែងចែកការងារណាស្រាលៗឲ្យធ្វើជំនួសវិញ ដូចជា ដាំស្លក្នុងរោងបាយ បេះបន្លែ ដាំបន្លែ ចិញ្ចឹមមាន់ ឬចិញ្ចឹមជ្រូកសម្រាប់ទុកហូបក្នុងអង្គភាព ។ ពេលមានអង្គប្រជុំប្រចាំខែដែលមានសមាសភាពមកពីគ្រប់អង្គភាពស្រែអំបិលដើម្បីរាយការណ៍ជូនអង្គការថ្នាក់លើពីផលិតផលដែលធ្វើបានសម្រេចនិងប្រជុំស្វ័យទិតៀន វ៉ាន់ មិនដែលរាយការណ៍អាក្រក់ពីកម្មករទេ លើសពីនេះទៅទៀត គាត់ថែម

ទាំងជួយនិយាយរិះរកហេតុផលដើម្បីកុំឲ្យអង្គការយកទោសកំហុសទៀត ។ ជាក់ស្តែងពេលមិត្តនារីរាយការណ៍ថាបានឃើញខាងយុវជនមកនិយាយលេងជាមួយនារីៗ រួចចោទថាខុសសីលធម៌ និងខុសវិន័យរបស់អង្គការ វ៉ាន់ ក៏ជួយនិយាយឲ្យនារីនោះរួចខ្លួនទាំងអស់ ។ វ៉ាន់ រៀបរាប់ថា «ខ្ញុំជួយមនុស្សនៅអង្គភាពជាមួយគ្នាបានច្រើននាក់ណាស់ ដូចជាឈ្មោះ នី (ស្លាប់ឆ្នាំ២០០៦), លី សព្វថ្ងៃរស់នៅភូមិភ្នំព្រឹក និង ម៉ាច សព្វថ្ងៃរស់នៅប្រទេសអូស្ត្រាលីជាដើម» ។

នៅឆ្នាំ១៩៧៨ វ៉ាន់ បានជួយផ្តល់ម្ហូបអាហារដល់បុរស ៨នាក់ ដែលមានសហករណ៍នៅមិនឆ្ងាយប៉ុន្មានពីអង្គភាពស្រែអំបិល ។ ពេលនោះ វ៉ាន់ បររទេះជាមួយមេក្រុមម្នាក់ដែលទុកចិត្តគ្នាមកកាប់ស្លឹកត្នោតនៅអង្គភាពស្រែអំបិល រួចដើរទៅដល់កន្លែងបុរសទាំង៨នាក់នោះដែលកំពុងតែហូបបាយមួយកញ្ចប់តូច ។ ឃើញដូច្នេះ វ៉ាន់ ក៏ប្រាប់អ្នកទាំងនោះឲ្យទៅកន្លែងរោងបាយរបស់គាត់ដើម្បីហូបបាយ ព្រោះមានម្ហូបអាហារមិនខ្វះ ។ ក្រោយពីបុរសទាំងនោះយល់ព្រមទៅជាមួយ វ៉ាន់ ក៏បញ្ជាឲ្យចុងភៅរៀបចំបាយឲ្យហូប ហើយខ្ចប់ប្រហុក និងផ្អកយកទៅជាមួយទៀត ។ បុរសទាំងនោះបានអរគុណ វ៉ាន់ ហើយឆ្លើយប្រាប់ថា «មិនហ៊ានយកទៅទេ» តែ វ៉ាន់ បានប្រាប់វិញថា «បើមានអ្នកណាដឹងប្រាប់ថាកន្លែងគាត់ជាអ្នកឲ្យ» ។ វ៉ាន់ បានផ្តាំចុងភៅឲ្យរៀបបាយសម្រាប់អ្នកទាំង៨នាក់នេះរាល់ពេលដែលមកកាប់ស្លឹកត្នោត ទោះជាគាត់មិននៅក៏ដោយ ។ វ៉ាន់ រៀបរាប់ថា គាត់ព្យាយាមជួយអ្នកដទៃ គឺធ្វើតាមបណ្តាំឪពុកម្តាយដែលបានប្រាប់ថា «យើងធ្វើអំពើល្អ យើងនឹងបានល្អ» ។ ដូច្នេះ វ៉ាន់ មិនដែលគិតថាខ្លួនគាត់ត្រូវអ្នកដទៃស្អប់ទេ ។ ប៉ុន្តែ អ្វីដែល វ៉ាន់ បានគិតគឺខុសទាំងស្រុង ព្រោះនៅតែមានអ្នករាយការណ៍មិនល្អពីគាត់ដែរ ។ ដោយសារតែអំពើល្អរបស់គាត់ ទោះជាមានហេតុការណ៍ណាមួយកើតឡើងចំពោះគាត់ក៏ដោយ ក៏មានមិត្តនារីនៅក្នុងអង្គភាពជាមួយគ្នាតែងតែជួយនិយាយការពារគាត់ឲ្យរួចពីការចោទប្រកាន់ដែរ ។

ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ ប្រជាជនមួយចំនួន និងកម្មាភិបាលខ្មែរក្រហមស្ទើរតែទាំងអស់នាំគ្នារត់ទៅព្រំដែនថៃ ព្រោះខ្លាចកងទ័ពវៀតណាមចូលមកធ្វើបាប និងដោយសារតែបានឮពាក្យគេនិយាយតៗគ្នាថា ប្រសិនបើកងទ័ពវៀតណាមចាប់បាននឹងវះពោះច្រកស្មៅ ។ ហេតុនេះហើយ វ៉ាន់ មិនបានត្រឡប់មកស្រុកកំណើតវិញទេ ។ តាមផ្លូវធ្វើដំណើរ វ៉ាន់ បានឃើញមនុស្សស្លាប់ជាច្រើន ដោយសារតែគ្មានអាហារហូបនិងឈឺគ្រុនចាញ់ ។ ព្រោះតែអាណិតអ្នកទាំងនេះ វ៉ាន់ បានចែករំលែកអង្ករដែលគាត់បានដាក់ជាប់ខ្លួនឲ្យបន្តិចបន្តួចគ្រាន់នឹងហូប ។ មួយរយៈក្រោយមក វ៉ាន់ ក៏ដូចប្រជាជនទាំងនោះដែរ គឺចាប់ផ្តើមឈឺហើម ។ តែសំណាងល្អ ទាហានថៃបានមកដឹកគាត់យកទៅក្នុងយៃ្ត ប្រទេសថៃដើម្បីព្យាបាល ។ នៅទីនោះ អង្គការពិភពលោកបានជួយសង្គ្រោះ វ៉ាន់ ឲ្យមានជីវិត ថែមទាំងផ្តល់សិទ្ធិឲ្យគាត់ទៅបរទេសទៀត ។ ប៉ុន្តែកាលនោះ វ៉ាន់ គ្មានបំណងទៅក្រៅប្រទេសទេ ដូច្នេះគាត់ក៏សម្រេចចិត្តត្រឡប់ចូលដីខ្មែរវិញ ។ ក្នុងពេលធ្វើដំណើរ វ៉ាន់ បានជួយក្មេងប្រុសកំព្រាម្នាក់ឈ្មោះ ម៉ារិន អាយុប្រហែលជា ៧ឆ្នាំដែលបងប្រុសស្លាប់ដោយសារជំងឺគ្រុនចាញ់នៅស្រុកខ្មែរ ។ ឃើញដូច្នេះ វ៉ាន់ មានចិត្តអាណិតព្រោះ ម៉ារិន គ្មានទីពឹងត្រូវរស់នៅម្នាក់ឯង រួចក៏យកមកចិញ្ចឹម ។ រហូតដល់ឆ្នាំ២០០៦ ឪពុកម្តាយរបស់ ម៉ារិន ក៏បានមកយក ម៉ារិន ត្រឡប់ទៅវិញ ។ វ៉ាន់ យល់ព្រមប្រគល់ក្មេងនេះទៅឲ្យឪពុកម្តាយបង្កើតរបស់ ម៉ារិន វិញដែរ ។ សព្វថ្ងៃ ម៉ារិន រស់នៅគីឡូម៉ែត្រលេខ៦ ទល់មុខរោងចក្រផលិតស្រា *SKD* ប្រកបមុខរបររត់ម៉ូតូកង់បី ។ ក្រៅពី ម៉ារិន វ៉ាន់ ក៏នៅចិញ្ចឹមក្មេងស្រីម្នាក់ទៀតឈ្មោះ អូន ដែលមានស្រុកកំណើតជាមួយគាត់ដែរ ។ សព្វថ្ងៃនេះ អូន បានរៀបការរួចហើយនិងផ្លាស់ទៅរស់នៅស្រុកខ្មែរ ។ វ៉ាន់ រៀបរាប់ថា «អ្នកដែលគាត់ធ្លាប់ជួយនិងក្មេងដែលគាត់ធ្លាប់ចិញ្ចឹមនៅមានទំនាក់ទំនងជាមួយគ្នានៅឡើយទេ ជាពិសេស អូន រាប់អាន ម៉ារិន ដូចបងប្អូនបង្កើត ហើយបានឲ្យលុយ ម៉ារិន ធ្វើដើមរកស៊ីទៀតផង» ។ វ៉ាន់ បន្ថែមទៀតថា «ពេលជួយអ្នកដទៃគាត់មិនបានគិតថាអ្នកនោះជាអ្នកមូលដ្ឋានឬអ្នក១៧មេសាទេ ហើយក៏មិនចង់ទារសគុណមកវិញដែរ» ។

សព្វថ្ងៃសៅ វ៉ាន់ រស់នៅភូមិភ្នំព្រឹក ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង មានប្តីឈ្មោះ សារាយ ឈាន អាយុ៥៧ឆ្នាំ និងកូនប្រុស៤នាក់ ។ ដោយសារតែអំពើល្អរបស់គាត់ ទើបធ្វើឲ្យជីវភាពរស់នៅរបស់គាត់ធូរធារដូចគេដូចឯង ។ **សុខ ខណ្ណៈ**

# វេទិកាប្រជុំពិភាក្សាថ្នាក់ភូមិរំសាយការឈឺចាប់របស់ប្រជាជន

បន្ទាប់ពីបានចូលរួមក្នុងសវនាការជាសាធារណៈមួយស្តីពីការប្រកាសសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា លោក អ៊ុន សុខចាន់ ដែលជាសមាជិកក្រុមប្រឹក្សាឃុំគងនយ ខេត្តកណ្តាល បានស្ម័គ្រចិត្តឡើងរៀបរាប់ពីការសង្កេតរបស់គាត់ក្នុងសវនាការទៅកាន់សមាជិកក្នុងសហគមន៍ ។ នៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ក្រុមការងារឯកសាររស់នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយ សុខចាន់ សម្រេចបំណងប្រាថ្នានេះ ដោយរៀបចំឲ្យមានការប្រជុំពិភាក្សាថ្នាក់ភូមិមួយ ។ ការប្រជុំនេះមានការចូលរួមយ៉ាងកុះករពីសំណាក់អ្នកភូមិចំនួន៩១នាក់ មកពីភូមិចំនួន៨នៅទូទាំងឃុំ ។ ក្នុងនោះយើងសង្កេតឃើញមានការចូលរួមយ៉ាងច្រើនពីស្ត្រី រហូតទៅដល់៣៧នាក់ ។

ការពិភាក្សានេះប្រព្រឹត្តទៅនៅវេលាម៉ោង២រសៀលដោយមានការណែនាំពីក្រុមការងាររបស់គម្រោង ។ ក្រុមការងារគម្រោងឯកសាររស់បានណែនាំពីគម្រោងឯកសាររស់ និងគោលបំណងដែលបង្កើតឲ្យមានវេទិកាប្រជុំពិភាក្សានេះ ។ បន្ទាប់មកក្រុមការងារបានបន្តរៀបរាប់ពីកម្មវិធីប្រជុំ និងប្រគល់នាទីទៅកាន់អ្នកតំណាងភូមិដែលបានចូលរួមក្នុងសវនាការរៀបរាប់ពីការយល់ដឹងរបស់គាត់ចំពោះតុលាការ ។

ដំបូង សុខចាន់ បានស្វាគមន៍អ្នកទាំងអស់ដែលបានចូលរួមក្នុងកម្មវិធីប្រជុំ ។ បន្ទាប់មក សុខចាន់ បានពន្យល់អំពីភាពពិតប្រាកដនិងដំណើរការរបស់សាលាក្តីខ្មែរក្រហម ។ ក្រោយមកគាត់ពន្យល់ពីមូលហេតុដែលនាំទៅដល់ការយឺតយ៉ាវរបស់សវនាការដោយគូសបញ្ជាក់ថា ភ័ស្តុតាងនិងសាក្សីគួរតែមានគ្រប់គ្រាន់មុនពេលដែលតុលាការសម្រេចក្នុងការបើកសវនាការជាសាធារណៈ ។ បន្ថែមពីលើនោះទៀត គាត់បានបង្ហាញពីសុទិដ្ឋិនិយមរបស់គាត់អំពីតុលាការនេះថា គាត់ជឿជាក់ថាសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងមានរូបរាងពិតប្រាកដនៅក្នុងអនាគតដ៏ខ្លីខាងមុខក្រោយពីគាត់បានទទួលព័ត៌មានតាមរយៈវិទ្យុនិងប្រភពផ្សេងៗទៀត ។ ចុងក្រោយ គាត់នាំមកឲ្យសហគមន៍របស់គាត់ គាត់សំណូមពរទៅតុលាការឲ្យដំណើរការឆាប់រហ័សដើម្បីកុំឲ្យមានការខ្ជះខ្ជាយប្រាក់កាសដែលអាចប្រើប្រាស់សម្រាប់ប្រយោជន៍រួមផ្សេងៗទៀតដូចជាការកសាងសំណង់ស្ពានថ្នល់ជាដើម ។

បន្ទាប់ពីមតិលោក សុខចាន់ បញ្ចប់ទៅ លោក ចៅ ជឹម ដែលជាប្រធានភូមិគងនយបានឆ្លៀតយកឱកាសនេះរៀបរាប់បន្ថែមអំពីទិដ្ឋភាពនៅក្នុងសាលសវនាការ ។ គាត់ជឿជាក់ថា ដំណើរការនៃសវនាការនេះមានភាពពិតប្រាកដជាក់លាក់ បើទោះបីជាគាត់ឃើញមុខ ឌុច លើផ្ទាំងសំពត់សនៅសាលសវនាការធំ រីឯសវនាការពិតប្រាកដប្រព្រឹត្តទៅនៅក្នុងបន្ទប់តូចដែលអាចទទួលបានទស្សនិកជនតែមួយចំនួនប៉ុណ្ណោះក៏ដោយ ។ បន្ថែមពីលើទិដ្ឋភាពនៅក្នុងបន្ទប់សវនាការ នៅពេលដែលគេសួរគាត់ថាតើមានអ្វីទៀតដែលគាត់បានឃើញ? គាត់ឆ្លើយតបមកយើងវិញដោយខ្លីអំពីខ្សែភាពយន្តឯកសារ «នៅពីក្រោយជញ្ជាំងស-២១» ដែលបានបញ្ចាំងនៅមជ្ឈមណ្ឌលឯកសារ ។

បន្ថែមពីលើការរៀបរាប់ដោយសង្ខេបរបស់អ្នកតំណាងសហគមន៍ ក្រុមការងារគម្រោងឯកសាររស់បានសង្ខេបដោយខ្លីពីចំណុចសំខាន់ៗដែលបានលើកឡើងនៅក្នុងសវនាការដែលប្រព្រឹត្តទៅនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ ទៅកាន់អ្នកចូលរួមទាំងអស់ដែលអាចឲ្យពួកគាត់អាចយល់បន្ថែមទៀតពីប្រធានបទដែលបានលើកឡើងរួចមកហើយ ។ យើងគួរកត់សម្គាល់ថា អ្នកចូលរួមក្នុងសវនាការទាំងអស់មិនអាចចងចាំគ្រប់ពាក្យពេចន៍ដែលបានប្រើនៅក្នុងសេចក្តីសម្រេចរបស់ចៅក្រមទេ បើពិនិត្យទៅលើភាពស្មុគស្មាញនៃពាក្យពេចន៍ច្បាប់ដែលត្រូវប្រើប្រាស់នៅក្នុងសវនាការ ។ ប្រការសំខាន់គឺថាអ្នកដែលបានចូលរួមបានផ្ញើសារសំខាន់ទៅកាន់អ្នកភូមិរបស់គាត់ដោយសង្កត់ធ្ងន់ទៅលើភាពពិតប្រាកដនៃដំណើរការរបស់តុលាការ ។

ក្រុមការងារឯកសាររស់កត់សម្គាល់ឃើញមូលហេតុសំខាន់បួនដែលនាំឲ្យតុលាការបដិសេធបណ្តឹងឧទ្ធរណ៍សុំឲ្យមានការដោះលែង ឌុច ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ដែលមានដូចជាសុវត្ថិភាពរបស់ជនចុងចោទ ភាពជឿជាក់ដែលថាជនចុងចោទអាចរត់គេច

ខ្លួនទៅក្រៅប្រទេស បំផ្លាញភស្តុតាងឬគំរាមកំហែងដល់សាក្សីសំខាន់ៗ រក្សាសន្តិសុខសាធារណៈ ព្រមទាំងរក្សាឲ្យមានវត្តមានរបស់ជនចុងចោទក្នុងតុលាការពេលដែលមានការចាំបាច់ ។

មួយម៉ោងក្រោយពីការចាប់អារម្មណ៍របស់អ្នកចូលរួមក្នុងសវនាការ វេទិកាពិភាក្សានេះត្រូវបានផ្តល់ទៅឲ្យអ្នកមានវត្តមាននៅក្នុងការប្រជុំដើម្បីចោទឆ្លើយនិងមានយោបល់ចំពោះតុលាការខ្មែរក្រហម ។ នៅពេលដែលសួរថាតើអ្នកចូលរួមទាំងអស់ធ្លាប់បានឮអំពីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលត្រូវបានចាប់ខ្លួននិងកំពុងរង់ចាំការកាត់ទោសដោយមានអ្នកចូលរួមមួយចំនួនធ្លាប់ឮពីដំណឹងនេះតាមវិទ្យុ ប៉ុន្តែពួកគាត់មិនបានយកចិត្តទុកដាក់ទៅនឹងព័ត៌មានបែបនេះទេ ហេតុនេះទើបគាត់មិនអាចដឹងថាតើមេដឹកនាំទាំងនោះជាអ្នកណា? កង ភិរម្យ មកពីភូមិគងនយមានយោបល់ថា តុលាការគួរតែបង្កើតកម្មវិធីនៅតាមវិទ្យុនិងទូរទស្សន៍ដើម្បីជម្រាបព័ត៌មានទៅកាន់ប្រជាជនតាមទីជនបទអំពីការវិវត្តរបស់សាលាក្តី ។ គាត់សំណូមពរឲ្យមានកម្មវិធីផ្សាយផ្ទាល់តាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកដើម្បីទាញការចាប់អារម្មណ៍របស់ប្រជាជនទាក់ទងទៅនឹងតុលាការខ្មែរក្រហម ។ គាត់មានយោបល់ថា សមិទ្ធផលដែលបានថតចម្លងចេញពីព្រឹត្តិការណ៍ផ្សេងៗរបស់តុលាការដូចជាដំណើរការនៃសវនាការគួរតែយកទៅបញ្ចាំងឲ្យអ្នកភូមិទស្សនាតាមរយៈការប្រជុំផ្សេងៗ ។ គាត់បន្ថែមថា ការបញ្ចាំងបែបនេះនឹងជួយបំផុសឲ្យមានការពិភាក្សា ។

ស្ត្រីម្នាក់មកពីភូមិសេរីសម្បត្តិ ហើយដែលបានបាត់បង់ឪពុកម្តាយនិងសមាជិកគ្រួសារផ្សេងៗទៀតនៅក្នុងរបបខ្មែរក្រហម មានចម្ងល់ថាតើរហូតដល់ពេលណាទើប ឌុច នឹងត្រូវកាត់ឲ្យជាប់ពន្ធនាគារ ។ ដូចជាជនរងគ្រោះជាច្រើនលាននាក់ទៀតដែលគាត់មិនមានអាហារគ្រប់គ្រាន់ដើម្បីទទួលទាន ហើយត្រូវបង្ខំចិត្តបរិភោគស្លឹកឈើជំនួសឲ្យបាយដើម្បីរស់ ។ ទោះជាក្រោយមករយៈពេល ៣០ឆ្នាំហើយក៏ដោយ ក៏គាត់នៅតែមានកំហឹងចំពោះខ្មែរក្រហមដែលបានប្រព្រឹត្តអំពើសាហាវឃោរឃៅចំពោះគ្រួសារគាត់ ។ គាត់នៅតែមានកំហឹងពេលដែលរំឭកពីបទពិសោធន៍ពីអតីតកាលរបស់គាត់ ។ ទោះជាយ៉ាងនេះក៏ដោយ គាត់មានចិត្តសប្បាយរីករាយណាស់ចំពោះដំណឹងស្តីពីសាលាក្តីខ្មែរក្រហម ។

អ្នកចូលរួមខ្លះទៀតមានចម្ងល់ថាតើ ឌុច មានប្រតិកម្មដូចម្តេចខ្លះចំពោះតុលាការ បន្ទាប់ពីចៅក្រមអានសេចក្តីសម្រេចនេះ ។ ហង់ ហួន មកពីភូមិត្រពាំងសំរិទ្ធចង់ដឹងថាតើ ឌុច មាននិយាយអ្វីទៅកាន់ចៅក្រមដែរទេ ។ សុខចាន់ បានឆ្លើយតបទៅវិញថា គាត់មិនបានឮ ឌុច និយាយអ្វីដោយផ្ទាល់ទេ ប៉ុន្តែមេធាវីរបស់ ឌុច សម្តែងការមិនពេញចិត្តចំពោះសេចក្តីសម្រេចនេះ ហើយគាត់បានទទូចសុំឲ្យមានសាក្សីនិងភស្តុតាងដែលអាចប្រើប្រាស់នៅតុលាការដើម្បីពិចារណាបន្តទៅទៀត ។

ការពិភាក្សានេះបង្កើតឲ្យមានការរៀបរាប់ពីរឿងរ៉ាវផ្ទាល់ខ្លួនពីអ្នកចូលរួមជាច្រើនទៀត ។ សឿង ខាន់ នៅភូមិគងនយដែលត្រូវបានជម្លៀសចេញពីខេត្តពោធិ៍សាត់ ហើយបាត់បង់សមាជិកគ្រួសារគាត់នៅក្នុងរបបខ្មែរក្រហមបានរំឭកអំពីបទពិសោធន៍គាត់ទាំងទឹកភ្នែកថា ដូចជនរងគ្រោះដទៃទៀតដែលរស់នៅក្នុងក្រុមតែមួយ គាត់ត្រូវបានបង្ខំឲ្យជីកប្រឡាយ វែកដីដែលធ្វើឲ្យគាត់ភ្លាត់ឆ្អឹងខ្នងរហូតមកដល់សព្វថ្ងៃ ។ គាត់បន្ទោសទៅលើខ្មែរក្រហមដែលធ្វើឲ្យគាត់មានជីវភាពក្រីក្ររហូតមកដល់សព្វថ្ងៃ ។

ខន សុខន មិនមានការអាណិតអាសូរចំពោះមេដឹកនាំខ្មែរក្រហមទេ ។ ដូចអ្នកភូមិផ្សេងៗទៀតដែរ សុខន គ្មានអាហារហូបចុកគ្រប់គ្រាន់ដែលធ្វើឲ្យរូបរាងគាត់ហើម ។ ខ្មែរក្រហមបង្ខំគាត់ឲ្យធ្វើស្រែ ទោះជាគាត់កំពុងមានផ្ទៃពោះក៏ដោយ ។ អ្វីដែលអាក្រក់ជាងនោះទៅទៀតគឺប្តីរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់នៅពេលដែលគាត់ទើបតែមានផ្ទៃពោះបាន៣ខែ ។ ការឈឺចាប់ផ្នែកផ្លូវកាយនិងផ្លូវចិត្តបន្សល់ទុកមកដល់សព្វថ្ងៃធ្វើគាត់មានការលំបាកក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតនៅពេលបច្ចុប្បន្ន ។ ជាចុងក្រោយគាត់សំណូមពរឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ខ្លួននិងកាត់ទោសមេដឹកនាំខ្មែរក្រហមសំខាន់ៗឲ្យទាន់ពេលវេលាដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជារងគ្រោះទាំងអស់ ។

ជាទូទៅ អ្នកចូលរួមភាគច្រើនចង់ឃើញអ្នកដែលទទួលខុសត្រូវចំពោះអំពើសាហាវឃោរឃៅនៅក្នុងរបបខ្មែរក្រហមត្រូវគេចាប់ខ្លួននិងកាត់ទោសនៅចំពោះមុខតុលាការ ហើយសំណូមពរថាសាលាក្តីនេះនឹងប្រព្រឹត្តទៅយ៉ាងលឿន ហើយបញ្ចប់ទៅក្នុងរយៈពេលខ្លី ដែលមិនធ្វើឲ្យមេដឹកនាំទាំងនោះស្លាប់មុនពេលមិនទាន់ស្វែងរកយុត្តិធម៌ឃើញនិងធ្វើឲ្យការឈឺចាប់ក្នុងចិត្តរបស់ប្រជាជនកម្ពុជាបានរសាយ ។ **ស៊ីវ សាទីណា**

# សវនាការអង្គបុរេជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨

អង្គបុរេជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់ពេលបើកសវនាការជាសាធារណៈលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចចំពោះសំណើសុំបដិសេធសម្រាប់ការបកប្រែសំណុំរឿងលើករណីរបស់លោក ខៀវ សំផន ។ អង្គបុរេជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យមានការផ្សាយបន្តផ្ទាល់នូវដំណើរការជំនុំជម្រះក្តី ដោយអនុញ្ញាតឲ្យស្ថានីយវិទ្យុ និងទូរទស្សន៍ផ្សព្វផ្សាយជាសាធារណៈ ។ អ្នកតំណាងប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនត្រូវបានអញ្ជើញឲ្យចូលរួមដោយផ្ទាល់ ។

***សូមចំណាំថា:*** *AV ភ្ជាប់ជាមួយប្រព័ន្ធផ្សព្វផ្សាយដោយប្រើ BNC សម្រាប់វីដេអូ និង XLR សម្រាប់សំឡេង ។*

ដំណើរការជំនុំជម្រះក្តីនឹងចាប់ផ្តើមនៅម៉ោង៩ព្រឹក ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ ។ ប្រជាជនទាំងអស់ត្រូវទៅដល់កន្លែងអង្គុយដែលអង្គជុំជម្រះរៀបចំឲ្យបានរយៈពេល៣០នាទី មុនពេលបើកសវនាការជំនុំជម្រះក្តី ។ ប្រជាជនគួរតែទៅដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងចន្លោះពីម៉ោង៨ ដល់ម៉ោង៨និង៣០នាទីព្រឹក ដើម្បីទុករយៈពេលឲ្យបានគ្រប់គ្រាន់សម្រាប់ការបែកសំបុត្រនិងត្រួតពិនិត្យសុវត្ថិភាព ។ ទ្វារនឹងបិទត្រឹមម៉ោង៩ព្រឹក ឬនៅពេលដែលកៅអីអង្គុយទាំងអស់នៅក្នុងអគារសវនាការមានមនុស្សពេញ ។ ប្រជាជនទាំងអស់ដែលក្រុមសន្តិសុខអនុញ្ញាតឲ្យចូលទៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបង្ហាញអត្តសញ្ញាណឲ្យបានច្បាស់លាស់រួមទាំងរូបថតមួយសន្លឹកផងដែរ និងត្រូវដើរឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាព ។ សូមចំណាំថា មនុស្សក្រោមអាយុ១៨ឆ្នាំ ទូរស័ព្ទដៃ កាបូបធំ អាហារឬក៏ភេសជ្ជៈមិនអនុញ្ញាតឲ្យមាននៅក្នុងសាលសវនាការទេ ។

***កន្លែងអង្គុយនៅក្នុងបន្ទប់សវនាការត្រូវបានរៀបចំដូចខាងក្រោម:***

អ្នកយកព័ត៌មាន : តម្រូវឲ្យមានការចុះឈ្មោះមុនថ្ងៃផុតកំណត់គឺថ្ងៃអង្គារ ទី២ ខែធ្នូ វេលាម៉ោង៥រសៀល ។ ប្រសិនបើជាកន្លែងអង្គុយទាំងនេះមិនមានអ្នកអង្គុយពេញត្រឹមម៉ោង១០ព្រឹក នៅថ្ងៃបើកសវនាការទេ អង្គជំនុំជម្រះនឹងផ្តល់កន្លែងទាំងនោះទៅដល់សាធារណជនទូទៅ ។ សម្រាប់ព័ត៌មានលម្អិតក្នុងការចូលរួមក្នុងសវនាការសូមទាក់ទង: លោក ម៉ៅ វុត្ថា តាមរយៈទូរស័ព្ទលេខ ០២៣ ២១៩ ៨១៤ រួចភ្ជាប់ទៅលេខ ៦១៦៦ ឬក៏ទូរស័ព្ទដៃលេខ ០១១ ៣៦៤ ៤៤៤ ឬ ០៩២ ៨២៨ ២៨៣ ឬតាមរយៈអ៊ីមែល: mao.vutha@eccc.gov.kh ។



**អ្នកភូមិឈរមើលការតាំងពិព័រណ៍រូបថតនៅខេត្តបាត់ដំបង**

***សម្រាប់អ្នកតំណាងអង្គការក្រៅរដ្ឋាភិបាលៈ*** មានកន្លែងអង្គុយចំនួន៥០កៅអីដែលផ្តល់ឲ្យសម្រាប់អ្នកតំណាងអង្គការក្រៅរដ្ឋាភិបាលថ្នាក់ជាតិ និងអន្តរជាតិ (ច្រើនបំផុត២នាក់ ក្នុង១អង្គការ) ។ តម្រូវឲ្យចុះឈ្មោះមុនថ្ងៃផុតកំណត់គឺថ្ងៃអង្គារ ទី២ ខែធ្នូ វេលាម៉ោង៥រសៀល ។ បើសិនជាកន្លែងអង្គុយទាំងនេះមិនមានអ្នកអង្គុយពេញត្រឹមម៉ោង៩ព្រឹកនៅថ្ងៃបើកសវនាការ អង្គជំនុំជម្រះនឹងផ្តល់កន្លែងទាំងនោះទៅដល់សាធារណជនទូទៅ ។

***ក្រុមៈ*** កន្លែងអង្គុយមានចំនួន១៤០កៅអីបានផ្តល់ឲ្យសម្រាប់ក្រុម (ច្រើនបំផុត២០នាក់ ក្នុង១ក្រុម) ។ តម្រូវឲ្យចុះឈ្មោះមុនថ្ងៃផុតកំណត់គឺថ្ងៃអង្គារ ទី២ ខែធ្នូ វេលាម៉ោង៥រសៀល ។ បើសិនជាកន្លែងអង្គុយទាំងនេះមិនមានអ្នកអង្គុយពេញត្រឹមម៉ោង៩ព្រឹកនៅថ្ងៃបើកសវនាការ អង្គជំនុំជម្រះនឹងផ្តល់កន្លែងទាំងនោះទៅដល់សាធារណជនទូទៅ ។



សាធារណជនទូទៅត្រូវបានលើកទឹកចិត្តឲ្យចុះឈ្មោះចូលរួមជាមុន ហើយនឹងអាចអង្គុយតាមលំដាប់នៃអ្នកមកមុនអង្គុយនៅជួរមុនខាងមុខ ។ កន្លែងអង្គុយមានចំនួន១០០កៅអីត្រូវបានបម្រុងទុក ។ ការអនុញ្ញាតឲ្យចូលរួមនឹងផ្តល់ឲ្យសម្រាប់តែអ្នកដែលបានផ្តល់ឈ្មោះមកអង្គជំនុំជម្រះមុន ។ តម្រូវឲ្យចុះឈ្មោះមុន ប្រសិនបើអ្នកចង់ជិះរថយន្តក្រុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយមិនគិតថ្លៃ ។

***មធ្យោបាយធ្វើដំណើរៈ*** អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងផ្តល់ជូននូវការជិះរថយន្តក្រុងដោយមិនគិតថ្លៃសម្រាប់អ្នកព័ត៌មាននិងសាធារណជនដែលមិនមានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនពីទីក្រុងភ្នំពេញទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការត្រឡប់មកវិញ ។ រថយន្តក្រុងនឹងចាកចេញពីមុខមជ្ឈមណ្ឌលផ្តល់ព័ត៌មាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅម៉ោង៧ និង១៥នាទីព្រឹក និងចាកចេញពីស្ថានីយរថភ្លើងភ្នំពេញនៅម៉ោង៧និង៣០នាទីព្រឹក ហើយតម្រូវឲ្យចុះឈ្មោះមុន ។ ដើម្បីចុះឈ្មោះសុំកន្លែងអង្គុយនិងការធ្វើដំណើរ សូមទាក់ទងលោក ជិន ហែមវិចិត្រ តាមរយៈទូរស័ព្ទលេខ ០២៣ ២១៩ ៨១៤ រួចហៅបន្តទៅលេខ ៦០៦៥ ឬលេខ ០១២ ៦៩៦ ២២០ ទូរសារៈ ០២៣ ២១៩ ៨៤១ អ៊ីមែលៈ info@eccc.gov.kh ។

អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាមានទីតាំងស្ថិតនៅក្នុងសង្កាត់ចោមចៅ ចម្ងាយពីទីក្រុងភ្នំពេញ១៦គីឡូម៉ែត្រ នៅខាងឆ្វេងដៃនៃផ្លូវជាតិលេខ៤ ។ សម្រាប់សាធារណជន និងអ្នកសារព័ត៌មានសូមចូលពីខ្លោងទ្វារសម្រាប់ភ្ញៀវដែលស្ថិតនៅចុងខាងកើតនៃបរិវេណអគារ ។

***សេវាកម្មៈ*** ទឹកសម្រាប់ផឹកនឹងផ្តល់ឲ្យនៅសាលធំខាងក្រៅបន្ទប់សវនាការ ។ មិនអនុញ្ញាតឲ្យមានអាហារឬភេសជ្ជៈនៅក្នុងបន្ទប់សវនាការទេ ។ បន្ទប់ទឹកត្រូវបានផ្តល់ឲ្យនៅក្នុងអគារតុលាការ និងកន្លែងចតរថយន្ត ។ កន្លែងចតរថយន្តនឹងផ្តល់ឲ្យសម្រាប់ភ្ញៀវដែលមកកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាមួយនឹងរថយន្តក្រុង ឬរថយន្តផ្ទាល់ខ្លួនរបស់គេ ។ កិច្ចការសង្គ្រោះនឹងផ្តល់ឲ្យសម្រាប់ជនពិការរួមជាមួយរទេះកង់ ។

# សវនាការថ្ងៃទី៤ ខែធ្នូ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាៈ តើនិយាយអំពីអ្វី?

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់ថ្ងៃបើកសវនាការជាសាធារណៈលើ «បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធការបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់ លោក ខៀវ សំផន» ដែលនឹងប្រារព្ធធ្វើនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ នៅវេលាម៉ោង ៩ព្រឹក ។

តាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ២០០៧ ដែលស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបអង្កេតរបស់ខ្លួនទៅលើជនសង្ស័យ៥រូប ដែលក្នុងនោះមាន ខៀវ សំផន មួយរូបដែរ ហើយនិងស្នើសុំឲ្យចាប់ខ្លួន និងឃុំខ្លួនផង ។ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកានាំខ្លួន ខៀវ សំផន យកមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។


ខៀវ សំផន

តាមអំណាចនៃដីកានាំខ្លួននេះ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ អាជ្ញាធរកម្ពុជាសហការជាមួយសន្តិសុខរបស់អង្គជំនុំជម្រះបាននាំខ្លួន ខៀវ សំផន មកកាន់អង្គជំនុំជម្រះវិសាមញ្ញ ។ ជាផ្លូវការនៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតបានចេញដីកាចោទប្រកាន់ ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមដែលប្រព្រឹត្តឡើងក្នុងកំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យរវាងថ្ងៃទី១៧ មេសា ១៩៧៥ និងថ្ងៃទី៦ មករា ១៩៧៩ ។ បន្ថែមលើនេះទៀត សហចៅក្រមស៊ើបអង្កេតបានសម្រេចចេញដីកាមួយទៀត គឺដីកាឃុំខ្លួន ខៀវ សំផន បណ្តោះអាសន្ន ហើយ ខៀវ សំផន ត្រូវបាន

នាំយកទៅឃុំខ្លួនបណ្តោះអាសន្ននៅក្នុងមជ្ឈមណ្ឌលឃុំឃាំងបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ការឃុំខ្លួនបែបនេះត្រូវបានសហចៅក្រមស៊ើបអង្កេតយល់ឃើញថាគឺជាវិធានការចាំបាច់ដោយអនុលោមតាមវិធាន ៦៣(៣)(ខ) ។

ភ្លាមៗដែរ ការិយាល័យគាំពារការពារក្តីបានចាត់តាំងមេធាវីពីររូប គឺលោក សាយ បូរី ជនជាតិខ្មែរ និងលោក ហ្សាក់ វែហ្សេស ជនជាតិបារាំង ដើម្បីការពារ ខៀវ សំផន នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ បន្ទាប់ពីមានការស្បថស្បែចូលកាន់តំណែងជាមេធាវីការពារក្តីរួចរាល់គឺនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧ សហមេធាវីរបស់ខៀវ សំផន បានជូនដំណឹងថា ខ្លួននឹងធ្វើការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្នប្រឆាំងនឹងកូនក្តីរបស់ខ្លួន ហើយនៅថ្ងៃទី២១ ខែឆ្នាំដដែល សហមេធាវីបានដាក់ពាក្យបណ្តឹងជាផ្លូវការជូនអង្គបុរេជំនុំជម្រះ ។

បើយោងតាមរបាយការណ៍របស់ចៅក្រម សហមេធាវីរបស់ ខៀវ សំផន នៅក្នុងពាក្យបណ្តឹងរបស់ខ្លួន គឺពុំបានឲ្យហេតុផលលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលថាការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ដោយអនុលោមតាមវិធាន ៦៣(៣)(ខ) នោះទេ ។

ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានឆ្លើយតបនឹងបណ្តឹងរបស់សហមេធាវី ខៀវ សំផន ដោយស្នើសុំឲ្យច្រានចោលនូវបណ្តឹងឧទ្ធរណ៍ទាំងមូល ហើយរក្សាការឃុំខ្លួនឲ្យនៅស្ថានភាពដដែល ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំដដែល មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ជូនការឆ្លើយតបរួមគ្នា ហើយស្នើថា បណ្តឹងឧទ្ធរណ៍របស់មេធាវី ខៀវ សំផន គួរត្រូវបដិសេធចោល ហើយខ្លួនគាំទ្រជំហររបស់សហព្រះរាជអាជ្ញា ។

ចំណុចសំខាន់និងគួរឲ្យចាប់អារម្មណ៍ ហើយដែលទាក់ទងនឹងប្រធានបទសវនាការថ្ងៃទី៤ ខែធ្នូ ខាងមុខនេះ (បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធការបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់ ខៀវ សំផន) គឺថា កន្លងមកសហមេធាវីរបស់ ខៀវ សំផន ស្នើសុំឲ្យមានការចាត់តាំង«អ្នកជំនាញបរទេសដែលមានការទទួលស្គាល់ច្បាស់លាស់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងឯករាជ្យ» ដើម្បីធ្វើការ «ផ្ទៀងផ្ទាត់» និងពិនិត្យ«នីត្យានុកូលភាព» លើឯកសារដែលប្រើប្រាស់សម្រាប់ធ្វើការចោទប្រកាន់មកលើកូនក្តីរបស់ខ្លួន ។

ឆ្លើយតបនឹងការស្នើបែបនេះ សហព្រះរាជអាជ្ញាឲ្យហេតុផលថា ការស្នើសុំបែបនេះ «ពុំបានបញ្ជាក់យ៉ាងច្បាស់លាស់លើឯកសារឬសេចក្តីថ្លែងការណ៍ណាមួយដែលមិនបានផ្ទៀងផ្ទាត់», ដោយបន្ថែមថា មេធាវី ខៀវ សំផន «ពុំបានឲ្យហេតុផលដើម្បីគាំទ្រលើចំណុចវិវាទនេះ ហើយក៏ពុំបានបញ្ជាក់ថា ការវិភាគបែបណាដែលនឹងត្រូវធ្វើឡើង»ដែរ ។ ចំណែកពាក្យថា «នីត្យានុកូលភាព» គឺសហមេធាវីចង់សំដៅថា «ភាពអាចទទួលយកបាន ភាពអាចជាប់ពាក់ព័ន្ធនិងទម្ងន់នៃភស្តុតាង» ដែលបញ្ហាទាំងនេះត្រូវសម្រេចដោយចៅក្រមនៃអង្គជំនុំជម្រះឯណោះទេ ។

នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ចៅក្រមទាំង៥រូបនៅអង្គបុរេជំនុំជម្រះ បានសម្រេចបើកសវនាការជាសាធារណៈលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដែលចេញដោយសហចៅក្រមស៊ើបអង្កេត ។ តើហេតុការណ៍បានកើតឡើងយ៉ាងដូម្តេច? ហើយហេតុអ្វីទើបមានសវនាការថ្ងៃទី៤ ខែធ្នូ ខាងមុខនេះ?

នៅក្នុងសវនាការជាសម្ងាត់ដែលជាផ្នែកមួយនៃសវនាការថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៧ ជនជាប់ចោទ (ខៀវ សំផន) បានស្នើសុំឲ្យផ្អាកនីតិវិធីទាំងស្រុង ដោយលើកយកហេតុផលថាមេធាវីបរទេសរបសគាត់បានបដិសេធលែងបន្តតំណាងឲ្យរូបគាត់តទៅទៀតហើយ ដោយហេតុថាឯកសារទាំងអស់នៅក្នុងសំណុំរឿងពុំអាចមានជាភាសាបារាំង (មេធាវីបរទេសរបស់ ខៀវ សំផន ជាជនជាតិបារាំង) ។ ដូច្នេះ ខៀវ សំផន បានបាត់បង់នូវមេធាវីតំណាងឲ្យខ្លួនម្នាក់ដែលធ្វើឲ្យគាត់យល់ថា គាត់ពុំមានការជឿជាក់លើខ្លួនឯងក្នុងពេលសវនាការ ។

ភ្លាមៗនោះដែរ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់អនុញ្ញាតឲ្យដាក់ពាក្យបណ្តឹងហើយសវនាការនោះផ្អាកតែម្តង ។ ប្រធានចៅក្រមបានប្រកាសទៀតថា សេចក្តីសម្រេចដែលមានហេតុផលពេញលេញជាលាយលក្ខណ៍អក្សរ នឹងផ្តល់ជូនភ្លាមបន្ទាប់ពីការផ្អាកសវនាការ ។

ជុំវិញហេតុការណ៍នេះ មេធាវីជនជាតិបារាំងរបស់ ខៀវ សំផន លើកឡើងថា គាត់មានបំណងស្ថិតនៅស្ងៀមមិននិយាយពេញមួយអំឡុងពេលនៃនីតិវិធី ដោយឈរលើហេតុផលថា ឯកសារទាំងអស់នៅក្នុងសំណុំរឿងពុំអាចមានជាភាសាបារាំង ដែលភាសានេះជាភាសាផ្លូវការមួយក្នុងចំណោមភាសាផ្លូវការពីរផ្សេងទៀតគឺភាសាខ្មែរ និងអង់គ្លេស ។

ចំណែកឯអង្គបុរេជំនុំជម្រះកត់សម្គាល់ថា ឯកសារដាក់ជូនទាំងអម្បាលមានដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍មានជាភាសាខ្មែរ អង់គ្លេស និងបារាំង ។ ការជូនដំណឹង (របស់មេធាវីការពារក្តី) អំពីការលំបាកនានានៅក្នុងនីតិវិធីដែលអនុញ្ញាតឲ្យកំឡុងពេលដាក់សារណា និងឯកសារផ្សេងៗក៏គ្មាន ការស្នើសុំរកការចង់ផ្អាកមុនពេលបើកសវនាការក៏គ្មាន ព្រមទាំងថាការបដិសេធរបស់មេធាវីបរទេសបែបហ្នឹងធ្វើឲ្យប៉ះពាល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ ។

លើសពីនេះទៀត អង្គបុរេជំនុំជម្រះបានរកឃើញថាអំពើរបស់មេធាវីបរទេសនៅពេលសវនាការបាននាំដល់ការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទ ជាពិសេសសិទ្ធិទទួលបានការកាត់ទោសទាន់ពេលវេលា និងសិទ្ធិមានមេធាវីតាមជម្រើសរបស់ជនជាប់ចោទ ។ ជាលទ្ធផល អង្គបុរេជំនុំជម្រះបានចេញការព្រមានមួយទៀតចំពោះមេធាវីបរទេសជនជាតិបារាំងដែលតំណាងឲ្យ ខៀវ សំផន នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ។

ជាបន្តមកទៀត ខ្ញុំបាទដាក់ជាសំណួរដើម្បីទាញការយកចិត្តទុកដាក់លើសវនាការថ្ងៃទី៤ ខែធ្នូខាងមុខនេះ ហើយម្យ៉ាងទៀតក៏ជាការងាយស្រួលតាមដាននិងយល់ចំពោះសវនាការដែរ ។ សំណួរពាក់ព័ន្ធនឹងបញ្ហាចោទឡើងអំពីការបកប្រែឯកសារទាំងអស់នៅក្នុងសំណុំរឿងព្រហ្មទណ្ឌប្រឆាំងនឹង ខៀវ សំផន ដែលមេធាវី ហ្សាក់ វែហ្សេស លើកឡើងនៅក្នុងសវនាការថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ។ សំណួរចោទសួរថា តើចៅក្រមទាំង៥រូបនៃអង្គបុរេជំនុំជម្រះនឹងសម្រេចបែបណា ទាក់ទិនបញ្ហាបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់ ខៀវ សំផន?

ជាការបន្ថែម ខ្ញុំបាទសូមលើកអំពីការជំនួសមេធាវីកម្ពុជាពីលោក សាយ បូរី ទៅលោក ស សូវ៉ាន បន្តិចសម្រាប់ជាជំនួយដល់ការងាយតាមដាន ។ បន្ទាប់ពីទទួលបានការជូនដំណឹងអំពីការសុំលាលែងពីតំណែងជាមេធាវីតំណាងឲ្យ ខៀវ សំផន របស់លោក សាយ បូរី ដែលលោកយល់ថា មិនអាចធ្វើជាមេធាវីតំណាងឲ្យ ខៀវ សំផន ពេញមួយដំណើរការជំនុំជម្រះក្តីដោយមូលហេតុសុខភាព អង្គភាពគាំពារការពារក្តីបានចាត់តាំងលោក ស សូវ៉ាន ឲ្យធ្វើជាមេធាវីខ្មែរជំនួសលោក សាយ បូរី កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ ។ លោក ស សូវ៉ាន បានទទួលសញ្ញាបត្រថ្នាក់បណ្ឌិតពីសាកលវិទ្យាល័យច្បាប់ ប៉ារីស២ នៅឆ្នាំ១៩៧២ ។ លោក សាយ បូរី ក៏មានសញ្ញាបត្រថ្នាក់បណ្ឌិតដែរ ។

## ខៀវ សំផន ជានរណា?

ខៀវ សំផន មានឈ្មោះហៅក្រៅ ហែម ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកដែលអាយុតិចជាងគាត់ច្រើនហៅគាត់ថា «អ៊ំ ហែម» ។ ចំណែកអ្នកដែលមានអាយុស្រករប្រហែលនឹងគាត់បានហៅគាត់ថា «បង ហែម» ។ មានមុខងារប្រហាក់ប្រហែលនឹងគាត់បានហៅគាត់ថា «បង ហែម» ។ មានឯកសារសរសេរថា «នៅពេលដែលយើងទៅដល់ភ្នំឱរ៉ាល់ កម្មាភិបាលផ្សេងទៀតបានហៅ ខៀវ សំផន ថា តា ហុង» ។ ខៀវ សំផន កើតចេញពីគ្រួសារដែលមានឪពុកឈ្មោះ ខៀវ ឡុង និងម្តាយឈ្មោះ ពៅ គង់ ។

យោងតាមឯកសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខៀវ សំផន កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅឃុំរំចេក ស្រុករំដួល ខេត្តស្វាយរៀង ។ នៅឆ្នាំ១៩៥៩ ខៀវ សំផន បានទទួលសញ្ញាបត្រថ្នាក់បណ្ឌិតសេដ្ឋកិច្ចនយោបាយនៅប្រទេសបារាំង ។ ក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន មានមុខនាទីជាប្រធានគណៈប្រធានរដ្ឋ (ប្រមុខរដ្ឋ), អ្នកដឹកនាំមន្ទីរ៨៧០ (មន្ទីរអង្គការ) និងជាសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ។

ខៀវ សំផន គឺជាជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាអន្តរជាតិទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ (ឧក្រិដ្ឋកម្មសង្គ្រាម) ដែលជាបទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមមាត្រា ៥, ៦ និង ២៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

**ឌ៉ាន់ថាន់ ពៅដារ៉ា**

# សហកម្មឧក្រិដ្ឋកម្មរួម និងការកាត់ទោសខ្មែរក្រហម

នៅថ្ងៃទី៥ ខែធ្នូ ចៅក្រមអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងសម្រេចលើបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាជនជាតិកាណាដា និងកម្ពុជា នៅក្នុងសំណុំរឿងព្រហ្មទណ្ឌប្រឆាំងនឹង ឌុច ដែលជាអតីតប្រធានគុកទួលស្លែងដ៏ស្អុយអសោចិ៍នៅទីក្រុងភ្នំពេញ ។ បណ្តឹងឧទ្ធរណ៍នេះនឹងដោះស្រាយបញ្ហាមួយចំនួន ក៏ប៉ុន្តែបញ្ហាមួយសំខាន់ជាងគេបំផុតនោះ គឺការស្នើសុំរបស់ព្រះរាជអាជ្ញាឲ្យអនុវត្តទ្រឹស្តីច្បាប់ដែលមានភាពប្រទាំងប្រទើស គឺសហកម្មឧក្រិដ្ឋកម្មរួម ។ ដូចដែលអត្ថបទនេះពិភាក្សាអឺចឹង សេចក្តីសម្រេចរបស់ចៅក្រមលើការយល់ព្រម ឬមិនយល់ព្រមតាមការស្នើសុំនោះទំនងជានឹងធ្វើឲ្យមានផលប៉ះពាល់ដល់ការកាត់សេចក្តីដទៃទៀតឬជនជាប់ចោទខ្មែរក្រហមជាច្រើនផ្សេងទៀត ។ វាក៏អាចបង្កើតជាគំរូដ៏សំខាន់សម្រាប់ដំណើរការជំនុំជម្រះក្តីឧក្រិដ្ឋកម្មជាអន្តរជាតិឬឧក្រិដ្ឋកម្មនៅក្នុងតុលាការកូនកាត់ថែមទៀតផង ។

### តើអ្វីទៅជាសហកម្មឧក្រិដ្ឋកម្មរួម?

សហកម្មឧក្រិដ្ឋកម្មរួមដែលជារឿយៗសសេរកាត់ថា «JCE» (ជេ ស៊ី អ៊ី) គឺជាទ្រឹស្តីច្បាប់ដែលតុលាការមួយអាចប្រើដើម្បីកាត់ឲ្យជាប់ទោសនូវជនជាប់ចោទចំពោះឧក្រិដ្ឋកម្មមួយចំនួនដែលប្រព្រឹត្តដោយអ្នកដទៃក្នុងការជួយជ្រោមផែនការឬគោលបំណងរួម ។ យោងទៅតាមអ្នកសិក្សាជាន់ខ្ពស់ ផ្នែកច្បាប់ភាគច្រើនបំផុតបង្ហាញថាសហកម្មឧក្រិដ្ឋកម្មរួមមានបីប្រភេទ ។ ទីមួយ ជនជាប់ចោទអាចត្រូវបានរកឃើញថាមានទោស ប្រសិនបើខ្លួនប្រព្រឹត្តអំពើដោយចេតនា ដែលជាផ្នែកមួយរបស់ក្រុមមួយដោយអនុវត្តនូវផែនការឧក្រិដ្ឋកម្មរួម ឬការរៀបចំផែនការឧក្រិដ្ឋកម្មរួមគ្នា ។ សហកម្មឧក្រិដ្ឋកម្មរួមប្រភេទនេះ គឺពុំសូវមានភាពចម្រូងចម្រាសឡើយ ។ វាផ្អែកលើសញ្ញាណដែលទទួលបានការទទួលស្គាល់ជាយូរមកហើយនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុកដែលថាអ្នកសមគំនិត ឬអ្នកញុះញង់អាចដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម បើទោះបីជានៅពេលនោះ អ្នកទាំងនោះមិនបានចាប់ផ្តើមការប្រព្រឹត្តក៏ដោយ ។ បើទោះជាតុលាការនូរ៉ឹមប៊ឺកមិនបានប្រើពាក្យ «សហកម្មឧក្រិដ្ឋកម្មរួម» ក៏ដោយ ក៏តុលាការនេះជាតុលាការអន្តរជាតិលើកដំបូងគេដែលលើកឡើងទ្រឹស្តីស្រដៀងៗគ្នានេះ ដោយបានប្រើប្រាស់ទស្សនាទាននៃការសមគំនិតគ្នាជាមូលដ្ឋានសម្រាប់កាត់ឲ្យមន្ត្រីណាហ្ស៊ីមួយចំនួនមានទោស ។

នៅក្នុងទម្រង់សហកម្មឧក្រិដ្ឋកម្មរួមទីពីរ ជនជាប់ចោទអាចត្រូវបានរកឃើញថាមានកំហុស ចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងនៅតាមស្ថាប័នមួយដូចជា គុក ឬជំរំប្រមូលផ្តុំ ប្រសិនបើជនជាប់ចោទរក្សាទីតាំងទាំងអស់នោះមួយរយៈដោយឲ្យដំណើរការនូវកិច្ចការសំខាន់ៗមួយចំនួន ។ ទោះជនជាប់ចោទនោះមិនចាំបាច់ធ្វើទារុណកម្ម ធ្វើការសម្លាប់មនុស្ស ឬប្រព្រឹត្តអំពើឧក្រិដ្ឋកម្មផ្សេងៗទៀតក៏ដោយ ក៏មានទោសដែរ ប្រសិនបើចុងចោទមានតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងស្ថាប័នដែលមានការប្រព្រឹត្តឧក្រិដ្ឋកម្មបានកើតឡើង ។

ទម្រង់សហកម្មឧក្រិដ្ឋកម្មរួមទីបីគឺមានលក្ខណៈទូលំទូលាយ និងប្រទាំងប្រទើសបំផុត ។ ទម្រង់នេះតម្រូវឲ្យតុលាការរកឲ្យឃើញថាជនជាប់ចោទមានកំហុសចំពោះបទឧក្រិដ្ឋទាំងឡាយដែលមិនមែនជាផ្នែកមួយនៃផែនការឬការរៀបចំផែនការឧក្រិដ្ឋរួម ប៉ុន្តែផលវិបាកជា «ធម្មជាតិ និងអាចព្យាករណ៍ទុកមុនបាន» ដែលកើតចេញពីផែនការនោះ ។ អាស្រ័យហេតុនេះ ជនជាប់ចោទអាចត្រូវកាត់ឲ្យជាប់ទោសបានចំពោះឧក្រិដ្ឋកម្មដែលខ្លួនមិនបានប្រព្រឹត្ត មិនមានចេតនាប្រព្រឹត្ត និងមិនបានជួយនិងជំរុញក៏ដោយ ។ ទ្រឹស្តីនៅពីក្រោយ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួមដ៏ទូលំទូលាយនេះ គឺថាជនជាប់ចោទអាចសន្និតទុកជាមុនបានអំពីហានិភ័យដែលថាប្រសិនបើដាក់បញ្ចូលនៅក្នុងផែនការឧក្រិដ្ឋកម្មរួមដ៏គ្រោះថ្នាក់នេះ វានឹងអាចជះឥទ្ធិពលអាក្រក់ជាច្រើនផ្សេងៗគ្នាដោយឯកឯង ។

### តើហេតុអីបានជាសហកម្មឧក្រិដ្ឋកម្មរួមគឺជាបញ្ហា?

សហកម្មឧក្រិដ្ឋកម្មរួមចោទជាបញ្ហាច្រើន ដោយសារតែ

ទម្រង់សហកម្មខុក្រិដ្ឋកម្មរួមពង្រីកវិសាលភាពធំធេងនៃអំពើប្រព្រឹត្តដែលធ្វើឡើងដោយជនជាប់ចោទខ្មែរក្រហមដែលអាចចាត់ទុកថាជាបទឧក្រិដ្ឋកម្ម ។ ជាផលវិបាក ទម្រង់សហកម្មខុក្រិដ្ឋកម្មរួមអាចចោទឡើងនូវលទ្ធភាពនៃការកាត់ឲ្យជាប់ទោស ។ ច្បាប់ស្តីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានចែងអំពីសហកម្មខុក្រិដ្ឋកម្មរួមឡើយ ក៏ប៉ុន្តែមានចែងអំពីវិធីសាស្ត្រមួយចំនួនដែលធ្វើឲ្យជនជាប់ចោទអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវបាន ។ ដូចបានឃើញស្រាប់ហើយ ច្បាប់នេះបានផ្តល់សិទ្ធិឲ្យតុលាការធ្វើការវិនិច្ឆ័យសេចក្តីចំពោះជនជាប់ចោទលើបទឧក្រិដ្ឋកម្មមួយចំនួនដែលជនជាប់ចោទមិនបានប្រព្រឹត្តផ្ទាល់ ។ ច្បាប់នេះក៏អនុញ្ញាតឲ្យតុលាការកាត់ទោសជនជាប់ចោទលើបទឧក្រិដ្ឋកម្មដែលអ្នកទាំងនោះមិនបានចាប់ផ្តើមប្រព្រឹត្ត ឬបង្កការរំលោភបំពានផ្ទាល់ក៏ដោយ ។ ជនជាប់ចោទខ្មែរក្រហមអាចដាក់ឲ្យទទួលខុសត្រូវបាន ប្រសិនបើអ្នកទាំងនោះបានរៀបចំផែនការញុះញង់ ឬជួយជំរុញឲ្យមានឧក្រិដ្ឋកម្មនោះកើតឡើង ។ លើសពីនេះទៀត ជនជាប់ចោទទាំងនោះអាចត្រូវបានកាត់ឲ្យជាប់ទោស ប្រសិនបើខ្លួនកាន់មុខតំណែងដ៏មានអំណាច ហើយបញ្ជាឲ្យមានការរំលោភបំពាន ឬខកខានមិនបានទប់ស្កាត់អំពើឧក្រិដ្ឋកម្មដែលអ្នកនៅក្រោមបង្គាប់បានប្រព្រឹត្ត ។

ទម្រង់សហកម្មខុក្រិដ្ឋកម្មរួមទីមួយប្រហែលជាមិនបន្ថែមចំនួននៃការចោទប្រកាន់ច្រើនណាស់ណាទេ ដោយសារតែតុលាការអាចបានរកឃើញហើយនូវជនជាប់ចោទដែលទទួលខុសត្រូវលើការរៀបចំផែនការ ឬជួយជំរុញអំពើឧក្រិដ្ឋកម្មឲ្យកើតឡើង ។ ទម្រង់សហកម្មខុក្រិដ្ឋកម្មរួមទីពីរអាចជះឥទ្ធិពលប្រសើរជាជាងទៅលើដំណើរការកាត់សេចក្តី ។ ទម្រង់នេះអនុញ្ញាតឲ្យតុលាការអាចដាក់ជនជាប់ចោទឲ្យទទួលខុសត្រូវបានចំពោះសកម្មភាពមួយចំនួនដែលកើតមាននៅតាមគុកដូចជាគុកទួលស្លែងដែលមិនមែនជាឧក្រិដ្ឋកម្ម ប៉ុន្តែជាកន្លែងដែលបានជួយឲ្យជនជាប់ចោទអាចប្រព្រឹត្តអំពើឃោរឃៅ ។ ព្រះរាជអាជ្ញាប្រហែលជាមិនចាំបាច់ត្រូវការទម្រង់នេះដើម្បីកសាងសំណុំរឿងក្តីប្រឆាំងនឹង ឌុច ឡើយ ។ ដោយសារតែ ឌុច បានគ្រប់គ្រងគុកនោះ ព្រះរាជអាជ្ញាអាចចោទប្រកាន់គាត់ពីបទចេញបញ្ជាឲ្យមានការរំលោភបំពានរៀបចំផែនការនៃការរំលោភបំពាន ឬខកខានមិនបានហាមប្រាម ឬដាក់ទោសទណ្ឌទៅលើអំពើរបស់អ្នកនៅក្រោមបង្គាប់របស់គាត់ ។ ការជាប់ពាក់ព័ន្ធនឹងទម្រង់សហកម្មខុក្រិដ្ឋកម្មរួមទីពីរនេះ អាស្រ័យមួយភាគធំទៅលើការណ៍ដែលថាតើជនជាប់ចោទដទៃទៀតអាចត្រូវចោទប្រកាន់ពីបទថាបានអនុវត្តនូវមុខងារសំខាន់នៅក្នុងប្រព័ន្ធព្រហ្មទណ្ឌរបស់ខ្មែរក្រហមដែរឬយ៉ាងណា?

ទម្រង់សហកម្មខុក្រិដ្ឋកម្មរួមទីបីដែលមានលក្ខណៈ «ទូលាយ» គឺមានសារសំខាន់បំផុតចំពោះការកាត់ទោសខ្មែរក្រហម ។ ទម្រង់នេះបានបើកទ្វារប្រកបដោយសក្តានុពលឲ្យមានការចោទប្រកាន់យ៉ាងច្រើនថែមទៀត ដោយផ្អែកលើសញ្ញាណដែលថា មេដឹកនាំខ្មែរក្រហមបានរៀបចំគោលនយោបាយមួយចំនួនដាក់លាក់ ទូលំទូលាយ កម្រិតខ្ពស់ ហើយគួរតែត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះផលវិបាកដែលបង្កដល់ការស្លាប់មនុស្ស ។ ព្រះរាជអាជ្ញានៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី


មេឃុំនៅក្នុងសិក្ខាសាលារបស់គម្រោង «វេទិកាកម្ពុជាប្រជាធិបតេយ្យៈ រូបថតក្នុង

បានប្រើអញ្ញត្រនៃគោលការណ៍នេះក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដាក់ឲ្យស្ដូបូដាន់ មីឡូសេវិក និងមេដឹកនាំស៊ែបផ្សេងៗទៀតទទួលខុសត្រូវចំពោះបទក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយអង្គភាពយោធាដែលមិនស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់គាត់ផ្ទាល់ ។ នៅក្នុងសំណុំរឿងក្ដីប្រឆាំងនឹងជនជាប់ចោទខ្មែរក្រហម ការទទួលខុសត្រូវនៃទម្រង់ «សហកម្មខក្រិដ្ឋកម្មរួមទី៣» នេះនឹងជួយកាត់បន្ថយភាពចាំបាច់របស់សហព្រះរាជអាជ្ញាក្នុងការផ្ដល់ភ័ស្ដុតាងជាក់ស្ដែង ជាពិសេសឯកសារដែលបង្ហាញពីខ្សែសង្វាក់នៃការបញ្ជា និងការចង្អុលបង្ហាញពីចេតនាខក្រិដ្ឋជាក់លាក់របស់ជនជាប់ចោទណាម្នាក់ ។

ដោយហេតុថាពេលវេលាបានកន្លងផុតទៅយូរទៅហើយ ចាប់តាំងពីការបញ្ចប់របប ប៉ុល ពត និងប្រភេទនៃឯកសារដែលនៅសេសសល់មានកម្រិតសហកម្មខក្រិដ្ឋកម្មរួមបានដើរតួនាទីដ៏សំខាន់នៅក្នុងយុទ្ធសាស្ត្រនៃការកាត់ទោស ។ ខណៈពេលដែលសហព្រះរាជអាជ្ញាបានដាក់បណ្ដឹងខទ្ទរណ៍ថ្មីៗនេះជូនអង្គបុរេជំនុំជម្រះវិសាមញ្ញ ព្រះរាជអាជ្ញាបានកំពុងគិតដល់យ៉ាងដាក់លាក់លើជនជាប់ចោទផ្សេងៗទៀត ជាជាងការគិតដល់ចំពោះតែ ឌុច ។ អតីតប្រធានគុកទួលស្លែងមានជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងបទខក្រិដ្ឋកម្មបានចងក្រងទុកជាឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលជាភ័ស្ដុតាងដែលអាចដឹងបាននិងមានកម្លាំងខ្លាំងក្នុងការប្រឆាំងនឹងជនជាប់ចោទផ្សេងៗទៀតមានលក្ខណៈខុសប្លែកគ្នា ។


ខែសីហា ឆ្នាំ១៩៧៨» នៅខេត្តបាត់ដំបង ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨

## ហេតុអ្វីបានជាទ្រឹស្ដីសហកម្មខក្រិដ្ឋកម្មរួមមានភាពប្រទាំងប្រទើស?

ការពិភាក្សាជុំវិញសហកម្មខក្រិដ្ឋកម្មរួមស្ថិតនៅត្រង់ចំណុចសំខាន់ពីរ ។ ទីមួយគឺបញ្ហាចោទឡើងថាតើគោលការណ៍នេះមានភាពយុត្តិធម៌ចំពោះជនជាប់ចោទដែរឬទេ? ស្ទើរតែគ្រប់ប្រព័ន្ធច្បាប់ទាំងអស់ទាមទារឲ្យមានធាតុផ្សំជាមូលដ្ឋានពីរយ៉ាងដើម្បីកាត់ឲ្យជាប់ទោសចំពោះបុគ្គលណាម្នាក់ពីបទខក្រិដ្ឋកម្ម គឺអំពើដែលត្រូវហាមប្រាមនិងការមានចេតនាប្រព្រឹត្តបទខក្រិដ្ឋកម្ម ។ អនុលោមតាមទម្រង់សហកម្មខក្រិដ្ឋកម្មរួម ទីបី ជនជាប់ចោទម្នាក់អាចត្រូវបានកាត់ឲ្យជាប់ទោសចំពោះបទខក្រិដ្ឋកម្មដែលតុលាការជឿជាក់ថាជាផលវិបាកជា «ធម្មជាតិ និងអាចព្យាករណ៍ទុកបាន» ដែលកើតចេញពីផែនការណាមួយ ។ ក្រុមអ្នករិះគន់សហកម្មខក្រិដ្ឋកម្មរួមជឿថា ទ្រឹស្ដីនេះអាចជួយសម្រាលនូវតម្រូវការឲ្យមានចេតនាប្រព្រឹត្តបទខក្រិដ្ឋកម្មយ៉ាងមានប្រសិទ្ធភាព និងផ្ដល់ឲ្យចៅក្រមនូវឆន្ទានុសិទ្ធិយ៉ាងច្រើនក្នុងការក្លែងបន្លំបញ្ហា នៅពេលដែលការកាត់ឲ្យជាប់ទោសជនជាប់ចោទស្ថិតនៅក្នុងភាពមិនប្រាកដប្រជានៅឡើយ ។ សហកម្មខក្រិដ្ឋកម្មរួមទីពីរ ក៏ចោទឡើងនូវបញ្ហាស្រដៀងគ្នានេះដែរ ។ នៅក្នុងគុកមួយដែលអំពើទារុណកម្មកើតមានជាលក្ខណៈធម្មតារបស់វាសួរថាតើមានយុត្តិធម៌ដែរឬទេក្នុងការដាក់ឲ្យជាងខ្សែភ្លើងទទួលទោសចំពោះបទល្មើសដូចគ្នាទៅនឹងអ្នកសួរចម្លើយដែលប្រើរំពាត់វាយនៅក្នុងបន្ទប់នោះ? នៅក្នុងសេចក្ដីសង្ខេបថ្មីៗនេះដាក់ជូនអង្គជំនុំជម្រះវិសាមញ្ញអ្នកសិក្សាជាន់ខ្ពស់ផ្នែកសិទ្ធិមនុស្ស និងជាមេធាវីផងនោះ គឺលោក កៃ អាំបូ បានអះអាងថា សហកម្មខក្រិដ្ឋកម្មរួមទីពីរត្រូវតែយកទៅអនុវត្តឲ្យមានភាពតូចចង្អៀតជាងនេះបន្តិចដើម្បីចៀសវាងការចាប់មន្ត្រីស្មោះត្រង់ផ្សេងទៀតនៅក្នុងវង្វង់ដ៏ធំនៃភាពមានពិរុទ្ធផ្នែកព្រហ្មទណ្ឌ

នៃអំពើឧក្រិដ្ឋកម្មទាំងមូល ។

មេធាវីអន្តរជាតិមួយចំនួនតូចបដិសេធថាបញ្ហាប្រឈមនៃការអនុវត្តគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមឲ្យមានភាពស្មើគ្នាគឺមិនអាចទេ ប៉ុន្តែមេធាវីអន្តរជាតិភាគច្រើនបានគាំទ្រទ្រឹស្តីនេះ ។ អ្នកគាំទ្រទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមបានអះអាងថា គោលការណ៍នេះគឺចង់ដាក់មេដឹកនាំទាំងឡាយឲ្យទទួលខុសត្រូវយ៉ាងត្រឹមត្រូវចំពោះផែនការដែលខ្លួនបានដាក់ឲ្យអនុវត្តនិងជំរុញឲ្យអ្នកទាំងនោះទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ។ អ្នកជំទាស់នឹងគោលការណ៍នេះក៏បានទទួលស្គាល់ហេតុផលមួយផ្សេងទៀតចំពោះទ្រឹស្តីនេះថា ប្រសិនបើគ្មានគោលការណ៍នេះទេ ការកាត់ឲ្យមេដឹកនាំកំពូលៗជាប់ទោសពិតជាមានការពិបាកមិនខាន ។ សហកម្មឧក្រិដ្ឋកម្មរួមបានបង្កើតឡើងដើម្បីជាវិធីមួយក្នុងការបំពេញប្រយោជន៍ខាងសីលធម៌និងនយោបាយដ៏មានឥទ្ធិពលក្នុងការដាក់ឲ្យមេដឹកនាំអាក្រក់ទទួលខុសត្រូវចំពោះការប្រព្រឹត្តខុសរបស់ខ្លួន ដែលជារឿយៗត្រូវបានបិទបាំងដោយវិសាលភាព និងភាពស្មុគ្រស្មាញនៃអំពើរំលោភបំពាន ។ ចៅក្រមនៃអង្គបុរេជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវធ្វើការថ្លឹងថ្លែងពីផលប្រយោជន៍ប្រកបដោយភាពប្រកួតប្រជែងនេះ ក្នុងការសម្រេចថាតើគួរអនុញ្ញាតឲ្យមានសហកម្មឧក្រិដ្ឋកម្មរួមនេះដែរឬទេ ជាពិសេសនៅក្នុង «ទម្រង់ទី៣» ដែលមានភាពទូលំទូលាយបំផុតនោះ ។ ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក៏ត្រូវតែដោះស្រាយបញ្ហាផ្លូវច្បាប់ដ៏លំបាកទីពីរទៀត ។ គោលការណ៍ជាមូលដ្ឋានដ៏សំខាន់បំផុតមួយនៃច្បាប់ព្រហ្មទណ្ឌចែងថា ជនជាប់ចោទមិនអាចត្រូវបានកាត់ទោសពីបទឧក្រិដ្ឋកម្មមួយដែលមិនមានចែងពីមុនមកនៅពេលដែលជនជាប់ចោទនោះប្រព្រឹត្តអំពើនោះឯង ។ ប្រការនេះចោទជាបញ្ហាឡើងថាតើទម្រង់សហកម្មឧក្រិដ្ឋកម្មរួមផ្សេងៗទៀតមានចែងតាំងតែពីឆ្នាំ១៩៧៥ដែរឬទេ? ជាការណ៍ច្បាស់ណាស់ថា ពាក្យនេះមិនត្រូវបានប្រើប្រាស់ទេដោយគិតត្រឹមឆ្នាំ ១៩៧៥ ។ តើគោលការណ៍នេះនៅតែជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរឬទេ?

អ្នកសិក្សាជាន់ខ្ពស់មានទស្សនៈខុសៗគ្នាលើបញ្ហានេះ ។ នៅក្នុងសេចក្តីសង្ខេបដែលដាក់ជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អតីតចៅក្រមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អង់តូនីញ៉ូ កាសេស បានឆ្លើយបញ្ជាក់ ។ លោកចៅក្រមបានអះអាងថា ទម្រង់សហកម្មឧក្រិដ្ឋកម្មរួមទាំងបីនេះបានក្លាយទៅជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅត្រឹមឆ្នាំ១៩៧៥ ដោយផ្អែកលើយុត្តិសាស្ត្រនៅនូរ៉ែមប៊ឺក និងនៅក្នុងការកាត់ទោសជាអន្តរជាតិផ្សេងៗទៀត ។ ទោះជាយ៉ាងណាក៏ដោយ កាសេស គឺជាឥស្សរជនសំខាន់ម្នាក់ដែលទទួលខុសត្រូវចំពោះការវិវត្តនៃគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងការកាត់ទោសនៅយូហ្គោស្លាវីដែលនាំឲ្យអ្នកវិភាគមួយចំនួនចោទសួរអំពីភាពមិនលម្អៀងរបស់គាត់ ។ មេធាវីការពារក្តីរបស់ អៀង សារី ក៏បានព្យាយាម (ដោយមិនបានជោគជ័យ) ក្នុងការច្រានចោលសេចក្តីសង្ខេបនេះដោយសារតែបញ្ហានៃភាពលម្អៀង ។ មេធាវី ស៊ីលកេ ស្ទូឌីនស្គី ដែលតំណាងឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានឆ្លើយតបជាមួយ កាសេស ដោយបានអះអាងថា សហកម្មឧក្រិដ្ឋកម្មរួមទីបីមិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេនៅក្នុងឆ្នាំ១៩៧០ ។ អ្នកសិក្សាជាន់ខ្ពស់ផ្សេងៗទៀតមានការយល់ឃើញផ្សេងៗពីគ្នាលើបញ្ហានេះ ។ ជាថ្មីម្តងទៀត ទាំងសងខាងមានទឡ្ហីករណ៍ដ៏គួរឲ្យទុកចិត្តបានដូចគ្នា ។

## តើតុលាការនឹងសម្រេចយ៉ាងដូចម្តេច?

ចៅក្រមនៃអង្គបុរេជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រឈមនឹងការសម្រេចចិត្តខាងផ្លូវច្បាប់ដ៏សំខាន់ ហើយលទ្ធផលយ៉ាងណាៗនោះគឺមិនទាន់ប្រាកដប្រជានៅឡើយ ។ ចៅក្រមអាចយល់ព្រមទទួលយកទម្រង់សហកម្មឧក្រិដ្ឋកម្មរួមទាំងអស់ឬក៏អនុញ្ញាតឲ្យព្រះរាជអាជ្ញាលើកយកមកប្រើប្រាស់នូវទម្រង់សហកម្មឧក្រិដ្ឋកម្មរួមខ្លះ ក៏ប៉ុន្តែមិនមែនទាំងអស់ឬយ៉ាងណានោះទេ ។ ប្រសិនបើចៅក្រមទទួលយកទម្រង់សហកម្មឧក្រិដ្ឋកម្មរួមណាមួយនោះ ចៅក្រមត្រូវតែកំណត់វិសាលភាពនៃគោលការណ៍នោះឲ្យបានច្បាស់លាស់ ។ ចៅក្រមអាចបដិសេធចោលនូវទ្រឹស្តីទាំងអស់តែម្តងក៏បានដោយអះអាងថា ទ្រឹស្តីនោះមិនមានចែងក្នុងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយមិនមែនជាគោលការណ៍ដែលបានដោះស្រាយរួចរាល់

ក្រោមច្បាប់ទំនៀមទម្លាប់គិតមកត្រឹមឆ្នាំ១៩៧៥ នៅឡើយ ។

ជាប្រវត្តិសាស្ត្រកន្លងមក តុលាការឧក្រិដ្ឋកម្មអន្តរជាតិនិងតុលាការកូនកាត់ទាំងឡាយមិនមានអារម្មណ៍ខ្មាសអៀនចំពោះការជំរុញឲ្យទ្រឹស្តីនេះត្រូវបានយកទៅអនុវត្តនិងការបង្កើតនូវទ្រឹស្តីថ្មីនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។ នៅពេលដែលតុលាការនូរ៉ែមប៊ឺកបានកាត់ទោសពួកណាហ្ស៊ីឲ្យជាប់ទោសពីបទសមគំនិត អ្នកសិក្សាជាន់ខ្ពស់ខ្លះបានអះអាងថាការកាត់ទោសនេះបានរំលោភសិទ្ធិចុងចោទ ។ ក្រុមអ្នករិះគន់អះអាងថា គ្មានបទឧក្រិដ្ឋកម្មបែបនោះពុំមានចែងនៅក្នុងច្បាប់អន្តរជាតិឡើយក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានប្រឈមនឹងការរិះគន់ស្រដៀងគ្នានេះដែរ នៅពេលដែលតុលាការនេះប្រើប្រាស់ទម្រង់សហកម្មឧក្រិដ្ឋកម្មរួមដ៏ទូលំទូលាយដើម្បីធ្វើការកាត់ទោស មីឡូសេវិក និងគូកនរបស់គាត់ ។

សកម្មភាពខាងផ្លូវច្បាប់នៅក្នុងវេទិកាបទឧក្រិដ្ឋកម្មអន្តរជាតិអាចជារឿងល្អមួយ ។ ប្រសិនបើតុលាការនូរ៉ែមប៊ឺក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីមិនមានការរីកចម្រើនក្នុងការបកប្រែច្បាប់នោះទេ តុលាការទាំងនេះនឹងមិនផ្តល់យុត្តិសាស្ត្រដ៏មានតម្លៃជាគំរូដែលអាចជួយឲ្យច្បាប់ព្រហ្មទណ្ឌអន្តរជាតិងើបឡើងចេញពីភាពក្មេងខ្ចីនោះបានទេ ។ តុលាការទាំងនោះក៏នឹងមិនអាចមានលទ្ធភាពនាំយកជនដៃដល់មកកាត់ទោសបានដែរ ។ ទោះបីជាយ៉ាងនេះក្តី ប្រសិនបើចៅក្រមត្រូវបានមើលឃើញថាជាអ្នកបង្កើតច្បាប់នោះ ចៅក្រមទាំងនោះបានបំពេញនូវការយល់ឃើញថាតុលាការអន្តរជាតិឬតុលាការកូនកាត់គឺចង់ធ្វើយ៉ាងណាឲ្យតែសម្រេចបាននូវលទ្ធផលមួយជាជាងការចង់ធ្វើការកាត់ទោសមួយប្រកបដោយយុត្តិធម៌ ។ យុត្តិធម៌មិនមែនជាការចងពៀរនោះទេ ។ វាមានន័យថា ជាការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងការអនុវត្តច្បាប់ប្រកបដោយភាពត្រឹមត្រូវជួនកាលតម្រូវឲ្យមានការអត់ធ្មត់ទាំងមិនអស់ចិត្ត ហើយអនុញ្ញាតឲ្យជនជាប់ចោទដ៏ឃោរឃៅទទួលបានផលប្រយោជន៍ពីការការពារជាច្រើនយ៉ាងដែលពីមុនជននេះបានបដិសេធមិនឲ្យអ្នកដទៃទទួលបានផលប្រយោជន៍ដូចខ្លួនទៅវិញ ។

ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែរិះរកដោយប្រយ័ត្នប្រយែងក្នុងការសម្រេចឲ្យដល់គោលដៅដែលមានលក្ខណៈប្រកួតប្រជែងបែបនេះ ។ មាគ៌ាដែលពុំសូវមានលក្ខណៈនយោបាយមួយ គឺទំនងជាអនុញ្ញាតឲ្យមានទម្រង់សហកម្មឧក្រិដ្ឋកម្មរួមចំនួនពីរ ហើយបើសិនជាអាចគឺយកទម្រង់ទាំងបីដើម្បីបម្រើប្រយោជន៍ដល់ការកាត់ឲ្យជាប់ទោសមន្ត្រីខ្មែរក្រហម និងធ្វើឲ្យរីកចម្រើននូវទស្សនវិស័យនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ក៏ប៉ុន្តែបើគិតពីទស្សនៈច្បាប់ដ៏តឹងរ៉ឹងវិញ បញ្ហានេះគឺមិនសូវមានភាពច្បាស់លាស់ឡើយ ។ ការអនុញ្ញាតឲ្យមានសហកម្មឧក្រិដ្ឋកម្មរួម និងជាពិសេសសហកម្មឧក្រិដ្ឋកម្មរួមទីបីនឹងទទួលបានការស្ញើចសរសើរយ៉ាងជាក់ច្បាស់ពីព្រះរាជអាជ្ញា ក៏ប៉ុន្តែអាចជំរុញឲ្យមានការពិភាក្សាយ៉ាងគគ្រឹកគគ្រេងនៅក្នុងអគាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងក្នុងចំណោមអ្នកសង្កេតការណ៍ខាងក្រៅទៀតផង ។

ប្រសិនបើចៅក្រមពិតជាយល់ព្រមឲ្យប្រើទម្រង់សហកម្មឧក្រិដ្ឋកម្មរួមទាំងអស់នេះមែនចៅក្រមត្រូវតែផ្តល់ហេតុផលផ្លូវច្បាប់ឲ្យបានសមស្រប និងច្បាស់លាស់ដើម្បីទប់ទល់នឹងការរិះគន់ដែលត្រឹមត្រូវតាមច្បាប់នានាដូចបានសង្ខេបជូនពីខាងលើ ។ ប្រសិនបើចៅក្រមបដិសេធចោលនូវការស្នើសុំរបស់សហព្រះរាជអាជ្ញាចៅក្រមនឹងបញ្ជូនសញ្ញាណដ៏មានឥទ្ធិពលមួយថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងដើរតាមអ្វីដែលជាវិធីសាស្ត្រផ្នែកច្បាប់ដែលមានលក្ខណៈអភិរក្សជាជាងដើរតាមអ្វីដែលបន្សល់ទុកពីតុលាការមុនៗ ។ ជាថ្មីម្តងទៀតគឺថាហេតុផលផ្លូវច្បាប់ដ៏ច្បាស់លាស់ត្រូវតែមានជាចាំបាច់ ។ វិធានការដែលត្រូវបានយល់ថាបានផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទខ្មែរក្រហមមិនមែនសុទ្ធតែខុសនោះទេ ក៏ប៉ុន្តែវិធានការបែបនេះគ្រាន់តែមិនទទួលបានប្រជាប្រិយភាពប៉ុណ្ណោះ ។ បើទោះបីជាចៅក្រមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រេចយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើយ៉ាងណាឲ្យបាន ដោយគូសបញ្ជាក់ធ្ងន់ៗថា យុត្តិធម៌គឺតម្រូវឲ្យមានការដាក់ឲ្យទទួលខុសត្រូវឲ្យទាល់តែបាន ហើយមានភាពត្រឹមត្រូវតាមច្បាប់ទៀតផង ។

**ចន ឆរធីរាវី**

00243306

A190/I/14

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / DEC / 2008
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fry

សំណុំរឿងព្រហ្មទណ្ឌលេខ:០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ១១)

## របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង (សាធារណៈ)

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 03 / DEC / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fry

I) នីតិវិធី

II) ការពិនិត្យសំណុំរឿងដោយសហចៅក្រមរបាយការណ៍

### I) នីតិវិធី

### ក) សេចក្តីផ្តើម

អនុលោមតាមវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") ប្រធានអង្គបុរេជំនុំជម្រះបានចាត់តាំងលោកចៅក្រម **ន៉ី ធុល** និង លោកស្រីចៅក្រម Katinka **LAHUIS** ឱ្យធ្វើរបាយការណ៍ពិស្តារអំពីសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការចេញដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ដែលត្រូវបានប្តឹងឧទ្ធរណ៍ ហើយឱ្យធ្វើរបាយការណ៍លើអង្គហេតុដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងលេខ:០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ១១)។

**ដែលក្នុងនោះជនត្រូវចោទ៖**

**ខៀវ សំផន** ហៅ "**ហែម**" ភេទប្រុស កើតថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅឃុំរំចេក ស្រុករំដួល ខេត្តស្វាយរៀង ប្រទេសកម្ពុជា ទីលំនៅមុនពេលចាប់ខ្លួន នៅភូមិក្បូនខ្ពង់ សង្កាត់អូរតាវៅ ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន ឪពុកឈ្មោះ **ខៀវ ឡុង** (ស្លាប់) ម្តាយឈ្មោះ **ស៊ោ គង់** (ស្លាប់) ប្រពន្ធឈ្មោះ **សូ សុជាតិ** មានកូន ៤ នាក់។

លោក **ខៀវ សំផន** មានលោក **ស សុវាន** និង លោក **Jacques VERGÈS** ជាសហមេធាវីតំណាង។

**បទចោទ**

**ខៀវ សំផន** ត្រូវបានដាក់ឱ្យស្ថិតក្រោមការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (អំពើឃាតកម្ម ការសម្លាប់បំផុតពូជ ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និង អំពើអមនុស្សធម៌ផ្សេងៗទៀត) និងបទ

00243307

A190/I/14
00២/១៩-០៩-២០០៧-អវតក-កសចស (អបជ១១)

រំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ (ការសម្លាប់ដោយចេតនា, ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬ ការធ្វើឱ្យឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ ឬ សុខភាព, ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម ឬ ជនស៊ីវិល នូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌, ការនិរទេស ឬការជម្លៀស ឬការឃុំឃាំងជនស៊ីវិល ដោយខុសច្បាប់) ដែលជាបទល្មើសមានចែង និង ផ្តន្ទាទោសតាមមាត្រា ៥, ៦, ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតឱ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ (ច្បាប់ អ.វ.ត.ក)។

**គោលបំណងនៃរបាយការណ៍**

របាយការណ៍របស់សហចៅក្រមរបាយការណ៍នេះ រៀបរាប់ពិស្តារអំពីសេចក្តីសម្រេចដែលត្រូវបានថ្លឹងឧទ្ទរណ៍ និងអង្គហេតុផ្សេងៗទៀតដែលដាក់ជូនចំពោះមុខតុលាការ។

**១). ការចេញដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ របស់សហចៅក្រមស៊ើបអង្កេត**

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ(“ដីកា”) ដែលដីកានេះត្រូវបានជូនដំណឹងដល់ជនត្រូវចោទ និងភាគីទាំងអស់នៅក្នុងសំណុំរឿង ដែលក្នុងនោះមានរូបលោក **ខៀវ សំផន** ផងដែរ។[1]

នៅក្នុងដីកានេះ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញមានហេតុផលបី ដែលនៅក្នុងនោះ សហមេធាវីរបស់ជនត្រូវចោទ បានស្នើសុំឱ្យបកប្រែឯកសារនៅក្នុងសំណុំរឿងរបស់គាត់ ហើយ ជាពិសេស គឺបកប្រែឯកសារទាំងនោះទៅជាភាសារបស់សហមេធាវីការពារក្តីអន្តរជាតិរបស់ជនត្រូវចោទ គឺភាសាបារាំង[2]។

សហចៅក្រមស៊ើបអង្កេតបានពិចារណាថា:

> “ម្យ៉ាង សិទ្ធិរបស់ជនត្រូវចោទទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ត្រូវតែមានការយកចិត្តទុកដាក់ ដែលសិទ្ធិទាំងនេះរួមមានដូចជា សិទ្ធិទទួលបានការជូនដំណឹងភ្លាមៗ និងពិស្តារ ជាភាសាដែលជនត្រូវចោទយល់បានអំពីប្រភេទ និងមូលហេតុនៃបទចោទប្រកាន់មកលើខ្លួន, សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំការការពារខ្លួន, សិទ្ធិមាន“*សមភាពនៃរាងអាវុធ និងមេធាវីការពារក្តី*” និង ជាពិសេស សិទ្ធិ

---

[1] ដីកាចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ឯកសារលេខ A190

[2] ការប្រកាសរបស់សហមេធាវីអន្តរជាតិ របស់លោក ខៀវ សំផន ទៅសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៤ កុម្ភៈ ២០០៨, (D75) ការប្រកាសរបស់សហមេធាវីអន្តរជាតិ របស់លោក ខៀវ សំផនចំពោះមុខអង្គបុរេជំនុំជម្រះ ២៣ មេសា ២០០៨, លិខិតពីក្រុមមេធាវីការពារក្តីលោក ខៀវ សំផនទៅលោក ប្រធានផ្នែកគ្រប់គ្រងតុលាការ ចុះថ្ងៃទី៥ មិថុនា ២០០៨។

របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង ២

00243308

A190/I/14
០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១១)

ពិនិត្យភស្តុតាងដាក់បន្ទុក និងសិទ្ធិទទួលបានការបង្ហាញ និង ការពិនិត្យភស្តុតាង ជំនួសឱ្យខ្លួន ក្រោមលក្ខខណ្ឌដូចគ្នា នឹងភស្តុតាងដាក់បន្ទុក, និងសិទ្ធិចុងក្រោយ គឺសិទ្ធិមាន ជំនួយពីអ្នកបកប្រែភាសាដោយមិនបង់ថ្លៃ ប្រសិនបើជនត្រូវចោទមិនអាចយល់ ឬមិនចេះភាសាដែលប្រើក្នុងតុលាការ។"

"ម្យ៉ាង សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ នឹងត្រូវបានប៉ះពាល់យ៉ាងខ្លាំង ប្រសិនបើឯកសារទាំងអស់នៅក្នុងសំណុំរឿង ត្រូវបានទាមទារអោយមានការបកប្រែណ ទៅជាបីភាសាប្រើប្រាស់ជាផ្លូវការនៅក្នុងការងារ អ.វ.ត.ក។"[3]

នៅក្នុងទស្សនៈរបស់សហចៅក្រមស៊ើបអង្កេត, តម្រូវការអាចកើតចេញពីមាត្រា ២១(៣)នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ("កិច្ចព្រមព្រៀង") និងវិធាន ១១(៤) និងវិធាន ២២(១) នៃវិធានផ្ទៃក្នុង។ បទប្បញ្ញត្តិទាំងនេះលើកឡើងថា ភាគីនានា ត្រូវចូលរួមចំណែកក្នុងការដោះស្រាយលើបញ្ហានៃសេចក្តីត្រូវការផ្នែកភាសារបស់ខ្លួន ដោយប្រើប្រាស់សមត្ថភាពផ្នែកភាសានៅក្នុងចំណោមក្រុមរបស់ខ្លួន និងផ្នែកគាំពារការការពារក្តី ហើយដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយផ្នែកគ្រប់គ្រងតុលាការ ("CMS") ដើម្បីអាចឱ្យផ្នែកនេះសម្របសម្រួលតម្រូវការការបកប្រែ និងដាក់អាទិភាពលើឯកសារ។[4]

សហចៅក្រមស៊ើបអង្កេតបានសម្រេចថា:

"ជនត្រូវចោទមានសិទ្ធិទទួលបានការបកប្រែជាភាសាខ្មែរ នូវរាល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ស្របតាមវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ដោយហេតុថាដីកានេះបង្ហាញពីអង្គហេតុ និងមូលដ្ឋាននៃបទចោទទាំងអស់ សម្រាប់ការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ លើសពីនេះទៀត ជនត្រូវចោទមានសិទ្ធិទទួលបានការបកប្រែជាភាសាខ្មែរនូវភស្តុតាងទាំងឡាយដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះបានយកមកធ្វើជាសម្អាង[...]

ជនត្រូវចោទមានសិទ្ធិទទួលបានការបកប្រែជាភាសាខ្មែរផងដែរ នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ព្រមទាំងលេខយោង និងលិបិក្រមនៃអង្គហេតុ ដែលដីកាទាំងនេះសម្អាងលើ។"[5]

ជាបន្ថែម ភាគីដែលត្រូវបានស្នើសុំបកប្រែ ត្រូវផ្តល់ជូនទៅផ្នែកគ្រប់គ្រងតុលការ នូវបញ្ជីឯកសារសំណុំរឿងជាក់លាក់ ដែលខ្លួនចាត់ទុកជាបញ្ហាអាទិភាពទាមទារអោយមានការបកប្រែ រួមទាំងសំណើនានាឱ្យកែប្រែសំណើសុំការបកប្រែពីមុនដែលមិនទាន់បានបញ្ចប់។[6] ក្រុមមេធាវីការពារក្តីត្រូវរួមបញ្ចូលផងដែរ ថាតើឯកសារ

[3] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ វាក្យខណ្ឌទី ក ៣។

[4] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ វាក្យខណ្ឌទី ក ៤។

[5] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ វាក្យខណ្ឌទី ខ ៤។

[6] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ទំព័រទី ៧ វាក្យខណ្ឌទី ២។

00243309

A190/I/14


តម្រូវអោយមានការបកប្រែទាំងមូល រឺក៏បកប្រែមួយផ្នែក, ចំនួនទំព័រដែលត្រូវបកប្រែ នឹងត្រូវបកប្រែជាភាសាអ្វី កម្រិតអាទិភាពដែលបានផ្តល់ចំពោះការបកប្រែ និងមូលហេតុនៃការស្នើសុំការបកប្រែ។[7]

ផ្នែកគ្រប់គ្រងតុលាការ ត្រូវផ្តល់ជូនសហចៅក្រមស៊ើបអង្កេត និងភាគីនានា នូវបញ្ជីលេខរៀងពេញលេញ នៃសំណើសុំរង់ចាំការបកប្រែទាំងអស់ នូវធនធានដែលមាន ជាមួយនឹងគម្រោងថ្ងៃដែលគិតថាសំណើសុំទាំងនេះ អាចត្រូវបានបំពេញរួចរាល់ និងផ្នែកគ្រប់គ្រងតុលាការត្រូវរក្សាបញ្ជីស្នើសុំបកប្រែរបស់ភាគី។[8] ជាការបន្ថែម:

"ផ្នែកគ្រប់គ្រងតុលាការ និងភាគីនានា ត្រូវខិតខំស្វែងរកការឯកភាពគ្នានៅពេលមានអាទិភាពជាន់គ្នា ហើយប្រសិនបើមិនមានការឯកភាពគ្នាទេ ផ្នែកគ្រប់គ្រងតុលាការត្រូវរាយការណ៍ជូនសហចៅក្រមស៊ើបអង្កេត [...] ដែលជាអ្នកដោះស្រាយទំនាស់នេះ តាមវិធីណាមួយដូចជាការកំណត់អាទិភាពឲ្យបានជាក់លាក់ និងប្រសិនបើជៀសមិនរួច តាមការកំណត់កូតាសម្រាប់ការបកប្រែ"។[9]

ជាចុងក្រោយ, ក្រុមការពារក្តីនីមួយៗត្រូវបញ្ជាក់អំពីភាសាដែលខ្លួនចង់បាន ក្នុងចំណោមភាសាដែលប្រើប្រាស់ជាផ្លូវការ ដើម្បីអោយការិយាល័យរដ្ឋបាល អាចតែងតាំងអ្នកបកប្រែជូនពួកគាត់។ និងបន្ទាប់មក ការិយាល័យរដ្ឋបាលនឹងធ្វើការតែងតាំងអ្នកបកប្រែពេញម៉ោងសម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗ ដោយមិនគិតកំរៃ សម្រាប់រយៈពេលពីរខែ និងអាចបន្តបាន។[10] ដើម្បី:

"ជនជាប់ចោទ និងក្រុមមេធាវីការពារក្តី អាចមានឯកសារមួយចំនួនត្រូវបានបកប្រែទៅតាមការចាំបាច់, ដើម្បីវាយតម្លៃពីតម្រូវការនៃការបកប្រែដែលត្រូវបញ្ជូនទៅ ផ្នែកគ្រប់គ្រងតុលាការ និងដើម្បីជួយដល់កិច្ចសហការរបស់ក្រុមមេធាវីការពារក្តី ជាមួយនឹងផ្នែកគ្រប់គ្រងតុលាការ"[11]

ការបន្តការតែងតាំង គឺជាឆន្ទានុសិទ្ធិរបស់ការិយាល័យរដ្ឋបាល បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសហចៅក្រមស៊ើបអង្កេត។[12]

[7] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ទំព័រទី ៧ វាក្យខណ្ឌទី ២។
[8] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ទំព័រទី ៧ វាក្យខណ្ឌទី ១-៣។
[9] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ទំព័រទី ៧ វាក្យខណ្ឌទី ៤។
[10] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ទំព័រទី ៧ វាក្យខណ្ឌទី ៦។
[11] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ វាក្យខណ្ឌទី ៥៦។
[12] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ទំព័រទី ៨ វាក្យខណ្ឌទី ៦។

00243310

A190/I/14
00២/១៩-០៩-២០០៧-អវតក-កសចស (អបជ០១)

## គ) បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាបកប្រែរបស់សហចៅក្រមស៊ើបអង្កេត

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍[13] ហើយនៅថ្ងៃទី ២២ កក្កដា ២០០៨ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធនឹសុំបកប្រែភាសាសំណុំរឿងរបស់លោក ខៀវ សំផន (បណ្តឹងឧទ្ធរណ៍)។[14]

សហមេធាវីការពារក្តីរបស់លោក **ខៀវ សំផន** បានស្នើមកអង្គបុរេជំនុំជម្រះ ១). ទុកជាមោឃៈ នូវសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធនឹនូវការស្នើសុំឱ្យមានការបកប្រែនៃសំណុំរឿង, ២) កត់សម្គាល់នូវការរំលោភបំពានសិទ្ធិការពារក្តីផ្សេងៗ ដែលបណ្តាលមកពីអវត្តមាននៃការបកប្រែ, ៣) បង្គាប់ឱ្យដោះលែង លោក ខៀវ សំផន ភ្លាមៗ និងដោយគ្មានលក្ខខណ្ឌ។[15] មេធាវីក៏បានលើកពីកង្វះខាតនៃមូលដ្ឋានផ្លូវច្បាប់នៃសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត និងថាសិទ្ធិរបស់ជនត្រូវចោទត្រូវបានរំលោភដល់កំរិតមួយដែលមិនអាចធានាបាននូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។[16]

## ឃ) សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍ ហើយលើកទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ ពីព្រោះលិខិតបទដ្ឋានគតិយុត្តរបស់ អ.វ.ត.ក ពុំបានផ្តល់នូវការប្តឹងឧទ្ធរណ៍ដែលទាក់ទងនឹងបញ្ហាបកប្រែភាសានោះទេ។ នៅក្នុងការយល់ឃើញរបស់សហព្រះរាជអាជ្ញា បណ្តឹងឧទ្ធរណ៍នេះមានវិការៈលើអង្គសេចក្តី ហើយការចេញដីកាសម្រេចស្តីពីការបកប្រែរបស់សហចៅក្រមស៊ើបអង្កេត មិនបានបំពានលើសិទ្ធិក្នុងការទទួលបានការកាត់ក្តីដ៏ត្រឹមត្រូវណាមួយរបស់ភាគីប្តឹងឧទ្ធរណ៍នោះទេ។ ជនត្រូវចោទក៏មិនមានសិទ្ធិទទួលបាននូវដំណោះស្រាយណាមួយដែលជាផលវិបាក ក៏ដូចជាសិទ្ធិក្នុងការដោះលែងផងដែរ។[17]

## ង) សេចក្តីសន្និដ្ឋានតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី

សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សេចក្តីសន្និដ្ឋានតបឡើយ។

---

[13] សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ (ឯកសារលេខ A190/I)

[14] សារណាបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២ កក្កដា ២០០៨ (ឯកសារលេខ A190/I/1)

[15] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៨០។

[16] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៧៥-៧៦។

[17] ការិយាល័យសហព្រះរាជអាជ្ញា, "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៨ សីហា ២០០៨ វាក្យខណ្ឌទី ៥៧"។

របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង ៥

00243311

A190/I/14
០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១១)

II) **ការពិនិត្យសំណុំរឿងដោយសហចៅក្រមរបាយការណ៍**

**អំណះអំណាងរបស់ភាគី**

ក) **ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍**

សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទមិនអាចទទួលយកបាន ដោយសារ "វិធាន ៧៤(៣)នៃវិធានផ្ទៃក្នុង បានរៀបរាប់លើប្រភេទដីកាទាំងអស់ ដែលជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ ហើយវិធាននេះមិនបានរួមបញ្ចូលនូវបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងសំណើសុំការបកប្រែឯកសារ។"[១៨]

ខ) **សមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការចេញដីកាបង្គាប់ការបកប្រែ**

សហមេធាវីការពារក្តីរបស់ជនត្រូវចោទសន្និដ្ឋានថា មានបទបញ្ញត្តិច្បាស់លាស់ទាក់ទងនឹងការបកប្រែភាសា។ អត្ថន័យជាលំដាប់ នៅក្នុងមាត្រា ២៦.២ នៃកិច្ចព្រមព្រៀង និងមាត្រា ៤៥ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក " ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់ អ.វ.ត.ក គឺភាសាខ្មែរ អង់គ្លេស និង ភាសាបារាំង ដែលសហចៅក្រមស៊ើបអង្កេតបានចេញនូវដីកាស្តីពីការបកប្រែដោយគ្មានមូលដ្ឋានច្បាប់។[19]

យ៉ាងណាមិញ, សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា បញ្ហាបកប្រែភាសាស្ថិតនៅក្នុងអំណាចនៃការសម្រេចរបស់សហចៅក្រមស៊ើបអង្កេត និងវាជាបញ្ហានៃយុត្តាធិការរដ្ឋបាលរបស់តុលាការ។[20]

គ) **លក្ខណៈពិសេសរបស់ អ.វ.ត.ក**

សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានលើកឡើងថា ការបដិសេធនៃការបកប្រែសំណុំរឿងមិនបានគិតគូរដល់លក្ខណៈពិសេសរបស់ អ.វ.ត.ក:

"ពិតប្រាកដណាស់ អ.វ.ត.ក គឺជាតុលាការទីមួយ ដែលមានលក្ខណៈចម្រុះ រឺអន្តរជាតិ ដែលមិនមែនជាតុលាការដែលយកលំនាំតាមប្រព័ន្ធច្បាប់ ខូមិនឡូ (Common law)។ អ.វ.ត.ក ផ្អែកលើប្រពៃណីបែប ស៊ីវិលឡូ (Civil law)" ដែលមានលក្ខណៈដឹកនាំដោយចៅក្រម ហើយដែលមានដំណាក់កាលស៊ើបអង្កេតពិសេសមួយ[...]

---

[១៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ២៦។

[19] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ២៩-៣១។

[20] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ២៥។

00243312

A190/I/14
០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១១)

"នៅក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេត, និងដើម្បីទទួលបាននូវសិទ្ធិការពាររបស់ជនត្រូវចោទជាការពិត [ប្រព័ន្ធច្បាប់ស៊ីវិលឡ-Civil law system] ផ្តល់នូវសិទ្ធិមេធាវីដើម្បីត្រួតពិនិត្យការស៊ើបអង្កេតសំណុំរឿង ជាភាសាដែលអាចយល់បាន។ វាជាភាសារបស់មេធាវីដែលមានអានុភាព មិនមែនភាសារបស់ជនត្រូវចោទទេ"។[21]

**សហព្រះរាជអាជ្ញាបានឆ្លើយតបថា:**

"[...] នៅពេលដែលអាចនឹងមានការខុសគ្នាជាលក្ខណៈប្រព័ន្ធនោះ ដំណោះស្រាយតាមផ្លូវច្បាប់ដែលត្រូវបានកំណត់ដោយវិធាននានា និងដែលត្រូវបានបញ្ជាក់នៅក្នុងដីកាសម្រេចស្តីពីការបកប្រែ បានធ្វើអោយកើតមាននូវការខុសគ្នាទាំងនោះ បើសិនជាមានការខុសគ្នាណាមួយដែលមិនមានផលវិបាក។ នៅពេលដែលមានការពិតថា ក្នុងពេលភ្លាមៗបន្ទាប់ពីចូលរួមនៅក្នុងកិច្ចស៊ើបសួរ នៅក្នុងពេលសវនាការដេញដោល ចុងចោទត្រូវបានអញ្ជើញអោយដាក់សារណាអំពីភស្តុតាងសំខាន់ៗនោះ សិទ្ធិពិនិត្យមើលឯកសាររបស់គាត់ អាចនឹងត្រូវបានបង្កលក្ខណៈងាយស្រួល ដោយសារកិច្ចសហការក្នុងរង្វង់ក្រុមមេធាវីរបស់គាត់ និងដោយសារការជួយឧបត្ថម្ភពីផ្នែកគាំពារការពារក្តី។[22]

## ឃ) សិទ្ធិរបស់ជនត្រូវចោទទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌

សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានលើកឡើងថា អវត្តមាននៃការបកប្រែ និងវិធានការដែលចាត់ឡើងដោយសហចៅក្រមស៊ើបអង្កេត វាធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនត្រូវចោទ។ សហមេធាវីបានលើឡើងជាទូទៅថា ដីកាស្តីពីការបកប្រែរំលោភបំពានលើសិទ្ធិរបស់ជនត្រូវចោទក្នុងការចូលរួមដំណើរការនីតិវិធី, សិទ្ធិទទួលបានសមតុល្យនៃកំលាំង, សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ។[23]

សហព្រះរាជអាជ្ញាបានឆ្លើយតបថា ដីកាស្តីពីការបកប្រែ មិនបានបានធ្វើអោយមានការអន្តរាយផ្សេងៗដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌ឡើយ។[24]

"ការជំនុំជម្រះដោយត្រឹមយុត្តិធម៌ ដែលតម្រូវអោយផ្តល់ឯកសារជាភាសាដែលចុងចោទអាចយល់បាននោះ គឺត្រូវបានបំពេញឲ្យបានគ្រប់គ្រាន់ ដោយដំណោះស្រាយចំពោះសមត្ថភាពពេញលេញខាងភាសាសាស្ត្រ

[21] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៣៣-៣៥។
[22] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៣៨។
[23] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៥៦-៧១។
[24] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៣៦។

00243313

A190/I/14
០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១១)

របស់ក្រុមមេធាវីការពារក្តីចំពោះធនធានរបស់ផ្នែកការពារក្តី ចំពោះអ្នកបកប្រែធ្វើការពេញម៉ោង ដែលត្រូវបានចាត់តាំងដូចនៅក្នុងសេចក្តីសម្រេចទាក់ទងនឹងការបកប្រែភាសា និងចំពោះការខិតខំប្រឹងប្រែងរបស់ផ្នែកគ្រប់គ្រងតុលាការ ដើម្បីផ្តល់នូវសេវាបកប្រែឯកសារអោយបានទាន់ពេលវេលា"។[25]

**ការបកប្រែឯកសារជាភាសារបស់មេធាវីការពារក្តីជនត្រូវចោទ**

សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានគូសបញ្ជាក់ជាពិសេសថា ដីកាស្តីពីការបកប្រែបានរំលោភទៅលើសិទ្ធិរបស់ជនត្រូវចោទនូវសិទ្ធិទទួលបានជំនួយផ្លូវច្បាប់ប្រកបដោយប្រសិទ្ធិភាព។ មាត្រា ៣៥ ថ្មី នៃច្បាប់ អ.វ.ត.ក និងវិធាន ២២(១) នៃវិធានផ្ទៃក្នុង ផ្តល់សិទ្ធិឱ្យជនត្រូវចោទ "ជ្រើសរើសយកមេធាវីខ្មែរ ឬក៏មេធាវីបរទេស ដោយសហការជាមួយមេធាវីខ្មែរមកធ្វើជាតំណាងរបស់ខ្លួន"។[26] ដីកាស្តីពីការបកប្រែមិនបានផ្តល់នូវការបកប្រែសំណុំរឿងអោយទៅជាភាសារបស់សហមេធាវីអន្តរជាតិដែលអាចយល់បាន។ សហមេធាវីអន្តរជាតិរបស់ជនត្រូវចោទមិនអាចចូលរួមដើម្បីការពារជនត្រូវចោទ មានន័យថាលោក ខៀវ សំផន ត្រូវបានបាត់បង់សិទ្ធិរបស់គាត់ក្នុងការទទួលបាននូវជំនួយពីសំណាក់សហមេធាវីរបស់គាត់។[27]

ម្យ៉ាងវិញទៀត, សហមេធាវីបានបញ្ជាក់ថា អ.វ.ត.ក មានលក្ខណៈជាតុលាការចម្រុះ " គោលដៅនៃភាពចម្រុះនេះ គឺធានាឲ្យមាននីតិវិធីមួយប្រកបដោយយុត្តិធម៌ និងគោរពធ្វើតាមបទដ្ឋានអន្តរជាតិ ដោយរក្សានូវអធិបតេយ្យភាពនៃប្រទេសកម្ពុជា នៅក្នុងការជំនុំជម្រះដែលកំពុងដំណើរការ។ វិធាននេះត្រូវបានអនុវត្តនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ហើយវិធាននេះត្រូវបានគោរពក្នុងការតែងតាំងចៅក្រមផងដែរ។ ការអនុវត្តចំពោះក្រុមការពារក្តី មិនអាចខុសពីការអនុវត្តនេះទេ ដែលថាលោក ខៀវ សំផន មានសិទ្ធិទទួលបាននូវជំនួយពេញលេញ និងទាំងស្រុងពីសំណាក់មេធាវីទាំងពីររបស់ខ្លួន ហើយលោកក៏មានសិទ្ធិទទួលនូវអត្ថប្រយោជន៍នៃការពិគ្រោះការងាររបស់ពួកគាត់ដែរ"។[28]

សហព្រះរាជអាជ្ញាបានឆ្លើយតបថា "ជាក់ស្តែង គឺមិនមានលិខិតុបករណ៍អន្តរជាតិណាមួយ ដែលធានាថាគ្រប់ឯកសារទាំងអស់នៅក្នុងសំណុំរឿងរបស់ជនត្រូវចោទ ត្រូវបានបកប្រែទៅជាភាសារបស់មេធាវីការពារក្តីរបស់ជនត្រូវចោទនោះទេ[...] , សហព្រះរាជអាជ្ញា បានធ្វើសេចក្តីសន្និដ្ឋានថា ដើមបណ្តឹងឧទ្ធរណ៍មិនមានសិទ្ធិ

[25] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៣៩។

[26] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៥០ និង ៥៩ ក្រមសីលធម៌មេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង HRC case, *Pinto v. Trinidad and Tobago*, No 232/1987

[27] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៥៨ និង ៦០។

[28] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៥៧។

របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង

00243314

A190/I/14
០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១១)

បែបនេះ មកប្រើដើម្បីតវ៉ាទាមទារអំពីការមានមេធាវីតំណាង ដោយមិនមានប្រសិទ្ធិភាពបានឡើយ”។[29] បន្ថែមលើសពីនេះទៀត ដីកាស្តីពីការបកប្រែការពារសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបាននូវសិទ្ធិតំណាងដោយប្រសិទ្ធិភាព:

“ថ្វីត្បិតតែមិនមានការទទួលស្គាល់អំពីសិទ្ធិ ដែលត្រូវមានឯកសារនានាជាភាសារបស់មេធាវីការពារក្តីអន្តរជាតិក៏ដោយ ក៏នៅពេលដែលគាត់មិនចេះនិយាយភាសារបស់ចុងចោទនោះ សេចក្តីសម្រេចទាក់ទងនឹងការបកប្រែនេះ បានព្យាយាមបង្កើតជាយន្តការមួយសម្រាប់ក្រុមមេធាវីការពារក្តីនានា ដើម្បីទទួលបានសេវាបកប្រែភ្លាមៗនូវឯកសារនានា ឱ្យទៅជាភាសាផ្សេងៗក្រៅពីភាសាខ្មែរ។ សេចក្តីសម្រេចនេះ បានចែងអំពីតម្រូវការបុគ្គលិកបន្ថែមដែលត្រៀមសម្រាប់តែបកប្រែដើម្បីធានាអោយប្រាកដថា ឯកសារអ្វីក៏ដោយដែលត្រូវឱ្យធ្វើការបកប្រែជាប្រញាប់ ឬដោយឥតបានគ្រោងទុក អាចមាននៅទីឯកន្លែងស្រាប់ ដោយសារមានជំនួយពីអ្នកបកប្រែសរសេរដោយមិនគិតកម្រៃដែលមានស្រាប់នៅនឹងកន្លែង”។[30]

## ខ) ប្រភេទឯកសារដែលត្រូវបកប្រែ

ទោះបីសហមេធាវីជនត្រូវចោទ និងសហព្រះរាជអាជ្ញាយល់ស្របថា ជនត្រូវចោទមានសិទ្ធិមួយចំនួនក្នុងការទទួលបានឯកសារដែលបានបកប្រែជាភាសាខ្លួនយល់ក៏ដោយ ក៏ពួកគេមិនយល់ស្របត្រង់ថា ឯកសារអ្វីខ្លះដែលដាច់ខាតត្រូវតែបកប្រែទៅជាភាសាណាមួយ។ សហមេធាវីការពារក្តីបានគូសបញ្ជាក់ថា ជនត្រូវចោទមានសិទ្ធិទទួលបានការបកប្រែឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿង ទៅជាភាសាសហមេធាវីអន្តរជាតិរបស់ខ្លួន។[31] សហព្រះរាជអាជ្ញាផ្តល់ទឡ្ហីករណ៍ថា ឯកសារខ្លះ តែមិនមែនឯកសារទាំងអស់ទេ ដែលមាននៅក្នុងសំណុំរឿងដាច់ខាតត្រូវតែបកប្រែ គឺមានតែការបកប្រែទៅជាភាសារបស់ជនត្រូវចោទតែប៉ុណ្ណោះ។[៣២]

### ភស្តុតាងដោះបន្ទុក

សហមេធាវីជនត្រូវចោទបានលើកឡើងជាក់លាក់ថា “គ្មានអ្វីដែលអាចធានាថា សហចៅក្រមស៊ើបអង្កេតនឹងធ្វើបច្ចុប្បន្នកម្ម ហើយនឹងធ្វើការពិនិត្យទៅលើភស្តុតាងដោះបន្ទុកទាំងអស់ ដែលមាននៅក្នុងសំណុំរឿងស៊ើបអង្កេតនោះទេ”។[33]

---

[29] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៤០។

[30] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៤២។

[31] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៥៩។

[32] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៣១។

[33] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៦៣។

00243315

A190/I/14
០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១១)

សហព្រះរាជអាជ្ញាមិនបានឆ្លើយតបដោយផ្ទាល់ទៅនឹងបញ្ហានេះទេ ប៉ុន្តែបានសន្និដ្ឋានថា "ឯកសារនានាដែលមានស្រាប់ជាភាសាខ្មែរ និងឯកសារទាំងឡាយដែលបានបង្គាប់ឲ្យផ្តល់ជាភាសាខ្មែរនៅក្នុងសេចក្តីសម្រេចស្តីពីការបកប្រែ បានរំលេចឲ្យឃើញពីរបបមួយដែលមានលក្ខណៈសេរីបំផុត ក្នុងការបង្ហាញឯកសារដែលតុលាការ ICTY និង ICTR បានប្រកាន់យក"។[34]

## ខ) ភារកិច្ចរបស់ភាគីដើម្បីសហការក្នុងដំណើរការបកប្រែ

សហមេធាវីជនត្រូវចោទបានជំទាស់ផងដែរអំពីតម្រូវការនៃដីកាបកប្រែ ដែលថាមេធាវីការពារក្តីត្រូវសហការយ៉ាងពេញទំហឹងជាមួយនឹងដំណើរការបកប្រែ។ នៅក្នុងគំនិតរបស់សហមេធាវីការពារក្តីយល់ថា វាមិនមានមូលដ្ឋានគ្រឹះផ្នែកច្បាប់ណាមួយ ដើម្បីនឹងដាក់កំហិតកាតព្វកិច្ចបែបនេះ ដល់ក្រុមការពារក្តី និងជនត្រូវចោទនោះទេ និងវិធានការដែលចែងនៅក្នុងដីកាស្តីពីការបកប្រែបានរំលោភបំពានទៅលើករណីកិច្ចរបស់មេធាវី ក្នុងការថែរក្សាភាពសម្ងាត់នៃវិជ្ជាជីវៈ។[35]

"ការបញ្ជូនទៅផ្នែកគ្រប់គ្រងតុលាការ (ទៅសហចៅក្រមស៊ើបអង្កេត នៅក្នុងករណីមានជម្លោះ) នូវបញ្ជីឯកសារដែលខ្លួនយល់ថាមានភាពជាអាទិភាពសម្រាប់ក្រុមការពារក្តី ហើយដែលបន្ថែមពីលើបញ្ជីនោះ មានហេតុផលនៃការស្នើសុំបកប្រែ និងជាពិសេសនោះមានការបញ្ជាក់អំពីភាពត្រឹមត្រូវស្តីពីលំដាប់នៃអាទិភាព បង្កើតបានជាការរំលោភបំពានយ៉ាងជាក់ច្បាស់ទៅលើករណីកិច្ចនេះ ព្រមទាំងជាការប៉ះពាល់ដល់ឯកសិទ្ធិនៃភាពមិនអាចរំលោភបំពានបានទៅលើគ្រប់ឯកសារទាំងអស់របស់មេធាវី"។[36]

សហព្រះរាជអាជ្ញាមិនបានឆ្លើយតបដោយផ្ទាល់ទៅនឹងបញ្ហានេះទេ ប៉ុន្តែបានសន្និដ្ឋានថា ដីកាស្តីពីការបកប្រែ ផ្តល់នូវការបកប្រែឯកសារសំខាន់ៗ ស្របទៅនឹងឯកសារដែលគេទាមទារអោយមានការបកប្រែ ដូចបណ្តាសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិនានា។[37] វិធានការនៅក្នុងដីកាស្តីពីការបកប្រែ អនុញ្ញាតអោយក្រុមមេធាវីការពារក្តីស្នើសុំបកប្រែផ្សេងទៀតក្រៅពីឯកសារសំខាន់មួយចំនួនដោយផ្អែកទៅលើមូលដ្ឋាននៃបញ្ជីរួម និងដែលបានកំណត់អំពីអាទិភាពនៃឯកសារបន្ទាន់។[38]

---

[34] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៣៦។

[35] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៤១-៤២។

[36] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៤២។

[37] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៣៧។

[38] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៣៧។

របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង

00243316

A190/I/14
00២/១៩-0៩-២00៧-អវតក-កសចស (អបជ១១)

ឌ) **ការដោះលែងជនត្រូវចោទ**

សមេធាវីជនត្រូវចោទបានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ថា ការរំលោភបំពានលើទ្រឹស្តីនៃដំណើរការនីតិវិធី បានអនុវត្តទៅលើស្ថានភាពរបស់លោក ខៀវ សំផន។ ជនត្រូវចោទបានទទួលរងនូវការរំលោភបំពានសិទ្ធិ យ៉ាងច្រើន រហូតដល់កំរិតមួយដែលមិនអាចធានាសិទ្ធិរបស់ជនត្រូវចោទទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយជនត្រូវចោទ គួរតែត្រូវបានដោះលែងភ្លាមៗ និងដោយគ្មានលក្ខខណ្ឌ។[39]

សហព្រះរាជអាជ្ញាបានឆ្លើយតបថា ចាប់តាំងពីការចេញដីកាស្តីពីការបកប្រែ វាមិនបានរំលោភបំពានសិទ្ធិរបស់ជនត្រូវចោទទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងគ្មានការរំលោភបំពានទៅលើនីតិវិធី ហើយជនត្រូវចោទក៏មិនត្រូវបានដោះលែងផងដែរ។[40]

ភ្នំពេញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៨

**សហចៅក្រមរបាយការណ៍**

**ចៅក្រម ន៉ីយ ថុល** ចៅក្រម Katinka LAHUIS

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

[39] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៧៥, ៨០។

[40] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៥៧។

រកាអរការណ៍ស្តីពីការរកឃើញពិតនៃដំណើររឿង

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ការិយាល័យសហព្រះរាជអាជ្ញា**
Extraordinary Chambers in the Courts of Cambodia
Office of the Co-Prosecutors

ភ្នំពេញថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៨

## សេចក្តីថ្លែងការណ៍របស់ការិយាល័យសហព្រះរាជអាជ្ញា

នៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០៨ ដោយអនុលោមតាមវិធានផ្ទៃក្នុង៧១(២) នៃតុលាការនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ សេចក្តីថ្លែងអំពីការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញាទាំងពីរ រួចបញ្ជូនទៅការិយាល័យរដ្ឋបាលដើម្បីទទួលការសម្រេចសេចក្តីពីសំណាក់ អង្គបុរេជំនុំជម្រះ។ ការខ្វែងគំនិតគ្នានេះ ស្ថិតនៅលើភាពសមស្របនៃការបើកកិច្ចស៊ើបអង្កេតថ្មីតាមផ្លូវតុលាការទៅលើឧក្រិដ្ឋកម្មទាំងឡាយ ដែលប្រព្រឹត្តឡើងនៅតាមបណ្តាទីតាំងនានាទូទាំងប្រទេសកម្ពុជាដោយជនមួយចំនួនដែលត្រូវបានចាត់ទុកជាមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ឬជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មក្រោមរបបនោះ។។ ការិយាល័យរដ្ឋបាលបានទទួល និងជូនដំណឹងដល់អង្គបុរេជំនុំជម្រះអំពីការខ្វែងគំនិតគ្នានេះដើម្បីធ្វើការសម្រេចសេចក្តី។ ការិយាល័យរដ្ឋបាលបានបញ្ជូនសំណុំរឿងនេះទៅអង្គបុរេជំនុំជម្រះ។

កិច្ចស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញា និង ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះទៅលើវិវាទរវាងសហព្រះរាជអាជ្ញាទាំងពីរ តាមច្បាប់ គឺជាការសម្ងាត់ ។ ប្រការនេះគឺឈរលើគោលការណ៍សច្ចធារណ៍នៃនិរទោស ការការពារជនរងគ្រោះ និង សាក្សី និងជាពិសេសបំផុតគឺការពារបូរណភាពនៃដំណើរការស៊ើបអង្កេត ។

សហព្រះរាជអាជ្ញាត្រូវតែខិតខំពុះពារសម្រេចឱ្យបាននូវការព្រមព្រៀងគ្នាមួយពេញអំឡុងនៃដំណើរការទាំងមូលនៃការសម្រេច តាមផ្លូវតុលាការទៅលើការខ្វែងគំនិតគ្នានេះ។ ដោយមិនគិតអំពីលទ្ធផលនៃការខ្វែងគំនិតគ្នានេះ សហព្រះរាជអាជ្ញាបាន និងងបន្តធ្វើការជាមួយគ្នាគ្រប់សំណុំរឿងទាំងអស់ដើម្បីធានាឱ្យប្រាកដថា យុត្តិធម៌ពិតជាបានផ្តល់ដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ៕

-ចប់-

ទំព័រ១ នៃទំព័រ១

# ការពិភាគទៅលើអំពើពុករលួយ ភាពលម្អៀង និងសេចក្តីសន្និដ្ឋាននៃភាពមិនលម្អៀងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

*សហគមន៍អន្តរជាតិទទួលស្គាល់ថា ជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មមានសិទ្ធិទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ ឯករាជ្យ និងភាពមិនលម្អៀង ។ គោលការណ៍នេះបង្កើតបានជាមូលដ្ឋាននៃប្រជាធិបតេយ្យ ហើយនេះគឺជាតួនាទីរបស់តុលាការក្នុងការជំរុញឲ្យមានភាពជឿជាក់នៅក្នុងការកាត់សេចក្តីក្នុងសង្គមប្រជាធិបតេយ្យដោយគោរពតាមគោលការណ៍ទាំងនេះ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាន់ខ្ជាប់គោលការណ៍បែបនេះចាប់តាំងពីថ្ងៃចាប់កំណើតរបស់ខ្លួន ។ «ដំណើរការនីតិវិធីនៃអង្គជំនុំជម្រះត្រូវតែមានយុត្តិធម៌និងគោរពគោលការណ៍ចំពោះមុខ ព្រមទាំងរក្សានូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងពីរ» ។ ជនទាំងឡាយ «ត្រូវបានចាត់ទុកថា គ្មានទោសដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ» ។ ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវដកខ្លួនចេញ ក្នុងករណីដែលចៅក្រមនោះមានឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការជាប់ពាក់ព័ន្ធដែលអាចប៉ះពាល់ដល់ភាពមិនលម្អៀង ឬ «បង្កើនឲ្យមានភាពលម្អៀង» ។*

*ក្រៅពីគោលការណ៍ទាំងនេះ ការពិនិត្យសាឡើងវិញទៅលើព្រឹត្តិការណ៍របស់តុលាការ និងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះធ្វើឲ្យមានការសង្ស័យថាតើប្រវត្តិសាស្ត្រអាចបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងការវិនិច្ឆ័យដោយរបៀបណា? តុលាការទាំងអស់តែងតែទទួលបាននូវការរិះគន់ទាក់ទងទៅនឹងឯករាជ្យភាព និងភាពមិនលម្អៀង ។ ការរិះគន់ដ៏ត្រឹមត្រូវគឺជាលក្ខណៈទូទៅនៃប្រជាធិបតេយ្យ ។ ដោយយោងទៅតាមគោលការណ៍នេះ អត្ថបទនេះនឹងវិភាគទៅលើចំណុចទូទៅបីទាក់ទងទៅនឹងការព្រួយបារម្ភចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ១) អំពើពុករលួយ, ២) ភាពលម្អៀង និង ៣) សេចក្តីសន្និដ្ឋាននៃភាពមិនលម្អៀងដែលតុលាការនិងចៅក្រមអះអាងដោយសម្អាងលើហេតុផលនៃការធ្វើសច្ចាប្រណិធាននិងលក្ខណៈសម្បត្តិរបស់ចៅក្រម ។*

### ១) អំពើពុករលួយ

*ការចោទប្រកាន់ពីអំពើពុករលួយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបណ្តាលឲ្យមានការព្រួយបារម្ភជាខ្លាំងដែលតម្រូវឲ្យសហគមន៍អន្តរជាតិនិងរដ្ឋាភិបាលកម្ពុជាធ្វើការយកចិត្តទុកដាក់ ។*

*វប្បធម៌នៃការគោរពច្បាប់កម្ពុជាគឺជាចំណុចចាប់ផ្តើមនៃការព្រួយបារម្ភ ។ សព្វថ្ងៃនេះនៅតែមានការចោទប្រកាន់ និងការព្រួយបារម្ភច្រើនទៅលើអំពើពុករលួយផ្នែកប្រព័ន្ធច្បាប់ក្នុងប្រទេសកម្ពុជា ។ យោងតាមអង្គការ Transparency International Corruption Perception (TICP) ដែលមានទីតាំងនៅទីក្រុងប៊ែកឡាំង បានឲ្យដឹងថា ក្នុងចំណោមប្រទេសចំនួន១៨០ប្រទេសកម្ពុជាជាប់ចំណាត់លេខ១៦៣ ហើយក៏ជាប្រទេសមួយក្នុងចំណោមប្រទេសដែលអំពើពុករលួយមានកម្រិតខ្ពស់ក្នុងជួររដ្ឋាភិបាល ។ ដោយកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ហើយទើបតែរួចផុតពីសង្គ្រាម ដូច្នេះនេះមិនគួរឲ្យភ្ញាក់ផ្អើលអ្វីទេ ។ ប្រភពមួយអះអាងថាយុត្តិធម៌នៃអំពើឧក្រិដ្ឋកម្មធ្វើឡើងបានតាមរយៈថវិកាជាតិមួយចំណែក ហើយចៅក្រមទទួលបានតែ២០ដុល្លារប៉ុណ្ណោះក្នុងមួយខែ ។*

*វាមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ដែលឥទ្ធិពលនៃអំពើពុករលួយបែបនេះអាចប៉ះពាល់ដល់ការជឿទុកចិត្តរបស់សាធារណជនចំពោះប្រព័ន្ធច្បាប់ ។ យោងតាមការសិក្សារបស់ធនាគារពិភពលោក នៅពេលដែលប្រជាជនមានទំនាក់ទំនងជាមួយតុលាការមានឱកាស៦៨ភាគរយដែលប្រជាជនទាំងនោះអាចធ្វើការសូក*

ប៉ាន់ ។ ឈ្មួញកណ្តាលបានបង្កើតអាជីវកម្មសម្រាប់ជួយឲ្យដើមបណ្តឹងនៅក្នុងតុលាការកម្ពុជាកាន់តែមានតម្លៃក្នុងការសូកប៉ាន់ ។

អំពើពុករលួយនៅក្នុងប្រទេសកម្ពុជាអាចធ្វើឡើងបានតាមរយៈមធ្យោបាយជាច្រើន ។ បុគ្គលិក តុលាការ និងចៅក្រមអាចទទួលបានមុខតំណែងដោយសារតែអ្នកទាំងនោះបានយល់ព្រមផ្តល់ប្រាក់ទៅឲ្យអ្នកជួយឲ្យគេឡើងកាន់តំណែង ។ អ្នកដែលចង់បានតំណែងក្នុងជួររដ្ឋាភិបាលផ្តល់ប្រាក់ទៅឲ្យភាគីទីបីឬភ្នាក់ងារដែលត្រូវការបុគ្គលិកដើម្បីទិញមុខតំណែងនោះ ។ កាតព្វកិច្ចហិរញ្ញវត្ថុកើតឡើងមិនដូចការ រវាងអ្នកចង់បានការងារ និងអ្នកត្រូវការបុគ្គលិកឬភាគីទីបី ហើយពេលខ្លះវាចំណាយពេលយូរដោយអាស្រ័យទៅលើប្រភេទនៃការងារ និងស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកចង់បានការងារ ។ ការធ្វើបែបនេះធ្វើឲ្យមានបញ្ហាធ្ងន់ធ្ងរមួយចំនួននៅក្នុងប្រព័ន្ធច្បាប់ទាំងមូល ។ ទោះបីជាវាមិនប៉ះពាល់ដល់ឯករាជ្យភាពរបស់អង្គជំនុំជម្រះ តែយ៉ាងហោចណាស់ក៏ប៉ះពាល់ដល់ការយល់ឃើញរបស់សាធារណជនដែរ ។

នៅឆ្នាំ២០០៦ មានការចោទប្រកាន់ថា បុគ្គលិកកម្ពុជាកំពុងត្រូវបានបង្ខំឲ្យផ្តល់ប្រាក់ខែរបស់ខ្លួនទៅឲ្យប្រធាន ។ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ កាសែតសំឡេងយុវជនខ្មែរបានបោះពុម្ពអត្ថបទជាភាសាខ្មែរដោយនិយាយថា «មន្ត្រីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារួមទាំងចៅក្រមបានផ្តល់៣០ភាគរយនៃប្រាក់ខែរបស់ខ្លួនទៅឲ្យមន្ត្រីរដ្ឋាភិបាលដើម្បីធានាមុខតំណែងរបស់ខ្លួន» ។ នៅឆ្នាំ២០០៧ អង្គការសហប្រជាជាតិឲ្យក្រុមហ៊ុនសវនកម្មដែលមានទីតាំងនៅប្រទេសម៉ាឡេស៊ីដឹកនាំការធ្វើសវនកម្មផ្ទៃក្នុងដែលដំណើរការចាប់ពីខែមករាដល់ខែមីនា ។ របាយការណ៍សវនកម្មផ្ទៃក្នុងត្រូវបានផ្តល់ឲ្យភាគីកម្ពុជា ប៉ុន្តែមិនត្រូវបានបោះពុម្ពផ្សាយ លើកលែងតែក្នុងករណីចាំបាច់ ។ ដោយការចោទប្រកាន់ទៅលើការចំណាយទាក់ទងនឹងបុគ្គល ហើយវាហួសពីយុត្តាធិការរបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ គេក៏បានបញ្ឈប់ការស៊ើបអង្កេត ។ ជាងនេះទៅទៀត កម្មវិធីនេះធ្វើឡើងដើម្បីអភិវឌ្ឍន៍ដំណើរការនីតិវិធី និងការគ្រប់គ្រងធនធានមនុស្សរបស់បុគ្គលិកកម្ពុជា ។ កម្មវិធីនេះបានបញ្ជូនលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួនទៅឲ្យអាជ្ញាធរកម្ពុជា ។

បន្ទាប់មក កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិបានអះអាងថា «មិនធ្លាប់មានបញ្ហាអ្វីទាក់ទងនឹងការគ្រប់គ្រងធនធានហិរញ្ញវត្ថុនៅអង្គជំនុំជម្រះឡើយ» ។ ព្រមទាំងបន្ថែមទៀតថា អង្គជំនុំជម្រះមិនធ្លាប់មាន «ចលាចលហិរញ្ញវត្ថុគួរឲ្យសង្ស័យ ការបែងចែកធនធានមិនត្រឹមត្រូវ ហើយក៏មិនមានឯកសារមិនពេញលេញ ឬបាត់បង់ពាក់ព័ន្ធនឹងការចំណាយរបស់អង្គជំនុំជម្រះនោះទេ» ។ យ៉ាងណាមិញ បញ្ហាចម្បងដែលអ្នកធ្វើសវនកម្មរកឃើញនោះគឺៈ

១) បុគ្គលិកដែលបានជ្រើសរើសមិនស័ក្តិសមនឹងតម្រូវការ

២) អត្រាឆ្លើយតបនឹងសេចក្តីប្រកាសស្វែងរកការងារមានលក្ខណៈទាប

៣) ការជ្រើសរើសបេក្ខភាព និងបទសម្ភាសន៍បេក្ខជនមិនបានចងក្រងជាឯកសារច្បាស់លាស់

៤) ភាពមិនសមស្របក្នុងការជ្រើសរើសបេក្ខជន

៥) ដំណើរការវាយតម្លៃការអនុវត្តការងារនៅខ្សោយ

៦) ប្រាក់ខែរបស់បុគ្គលិកជាតិនៅអង្គជំនុំជម្រះខ្ពស់

៧) អ្នកគ្រប់គ្រងគម្រោងត្រួតពិនិត្យនិងគ្រប់គ្រងការងារដោយមិនមានប្រសិទ្ធភាព

*Open Society Justice Initiative (OSJI)* ជាអង្គការក្រៅរដ្ឋាភិបាលដែលធ្វើសេចក្តីរាយការណ៍អំពីអង្គជំនុំជម្រះបានស្នើឲ្យមានការស៊ើបអង្កេតទៅលើការចោទប្រកាន់ថាមានអំពើពុករលួយ ។ យោងទៅតាម (OSJI) លោក ស៊ាន វិសុទ្ធ ប្រធានផ្នែករដ្ឋបាលនៃអង្គជំនុំជម្រះបានឆ្លើយតប ដោយហាមឃាត់មិនឲ្យមន្ត្រីរបស់ (OSJI) នៅការិយាល័យរបស់លោក ។

នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៨ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិបានអះអាងថាខ្លួនបានបិទថវិកាសម្រាប់ប្រតិបត្តិការ និងប្រាក់ខែបុគ្គលិកកម្ពុជានៅអង្គជំនុំជម្រះខណៈពេលដែលមានការចោទប្រកាន់ថាមានការសូកប៉ាន់ ។ ការចោទប្រកាន់ត្រូវបានបញ្ជូនទៅមន្ត្រីអង្គការសហប្រជាជាតិនៅកម្ពុជា និងត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យអង្គការសហប្រជាជាតិនិងភ្នាក់ងារស៊ើបអង្កេត ។ បន្ទាប់មកនៅថ្ងៃទី១៣ ខែសីហា លោក កែវ ធីរិទ្ធ ប្រធានបុគ្គលិកកម្ពុជាត្រូវបានដកចេញពីតំណែង ។ លោក រាជ សម្បត្តិ អ្នកនាំពាក្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អះអាងថា «លោក កែវ ធីរុទ្ធ ត្រូវបានផ្លាស់ប្តូរទៅធ្វើការនៅក្រុមប្រឹក្សារដ្ឋមន្ត្រីវិញ» ហើយលោកបដិសេធមិនធ្វើសេចក្តីអធិប្បាយបន្ត ។ អ្នកស្រី ហេឡែន ចាវីស អ្នកនាំពាក្យការិយាល័យរដ្ឋបាលភាគីកម្ពុជាបានអះអាងថា នេះគឺជាទម្លាប់ ហើយបានស្នើថា យើងមិនអាចធ្វើអ្វីពាក់ព័ន្ធការចោទប្រកាន់នៅពេលថ្មីៗនេះបានទេ ។

នៅថ្ងៃទី១៩ ខែសីហា លោក ស៊ាន វិសុទ្ធ មន្ត្រីរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកកិច្ចការអង្គជំនុំជម្រះបានសន្យាថានឹងលាលែងពីតំណែងប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានអំពើពុករលួយ ។ ទោះបីជាមន្ត្រីកម្ពុជាសុទ្ធតែបដិសេធនឹងការចោទប្រកាន់ថាមានអំពើពុករលួយ ហើយអង្គជំនុំជម្រះបានបង្កើតកិច្ចការសម្រាប់ត្រួតពិនិត្យក៏ដោយ ប៉ុន្តែបញ្ហានៅតែមិនទាន់បានដោះស្រាយទាំងស្រុងនៅឡើយ ។ តាមការពិត បញ្ហាអំពើពុករលួយកាន់តែមានសភាពធ្ងន់ធ្ងរដែលប៉ះពាល់ដល់ភាពយុត្តិធម៌ ឯករាជ្យភាព ភាពមិនលម្អៀងរបស់តុលាការ ព្រមទាំងការយល់ឃើញរបស់សាធារណជន ។ អាជ្ញាធរកម្ពុជាបានស្នើថា ពាក្យបណ្តឹងដំបូងគួរតែប្រគល់ឲ្យ «អាជ្ញាធរមានសមត្ថកិច្ច» នៅកម្ពុជាដើម្បីធ្វើការស៊ើបសួរជាជាងធ្វើការស៊ើបអង្កេតទៅលើការចោទប្រកាន់នោះ ។ ការទាស់ទែងគ្នាដើម្បីផលប្រយោជន៍នៅក្នុងស្ថានភាពនេះក៏មានសារសំខាន់ដែរ ពីព្រោះអ្នកនៅក្រោមបញ្ជានឹងចង្អុលបង្ហាញថា នរណាជាអ្នកបញ្ជាអ្នកទាំងនោះប្រហែលជាមានមុខតំណែងខ្ពស់នៅក្នុងជួររដ្ឋាភិបាល ។

ចៅក្រមរបស់អង្គជំនុំជម្រះទទួលស្គាល់ភាពធ្ងន់ធ្ងរនៅក្នុងស្ថានភាពនេះ ។ នៅក្នុងការប្រជុំរៀបចំគម្រោង ស៊ីលវៀ ខារ៉ាយ ចៅក្រមមកពីប្រទេសញូវហ្សឺលែននិយាយថា តុលាការមិនគួរចំណាយពេលដោះស្រាយបញ្ហាអំពើពុករលួយដែលមិនទាន់កើតមាននោះទេ ។ ខារ៉ាយ រៀបរាប់ថា អំពើពុករលួយគឺជា «បញ្ហាសំខាន់មួយដែលបានរំខានដល់ចៅក្រមទាំងអស់» ។

បញ្ហាសំខាន់ជាងគេបំផុតដែលមិនសូវមានគេយកមកនិយាយគឺការចោទប្រកាន់ថា ចៅក្រមកម្ពុជាដែលត្រូវបានជ្រើសតាំងជាចៅក្រមនៅអង្គជំនុំជម្រះបានសារភាពថា ខ្លួនធ្លាប់ទទួលសំណូកមុនពេលត្រូវបានជ្រើសតាំង ។ នៅក្នុងកម្មវិធីផ្សព្វផ្សាយសាធារណៈមួយ អ្នកសារព័ត៌មានម្នាក់អង្គុយជាមួយចៅក្រម នីល ណុន ។ «លោក នីល ណុន សារភាពថា គាត់បានទទួលសំណូក ប៉ុន្តែវាកើតឡើងក្រោយពីករណីសំណុំរឿងនោះបានបញ្ចប់ទេ ។ លោក នីល ណុន រកបានត្រឹម៣០ដុល្លារក្នុងមួយខែតែប៉ុណ្ណោះ វាស្ទើតែមិនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារផង ។ «តើគាត់នឹងធ្វើអ្វីទៀត» ?

ខណៈពេលដែលការចោទប្រកាន់ពីអំពើពុករលួយនៅអង្គជំនុំជម្រះនៅមិនទាន់បានកំណត់ ស្ថានភាពនៅជុំវិញអង្គជំនុំជម្រះដូចជាការអះអាងដដែលៗគឺជាបញ្ហាគួរតែយកចិត្តទុកដាក់ ។ អង្គជំនុំជម្រះមិនត្រូវស៊ើបអង្កេតតែទៅលើបញ្ហានេះទេ គួរតែបង្កើតវិធីសាស្ត្រត្រួតពិនិត្យដោយឯករាជ្យនិងមានតម្លាភាពដើម្បីការពារកុំឲ្យមានបញ្ហាបែបនេះកើតឡើងម្តងទៀត ។ ការធ្វើឲ្យមានតម្លាភាពយ៉ាងហោចណាស់ក៏អាចធ្វើឲ្យការព្រួយបារម្ភមិនក្លាយទៅជាបញ្ហាធ្ងន់ធ្ងរដែលប៉ះពាល់ដល់អង្គជំនុំជម្រះនៅពេលចាប់ផ្តើមកាត់ទោស ។

## ២) ភាពលម្អៀង

បញ្ហាជុំវិញអង្គជំនុំជម្រះនិងសេចក្តីសម្រេចថ្មីៗនេះបង្កឲ្យមានការវិភាគទៅលើអ្វីដែលធ្វើឲ្យប៉ះពាល់ដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ហើយថាតើអង្គជំនុំជម្រះនឹងដោះស្រាយបញ្ហាចៅក្រមដែលពាក់ព័ន្ធនឹងភាពលម្អៀងដោយរបៀបណា?

ចាប់តាំពីពេលចាប់ផ្តើម អង្គជំនុំជម្រះបានប្រឈមមុខនឹងបញ្ហាវប្បធម៌ច្បាប់កម្ពុជាដែលបណ្តាលឲ្យមានភាពលម្អៀងក្នុងការកាត់ក្តី ហើយខាងនីតិប្រតិបត្តិបានរាំងស្ទះសុឆន្ទៈ និងបំណងដែលធ្វើឲ្យប៉ះពាល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ អំណាចតុលាការនិងរដ្ឋាភិបាលទើបតែបំបែកជាពីរផ្នែកដាច់ពីគ្នាជាផ្លូវការនៅឆ្នាំ១៩៩៣ ។ លោក កូហ៊ី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិបាននិយាយពីការព្រួយបារម្ភរបស់លោកទៅលើអំណាចតុលាការរបស់កម្ពុជា ។

នៅពេលដែលរដ្ឋធម្មនុញ្ញកម្ពុជាបញ្ជូលឯករាជ្យភាពនៃអំណាចតុលាការ ព្រះមហាក្សត្រ និងស្ថាប័នមួយដែលមានឈ្មោះថាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកធានាទៅលើភាពឯករាជ្យនោះ ។ លោក ហ៊ុន សែន បានផ្លាស់ប្តូរស្ថាប័នឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៅពេលដែលលេខាធិការដ្ឋាននៃស្ថាប័ននេះត្រូវបានរំលាយ ហើយការគ្រប់គ្រងត្រូវដាក់ឲ្យស្ថិតនៅក្រោម

ក្រសួងយុត្តិធម៌ដែលមានសមាជិកម្នាក់មកពីគណបក្សប្រជាជនកម្ពុជា ។ លោកអគ្គលេខាធិការ កូហ្វី អាណាន់ បាននិយាយថា «...មានបញ្ហាជាច្រើនទាក់ទងនឹងវិធានច្បាប់កម្ពុជានិងការគ្រប់គ្រងប្រព័ន្ធតុលាការដែលបផ្អាក់ដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការ...» ។

រដ្ឋាភិបាលប្រហែលជាអាចប្រើប្រាស់អង្គជំនុំជម្រះជាវិធីសាស្ត្រដើម្បីធានាឲ្យមានការគាំទ្រពីអតីតមេដឹកនាំខ្មែរក្រហមដែលធ្វើការជាមួយរដ្ឋាភិបាល ។ ការផ្តល់មុខតំណែងនៅក្នុងជួររដ្ឋាភិបាលទៅឲ្យអតីតខ្មែរក្រហមហាក់ដូចជាមានភាពមិនត្រឹមត្រូវ ។ ដោយមន្ត្រីរដ្ឋាភិបាលជាច្រើនមានជាប់ពាក់ព័ន្ធនឹងរបប ប៉ុល ពត ដូច្នេះរដ្ឋាភិបាលកម្ពុជាមិនមានការចាប់អារម្មណ៍ខ្លាំងទៅលើការស៊ើបអង្កេតនិងលទ្ធផលបន្ទាប់នៃការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយការពិតប្រហែលជាធ្វើឲ្យបុគ្គលទាំងនោះមានភាពអាម៉ាស់ ។ ខណៈពេលដែលចំណុចនេះបង្កើតឲ្យមានការព្រួយបារម្ភ ហើយអង្គជំនុំជម្រះកំពុងប្រឈមមុខនឹងការចោទប្រកាន់ពីអំពើពុករលួយ គ្មានអ្នកណាម្នាក់អាចជួយដោះស្រាយបញ្ហានេះ ហើយគេបែរជាមានចម្ងល់ថាតើបញ្ហាទាំងនេះគឺជាការពិតមែនឬ ។

មន្ត្រីអង្គការសហប្រជាជាតិមួយចំនួនយល់ស្របនឹងបញ្ហានេះ ។ «នៅពេលដែលគេសួរថាតើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាអាចផ្តល់ឯករាជ្យភាពដ៏មានយុត្តិធម៌ដែរឬទេ? លោក ហែន ខូរ៉ែល ទីប្រឹក្សាច្បាប់ និងជាអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់បានមានប្រសាសន៍ថា «ក្នុងនាមខ្ញុំជាសមាជិកម្នាក់របស់អង្គការសហប្រជាជាតិ ខ្ញុំទទួលបន្ទុកធ្វើការចរចា ហើយខ្ញុំបានព្យាយាមឲ្យអស់ពីសមត្ថភាពដើម្បីធ្វើការចរចានេះ ។ យោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំគឺជាបញ្ហាផ្សេង» ។ នៅខែសីហា ឆ្នាំ២០០៧ អង្គការសហប្រជាជាតិបានបង្ហាញពីការព្រួយបារម្ភថា «ការជំរុញរបស់រដ្ឋាភិបាលកម្ពុជាដើម្បីលើកចៅក្រមម្នាក់ធ្វើជាប្រធានអាចប៉ះពាល់ដល់ប្រសិទ្ធភាពនិងឯករាជ្យភាពដ៏មានយុត្តិធម៌នៅក្នុងអង្គជំនុំជម្រះ ។

ការពិចារណាទៅលើចៅក្រមកម្ពុជាដែលជាប់ពាក់ព័ន្ធនឹងសង្គមកម្ពុជាក៏មានសារសំខាន់ដែរ ។ ចៅក្រមកម្ពុជានៅក្នុងអង្គជំនុំជម្រះប្រាកដជាគាំទ្រការកាត់ទោសឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងប្រទេសរបស់ខ្លួន ។ «យោងតាមទំហំនៃឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម វាប្រហែលជាមិនអាចស្វែងរកចៅក្រមដែលមិនមានភាពលម្អៀងទេ ។ ប្រសិនបើចៅក្រមនោះមិនមែនជាជនរងគ្រោះផ្ទាល់ ប៉ុន្តែគេក៏ប្រហែលជាមានមិត្តភក្តិឬសាច់ញាតិដែលជាជនរងគ្រោះដែរ» ។ របាយការណ៍ឆ្នាំ២០០៥បង្ហាញថា «ប្រជាជនកម្ពុជា៨១ភាគរយជួបប្រទះនឹងការធ្វើបាប ៤០ភាគរយមានជំងឺថប់អារម្មណ៍ ២៨.៤ភាគរយមានជំងឺបាក់ស្បាត និង១១.៥ភាគរយមានជំងឺអាកប្បកិរិយា ។

ដោយគិតទៅដល់ស្ថានភាពសង្គមកម្ពុជា តួនាទីរបស់តុលាការនិងការមានជាប់ពាក់ព័ន្ធនឹងរបបខ្មែរក្រហម អង្គបុរេជំនុំជម្រះបានយកចិត្តទុកដាក់ទៅលើការចោទប្រកាន់ពីភាពលម្អៀង ។ វាមិនត្រឹមត្រូវក្នុងការរិះគន់អង្គជំនុំជម្រះ ប៉ុន្តែវាត្រឹមត្រូវក្នុងការរិះគន់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការដោះស្រាយបញ្ហា ។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលមេធាវីការពារក្តីករណី នួន ជា ស្នើឲ្យដកចៅក្រម ន័យ ថុល ហាក់ដូចជាធ្វើឲ្យអង្គជំនុំជម្រះត្រូវតែពិចារណាទៅលើរឿងនេះទៀត ។ ការគ្រប់គ្រងនៅក្នុងស្ថានភាពនេះបង្កឲ្យមានការព្រួយបារម្ភខ្លះ ។

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ មេធាវីការពារក្តី នួន ជា បានដាក់ពាក្យបណ្តឹងជំទាស់ជាបន្ទាន់មួយដើម្បីដកសិទ្ធិចៅក្រម ន័យ ថុល ដោយសម្អាងទៅលើមូលហេតុមួយចំនួន ១) ឋានៈរបស់លោកជាមន្ត្រីនៅក្នុងកងយោធពលខេមរភូមិន្ទ ២) ការសម្តែងនូវសុឆន្ទៈរបស់លោកក្នុងការប្រើប្រាស់អំណាចតុលាការមិនសមស្រប ដោយធ្វើតាមការបង្គាប់បញ្ជារបស់គណបក្សប្រជាជន និង ៣) លោកជាសមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជន ។

នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបដិសេធនឹងពាក្យបណ្តឹងជំទាស់នោះដោយសម្អាងថា គ្មានការព្រួយបារម្ភទៅលើភាពលម្អៀងពីសំណាក់អ្នកអង្កេតដែលបានដឹងរាល់បញ្ហាដែលទាក់ទងនឹងចៅក្រមដែលមានបញ្ហាទេ ។ អង្គជំនុំជម្រះបានសន្មតទុកជាមុននូវការដាក់បន្ទុកលើ «ភាពលម្អៀងពិតប្រាកដ» ដោយយោងទៅតាមកាលៈទេសៈថាវាហាក់ដូចជាមិនសមស្របថាមិនមានភាពលម្អៀងដែលមើលឃើញពីខាងក្រៅ ។

ទីមួយ ចៅក្រម ន័យ ថុល មិនកាន់មុខតំណែងជាចៅក្រមអង្គជំនុំជម្រះក្នុងឋានៈជាមន្ត្រីក្នុងកងយោធពលខេមរភូមិន្ទ ប៉ុន្តែ

ក្នុងឋានៈជាជនស៊ីវិល ។ វាមានលក្ខណៈសមហេតុផលដែលថា អ្នកអង្កេត «បានដឹងគ្រប់កាលៈទេសៈទាំងអស់ដែលមានជាប់ពាក់ព័ន្ធ ហើយធ្វើការស្វែងរកភាពលម្អៀងនៅគ្រប់កាលៈទេសៈ ។ ចៅក្រម ន័យ ថុល ចូលបម្រើទ័ពតាំងពីឆ្នាំ១៩៧៩ ហើយលោកមានឋានៈជាឧត្តមសេនីយ៍ ។ ខណៈពេលដែលលោកកាន់មុខតំណែងជាប្រធានតុលាការយោធា លោកក៏ជាសមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាដែរ ។ ក្នុងឋានៈជាសមាជិកកងយោធពលខេមរភូមិន្ទ ដែលមានមុខតំណែងជាឧត្តមសេនីយ៍ យើងមិនអាចសន្មតថា ចៅក្រម ន័យ ថុល ត្រូវតែគោរពតាមបញ្ជារបស់ផ្នែកនីតិប្រតិបត្តិទេ ។ ជាក់ស្តែង អ្នកអង្កេតគួរតែដឹងថា សេចក្តីសម្រេចមិនទូលំទូលាយ ធ្វើឡើងដោយចៅក្រមនៅអង្គជំនុំជម្រះអាចបណ្តាលឲ្យផ្នែកនីតិប្រតិបត្តិមានប្រតិកម្ម ។

ទីពីរ ខណៈពេលដែលមានយោបល់លើកឡើងនៅក្នុងសំណុំរឿងមួយមិនអាចធ្វើឲ្យយើងរកឃើញភាពលម្អៀងនៅក្នុងករណីផ្សេងដែលមើលឃើញខាងក្រៅបាន អង្គជំនុំជម្រះមិនអាចប្រានចោលករណីដែលមានបញ្ហា ។ ចៅក្រម ន័យ ថុល បានកាត់ទោសព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ មេដឹកនាំគណបក្សហ្វុនស៊ិនប៉ិចពីបទឃុបឃិតជាមួយខ្មែរក្រហមដើម្បីទម្លាក់រដ្ឋាភិបាលបន្ទាប់ពីគណបក្សប្រជាជនបានបង្ខំឲ្យព្រះអង្គចេញពីតំណែង ។ លោកក៏បានកាត់ទោសលោក ជាម ចាន់នី តំណាងរាស្ត្រគណបក្សសមរង្ស៊ី ពីបទធ្វើឧក្រិដ្ឋកម្មដោយបានរៀបចំទុកជាមុននិងការក្លែងបន្លំដើម្បីបង្កើត «កងកម្លាំងប្រដាប់អាវុធខុសច្បាប់» ។ ជាងនេះទៅទៀតលោកក៏មានជាប់ពាក់ព័ន្ធក្នុងការពន្យារពេលការស៊ើបអង្កេតករណីកាំង ហ្គេកអ៊ាវ (ហៅឌុច) ដែរ ។

បញ្ហាទាំងអស់នេះស្ថិតនៅក្រោមការត្រួតពិនិត្យជាអន្តរជាតិ និងទទួលការរិះគន់ ។ អង្គបុរេជំនុំជម្រះបាននិយាយថា «ភ័ស្តុតាងជាច្រើនដែលលើកឡើងដោយមេធាវីការពារក្តីបង្កើតឡើងដោយការអធិប្បាយរបស់ភាគីទីបី» ដែលមិនមានជាប់ពាក់ព័ន្ធនឹងភាពលម្អៀងដែលធ្វើឡើងដោយចៅក្រម ន័យ ថុល ។ អង្គជំនុំជម្រះបន្ថែមទៀតថា «ការអង្កេតទូទៅនេះ និងការចោទប្រកាន់ មិនមានភ័ស្តុតាង ដើម្បីបញ្ជាក់ថាពិតជាមានភាពលម្អៀង» ។ ភាគីទីបីបានបង្ហាញថា ករណីនេះឆ្លុះបញ្ចាំងដំណើរការនីតិវិធីដែលមានភាពលម្អៀង ការបង្អាក់ដំណើរការនីតិវិធី និងសេចក្តីសម្រេចរបស់ចៅក្រម ន័យ ថុល អាចមាននិន្នាការខាងនយោបាយ ។ ការអង្កេតរបស់ភាគីទីបីមានជាប់ពាក់ព័ន្ធនឹងការកំណត់របស់អ្នកអង្កេតគឺថា តើចៅក្រមមានទម្លាប់កែប្រែសេចក្តីសម្រេចរបស់ខ្លួនដើម្បីផ្គាប់ចិត្តខាងនីតិប្រតិបត្តិឬទេ?

ការអះអាងរបស់អង្គជំនុំជម្រះដែលថា ការអង្កេតរបស់ភាគីទីបី «មិនមានភ័ស្តុតាង» ដើម្បីបញ្ជាក់ថាមានភាពលម្អៀងពិតជាត្រឹមត្រូវ ប៉ុន្តែការដែលនិយាយថាយោបល់ទាំងអស់នោះមិនមានជាប់ពាក់ព័ន្ធនឹងភាពលម្អៀងដូចដែលអ្នកអង្កេតលើកឡើងពិតជាមិនសមហេតុផលទេ ។ លក្ខណៈដែលមើលឃើញពីខាងក្រៅសំដៅទៅលើការយល់ឃើញ និងមើលឃើញពីខាងក្រៅទៅលើមនុស្សណាម្នាក់ឬវត្ថុអ្វីមួយ ។ ប្រសិនបើមានសំណួរផ្នែកច្បាប់សួរថា «តើលក្ខណៈពីខាងក្រៅរបស់ចៅ ក្រម ន័យ ថុល ដូចម្តេច?» ការអង្កេតរបស់ភាគីទីបីនឹងមានទាក់ទងនឹងសំណួរនេះ បើទោះជាសំណួរនោះផ្តោតទៅលើករណីផ្សេងក៏ដោយ ។ សារណាដែលដាក់ដោយភាគីទីបី និងយោបល់របស់ចៅក្រមអាចបន្ថែមឬបន្ថយទម្ងន់នៃការអង្កេតរបស់ភាគីទីបី ។

ស្ថានភាពទីបីទាក់ទងនឹងភាពជាសមាជិករបស់ចៅក្រមនៅក្នុងគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាថ្មីបើភាពលម្អៀងដែលមើលឃើញពីខាងក្រៅមិនត្រូវទទួលស្គាល់ស្ថានភាពនេះនៅតែមានជាប់ពាក់ព័ន្ធ ទោះបីជាលោកបានលាលែងពីតំណែងក្រោយពេលត្រូវបានតែងតាំងនៅអង្គជំនុំជម្រះ ។ នៅពេលដែលយើងលើកស្ថានភាពនេះដាក់ទៅក្នុងករណីផ្សេង វានឹងផ្តល់ទម្ងន់ទៅលើការយល់ឃើញរបស់អ្នកអង្កេតដែលថាផ្នែកនីតិប្រតិបត្តិអាចជះឥទ្ធិពលដល់ចៅក្រម ។

នៅពេលដែលយើងលើកឡើងពីសង្គម និងវប្បធម៌កម្ពុជា ករណីទាំងបីនេះអាចសន្មតថាមានការជាប់ពាក់ព័ន្ធគ្នាយ៉ាងខ្លាំងរវាងឋានៈរបស់ចៅក្រម ន័យ ថុល និងការចូលរួមរបស់លោកនៅក្នុងបក្សកាន់អំណាច ។ ដូច្នេះគួរតែជំរុញឲ្យមានអ្នកអង្កេតទៅលើភាពលម្អៀង ។

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ផ្នែកវិជ្ជាជីវៈច្បាប់កម្ពុជាត្រូវបានបំផ្លាញទាំងស្រុង ។ យោងទៅតាមរបាយ

ការណ៍សេវាកម្មផ្សព្វផ្សាយសាធារណៈឆ្នាំ២០០២ ចៅក្រមតិចជាងពាក់កណ្តាលនៅក្នុងប្រទេសបានរៀនចប់ថ្នាក់វិទ្យាល័យដោយមិនគិតពីការសិក្សានៅសាលាច្បាប់ ។ ក្នុងចំណោមចៅក្រម និងព្រះរាជអាជ្ញាចំនួន១៧១នាក់ដែលធ្វើការនៅប្រទេសកម្ពុជានៅឆ្នាំ ២០០២ មានតែ៣៣ភាគរយនៃអ្នកទាំងនោះប៉ុណ្ណោះបានទទួលវគ្គបណ្តុះបណ្តាលផ្នែកច្បាប់ជាផ្លូវការ ។ យោងតាមភាពខ្វះខាតនេះ កម្ពុជានៅតែត្រូវការចៅក្រមនិងមេធាវីបន្ថែម ។ យើងអាចសន្និដ្ឋានដោយសមហេតុផលថា «អ្នកដែលដឹងពីបញ្ហានេះ» គឺជាមនុស្សសំខាន់ដែលអាចតំឡើងឬផ្លាស់ប្តូរដំណែងនៅក្នុងជួររដ្ឋាភិបាល ។

ក្នុងករណីដែលចៅក្រម ន័យ ថុល មានទំនាក់ទំនងជាមួយយោធា ផ្នែកនីតិប្រតិបត្តិ និងគណបក្សប្រជាជនកម្ពុជា អង្គបុរេជំនុំជម្រះបានសំអាងសេចក្តីសម្រេចរបស់ខ្លួនទៅលើការសន្និដ្ឋានដែលនៅខ្វះចន្លោះថា តួនាទី «បុគ្គល» និង «មន្ត្រី» អាចត្រូវបានសម្គាល់ និងបែងចែកយ៉ាងងាយស្រួល ដូចដែលការគាំទ្រខាងយោធា និងនយោបាយអាចត្រូវបានបែងចែកដោយបានការធ្វើសច្ចាប្រណិធានថា នឹងកាត់សេចក្តីដោយសំអាងទៅលើអង្គហេតុ ។ នៅក្នុងករណីខ្លះ ចៅក្រមមួយចំនួនប្រហែលជាប្រើប្រាស់ជំនាញបំបែកស្ថានភាពមួយចេញពីស្ថានភាពមួយទៀត ។ ការធ្វើបែបនេះមិនមែនជា «ការធ្វើឲ្យមានភាពលម្អៀងពិតប្រាកដ» ទេ ប៉ុន្តែអ្នកអង្កេតដែលដឹងពីគ្រប់កាលៈទេសៈអាចយល់ថា នេះជាភាពលម្អៀង ។

អង្គជំនុំជម្រះបានលើកឡើងពីបទដ្ឋាន ព្រមទាំងដឹកនាំការគ្រប់គ្រងដោយផ្តល់ការបកស្រាយមិនគ្រប់គ្រាន់ចំពោះមធ្យោបាយនៃការធ្វើសេចក្តីសម្រេច ។ ប្រសិនបើអង្គជំនុំជម្រះបានបកស្រាយការវិភាគរបស់ខ្លួនបានពេញលេញជាងនេះបន្តិច សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ប្រហែលជាសមហេតុផលជាងនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកនិពន្ធជឿថាសេចក្តីសម្រេចដែលធ្វើឡើងមិនបានផ្អែកទៅលើទម្ងន់នៃស្ថានភាពទេ តែបែរជាពិចារណាទៅលើស្ថានភាពនយោបាយដែលកើតឡើងដោយស្ថានភាពនេះទៅវិញ ។ ការអង្កេតនេះមានប្រតិកម្មចំពោះការគ្រប់គ្រងមិនសមស្របរបស់អង្គជំនុំជម្រះចំពោះបញ្ហាដែលអង្គជំនុំជម្រះមិនទទួលយោបល់អ្នកដែលជាភាគីទីបី សារណាដែលអាចមានការជាប់ពាក់ព័ន្ធនឹងការស៊ើបអង្កេត និងបញ្ហាចម្រូងចម្រាស ។

ការដកចៅក្រម ន័យ ថុល អាចបណ្តាលឲ្យមាន «ភាពច្របូកច្របល់» ដែលអាចបន្តឲ្យមានការដកចៅក្រមកម្ពុជាដទៃទៀត ។ នេះមិនមានន័យថា ចៅក្រមដទៃស្ថិតនៅក្នុងស្ថានភាពស្រដៀងនឹងចៅក្រម ន័យ ថុល ទេ ប៉ុន្តែវាអាចបណ្តាលឲ្យមានការស៊ើបអង្កេតដ៏ស្មុគស្មាញដែលធ្វើឲ្យអង្គជំនុំជម្រះមានភាពអាម៉ាស់ ឬយ៉ាងហោចណាស់ក៏ធ្វើឲ្យអង្គជំនុំជម្រះទទួលការរិះគន់រយៈពេលយូរដែរ ។

បញ្ហាទីបីនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះគឺទស្សនៈដែលថា «អង្គជំនុំជម្រះគឺជាតុលាការមួយដាច់ដោយឡែកនិងឯករាជ្យ គ្មានជាប់ពាក់ព័ន្ធនឹងតុលាការផ្សេងទៀតនៅកម្ពុជាទេ» ។ ការអះអាងនេះនឹងមិនធ្វើឲ្យមានការចាប់អារម្មណ៍ប្រសិនបើតុលាការគ្រាន់តែនិយាយថា នេះគឺជាការបញ្ជាក់តាមផ្លូវច្បាប់ ។ ប៉ុន្តែតុលាការមិនបានបង្ហាញបែបនេះទេ តែបែរជាបង្ហាញក្នុងទម្រង់ជាប់ពាក់ព័ន្ធនឹងការវិភាគរបស់អង្គជំនុំជម្រះទៅលើករណីចៅក្រម ន័យ ថុល ។ អង្គជំនុំជម្រះបានយកការអះអាងតាមអង្គច្បាប់ដែលពណ៌នាពីស្ថាប័ននិងបុគ្គលដែលផ្ទុយពីការអះអាងរបស់អង្គហេតុ ។

ទស្សនៈនេះបង្ហាញឲ្យឃើញភាពខុសគ្នារវាងតុលាការនិងប្រវត្តិរបស់ចៅក្រមកម្ពុជា ។ អ្វីដែលអាក្រក់គឺវាចោទជាសំណួរថា តើអង្គជំនុំជម្រះមានសុឆន្ទៈដោះស្រាយបញ្ហាអំពើពុករលួយនិងភាពលម្អៀងដែលស្មើនោះទេ ។ ខណៈពេលដែលតុលាការអះអាងពីយុត្តិធម៌ ឯករាជ្យភាព និងភាពមិនលម្អៀងនៅក្នុងសកម្មភាពដែលស្របតាមដំណើរនីតិវិធីនិងភ័ស្តុតាង គោលការណ៍នេះនឹងប្រតិបត្តិមិនត្រឹមតែជាការសន្និដ្ឋានទេ ហើយក៏ជាលក្ខណៈបទដ្ឋានដែរ ។ ប្រសិនបើតុលាការសន្និដ្ឋានឯករាជ្យភាពជាអង្គហេតុដែលជាប់ពាក់ព័ន្ធនេះបណ្តាលឲ្យមានសំណួរថាតើតុលាការនឹងមានប្រតិកម្មយ៉ាងដូចម្តេចនៅពេលដែលភ័ស្តុតាងបង្ហាញពីភាពផ្ទុយគ្នា ។

## ៣) ការសន្និដ្ឋានឯករាជ្យភាព និងភាពមិនលម្អៀង

មូលដ្ឋាននៃទស្សនៈរបស់អង្គជំនុំជម្រះដែលយកគោលការណ៍មកបញ្ជាក់ថា «ចំណុចចាប់ផ្តើមនៃការកំណត់លើការជំទាស់អំពី (ភាពលម្អៀង)» គឺមាន «ការសន្និដ្ឋានទុកជាមុនថា ចៅក្រមមិនមានភាពលម្អៀង ។ ការសន្និដ្ឋាននេះកើតចេញពីការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រមនិងលក្ខណៈគ្រប់គ្រាន់សម្រាប់ការ

តែងតាំង ព្រមទាំងបានដាក់បន្ទុកដ៏ធ្ងន់ចំពោះភាគីដែលបណ្ដឹងជិតចិត្តក្នុងការដកចេញនូវការសន្មតទុកជាមុន» ។ គោលបំណងនៃការធ្វើការសន្មតនេះគឺដើម្បីការពារការចោទប្រកាន់ដែលមិនមានភ័ស្ដុតាងបញ្ជាក់ដែលអាចធ្វើឲ្យតុលាការបាត់បង់ការជឿទុកចិត្តពីប្រជាជន ។ ជាងនេះទៅទៀត ការសន្មតក៏បានការពារការចោទប្រកាន់ឥតបានការដែលអាចប៉ះពាល់ដល់ការគ្រប់គ្រងដោយត្រឹមត្រូវ និងមិនមានភាពលម្អៀង ។ ត្រូវតែមានការសន្មតថា «ចៅក្រមនឹងមិនកែប្រែចិត្តចំពោះទស្សនៈផ្ទាល់ខ្លួននិងឥរិយាបថដែលមិនជាប់ពាក់ព័ន្ធ ។

ដោយមើលទៅលើកាលៈទេសៈចៅក្រមកម្ពុជានៅអង្គជំនុំជម្រះ ការសន្មតនេះអាចតម្រូវឲ្យមានការពិចារណាសាឡើងវិញ ប៉ុយ៉ាងហោចណាស់ក៏ត្រូវមានការត្រួតពិនិត្យឡើងវិញដែរ ។ យោងតាមរបាយការណ៍សេវាកម្មផ្សព្វផ្សាយព័ត៌មានសាធារណៈ នៅឆ្នាំ២០០២ ចៅក្រមមិនដល់ពាក់កណ្ដាលនៅក្នុងប្រទេសកម្ពុជាបានបញ្ចប់ការសិក្សាពីវិទ្យាល័យដោយមិនគិតពីសាលាច្បាប់ ។ លោក អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បាននិយាយថា នៅពេលដែលចៅក្រមកម្ពុជាបំពេញការងារ «ខ្ញុំមិនដឹងថាតើចៅក្រមទាំងនោះមានបទពិសោធន៍ផ្នែកអន្តរជាតិប៉ុន្មានទេ» ។ លោកបានបញ្ជាក់ទៀតថា «ក្នុងករណីដោះស្រាយឧក្រិដ្ឋកម្មក្នុងស្រុក ចៅក្រមទាំងនោះមានលទ្ធភាពអាចធ្វើបាន ។

ការសន្មតភាពមិនលម្អៀងត្រូវបានកំណត់ទៅលើ ១) ការធ្វើសច្ចាប្រណិធានចូលកាន់តំណែង និង ២) លក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំង ។ តើការសន្មតភាពមិនលម្អៀងគួរតែធ្វើឡើងឬទេ ខណៈពេលដែលលក្ខណៈសម្បត្តិ និងបទពិសោធន៍របស់ចៅក្រមកំពុងមានបញ្ហា? តើការសន្មតពីភាពមិនលម្អៀងគួរតែធ្វើឡើងឬទេ ខណៈពេលដែលចៅក្រមធ្លាប់ធ្វើខុស?

អង្គជំនុំជម្រះបានសន្មតថា ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់មិនលម្អៀង សុចរិត និងមានគុណសម្បត្តិតាមការតម្រូវសម្រាប់តែងតាំងឲ្យបម្រើការងារក្នុងការិយាល័យតុលាការនៅក្នុងប្រទេស ។ ចៅក្រមត្រូវតែឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន មិនអាចទទួលយកឬស្វែងរកការណែនាំពីរដ្ឋាភិបាលឬប្រភពណាមួយផ្សេងទៀតឡើយ ។

ចំពោះការតែងតាំងនៅអង្គជំនុំជម្រះ ចៅក្រមគួរតែមានបទពិសោធន៍ខាងច្បាប់ព្រហ្មទណ្ឌ ច្បាប់អន្តរជាតិ ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស ។

ខណៈពេលដែលគោលការណ៍ទាំងនេះមានតម្លៃសម្រាប់ពណ៌នាចៅក្រមដែលគួរតែធ្វើការនៅអង្គជំនុំជម្រះ តុលាការគួរតែពិចារណាម្ដងទៀតទៅលើការសន្មតដែលយោងទៅតាមគោលការណ៍នេះ ។ វាហាក់ដូចជាមិនសមហេតុផលក្នុងការយកការសន្មតចំពោះចៅក្រមដែលមានបទដ្ឋានអន្តរជាតិមកដាក់លើចៅក្រមដែលមិនមានបទដ្ឋានអន្តរជាតិ ។ នេះមិនមានន័យថាចៅក្រមកម្ពុជាបង្កើនការសន្មតភាពមិនលម្អៀងដែលមានលក្ខណៈទាប ប៉ុន្តែតុលាការមិនគួរប្រកាន់យកការសន្មតខ្ពស់បែបនេះទេ ខណៈពេលដែលធាតុផ្សំដែលបានមកពីការធ្វើសច្ចាប្រណិធាននិងលក្ខណៈសម្បត្តិរបស់ចៅក្រមទាបនៅឡើយ ។

អំពើពុករលួយ ឥទ្ធិពលនយោបាយ ការជាប់ពាក់ព័ន្ធនិងសេចក្ដីសម្រេចរបស់តុលាការ ដែលមានបញ្ហានៅក្នុងករណីមុនគួរតែជំរុញឲ្យតុលាការធ្វើការពិចារណាម្ដងទៀតទៅលើការសន្មតិពីឯករាជ្យភាពនិងភាពមិនលម្អៀង ។

ខណៈពេលដែលអង្គជំនុំជម្រះគឺជាស្ថាប័នចម្រុះដែលមានបំណងនាំយកយុត្តិធម៌ ការផ្សះផ្សាជាតិនិងសន្តិភាពមកឲ្យប្រជាជនកម្ពុជា អង្គជំនុំជម្រះគួរតែប្រកាន់ខ្ជាប់នូវយុត្តិធម៌ ឯករាជ្យ និងភាពមិនលម្អៀង មិនមែនជាការសន្មតដែលគ្មានបញ្ហា តែជាការសន្មតដែលមានបទដ្ឋាន ។ យោងតាមបទដ្ឋាន តុលាការគួរតែប្រកាន់យកការសន្មតខ្ពស់ទៅលើមូលដ្ឋានអង្គហេតុដែលមានប្រសិទ្ធភាព និងសមហេតុផល ។ **គ្រីស្តូហ្វ័រ**

## ពាក្យស្លោកខ្មែរក្រហម

- ស្លាប់ក្នុងសង្គ្រាមប្រសើរជាងរស់។
- ខ្លះខ្លែងកម្ទេចកម្លាំងខ្មាំង ថែរក្សានិងបំប៉នកម្លាំងយើង កាន់តែខាយកាន់ខ្លាំង កាន់តែខាយកាន់ឈ្នះ។
- ភ្ជាប់ឱ្យជាប់នូវសតិអារម្មណ៍ខាយសម្រុក ខ្លះខ្លែងសម្រុក ខាយសម្រុកជាប់ជានិច្ច។ *(សៀវភៅកំណត់ហេតុលេខ២០០)*

# ការពិតត្រូវបានលាតត្រដាង :
# ការវិលត្រឡប់របស់ ហ្កុនណា បឺយស្រ្តម មកកម្ពុជា

*នៅពេលដែលយើងកំពុងតែដើរឆ្ពោះទៅកាន់វិថីដ៏សំខាន់មួយក្នុងទីរួមខេត្តកំពង់ចាមដែលជាខេត្តមួយត្រូវចំណាយពេលធ្វើដំណើរប្រមាណជាពីរម៉ោងតាមរថយន្តពីទីក្រុងភ្នំពេញ ហ្កុនណា បាននិយាយមកកាន់ខ្ញុំដោយចិត្តក្តុកក្តួលថា «ខ្ញុំមានអារម្មណ៍រំជួលចិត្តយ៉ាងខ្លាំង» ។ ហ្កុនណា បានខំសម្លឹងរកមើលស្ថានីយរថយន្តក្រុងជាកន្លែងដែលគាត់បានថតរូបកាលពី៣០ឆ្នាំមុនពេលដែលគាត់បានមកបំពេញទស្សនកិច្ចចំនួន១៨ថ្ងៃនៅក្នុងប្រទេសកម្ពុជា ។*

*ហ្កុនណា បាននិយាយបន្តទៀតថា «ពេលនេះខ្ញុំមានអារម្មណ៍ប្លែកជាងកាលនៅទីក្រុងភ្នំពេញកាលពីម្សិលមិញ ដោយសារទីនេះមានសភាពស្ងាត់ជ្រងំពេលដែលខ្ញុំបានមកដល់កាលពី៣០ឆ្នាំមុន» ។*

*ហ្កុនណា បានមកដល់ប្រទេសកម្ពុជាកាលពីថ្ងៃអាទិត្យនិងធ្វើការសុំខមាទោសដល់ប្រជាជនកម្ពុជានូវអ្វីដែលគាត់ធ្លាប់បានគាំទ្ររបបខ្មែរក្រហម ។ នេះជាលើកទីមួយដែលគាត់បានត្រឡប់មកកាន់ប្រទេសកម្ពុជាម្តងទៀតកាលគាត់មកជាងបីទសវត្សរ៍មុន ។*

*ហ្កុនណា បានមកដល់ប្រទេសកម្ពុជាដំបូងនៅខែសីហា ឆ្នាំ១៩៧៨ ជាមួយគណៈប្រតិភូស៊ុយអែដចំនួន៣នាក់ផ្សេងទៀត ។ កម្មាភិបាលខ្មែរក្រហមពីរនាក់បាននាំ ហ្កុនណា បឺយស្រ្តម និងគណៈប្រតិភូទៅទស្សនាមន្ទីរពេទ្យ សាលារៀន រោងចក្រ និងសហករណ៍ ។ គណៈប្រតិភូបានពិសារអាហារនិងផឹកស្រាដែលរៀបចំទទួលដោយ ប៉ុល ពត និង អៀង សារី នៅក្នុងរាជវាំង ហើយក៏បានស្នាក់នៅ២យប់ក្នុងភូមិគ្រឹះនៅទីក្រុងសៀមរាបផងដែរ ។*

*បើតាមសម្តីរបស់ ហ្កុនណា គាត់មិនបានឃើញការធ្វើទារុណកម្ម ការសម្លាប់ ហើយក៏មិនបានដឹងពីការអត់ឃ្លានរបស់ប្រជាពលរដ្ឋដែរ នៅពេលគាត់មកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ។ ហ្កុនណា បានត្រឡប់ទៅកាន់មាតុភូមិនៃប្រទេសស៊ុយអែតវិញ ដោយបាននាំយកជាមួយនូវសៀវភៅសិក្សា ចម្រៀង ទស្សនាវដ្តីនិងរូបថតរាប់ពាន់សន្លឹក អ្វីដែលគាត់បានឃើញផ្ទាល់ផ្នែកភ័ស្តុតាងនិងបទពិសោធន៍នៅអំឡុងពេលដែលខ្មែរក្រហមស្ថិតក្នុងដំណាក់កាលដំបូងមុននឹងឆ្ពោះទៅរកសង្គមមួយដែលល្អឥតខ្ចោះ ទោះបីជាពេលនោះមិនទាន់មានលក្ខណៈល្អឥតខ្ចោះបែបនេះក៏ដោយ ។ ទើបតែពេលដែលគាត់បានឃើញជនភៀសខ្លួនបានមកផ្តុំគ្នានៅប្រទេសថៃទេ ទើបគាត់ដឹងថា គាត់បានវិនិច្ឆ័យខុសចំពោះរបបខ្មែរក្រហម ។*

*យើងបានរកឃើញស្ថានីយរថយន្តក្រុង ដែលពេលនេះត្រូវបានផ្លាស់ប្តូរទៅជាផ្សារលក់ទំនិញយ៉ាងណែនណាន់តាន់តាប់ ។ ហ្កុនណា បានលាន់មាត់ថា ផ្សារនៅមានលក្ខណៈរស់រវើកនៅឡើយ ។ វាមានសភាពខុសគ្នាស្រឡះទៅនឹងអ្វីដែលគាត់បានឃើញកាលពីឆ្នាំ១៩៧៨ ដែលកាលនោះមានសភាពស្ងាត់ជ្រងំនិងជាទីក្រុងមួយដែលគាត់បានឃើញមនុស្សតិចតួចកំពុងហាលពោត និងមើលថែកូនក្មេងនៅពីមុខហាងដ៏សែនស្ងាត់ ។*

*ហ្កុនណា និយាយថា «កាលពី៣០ឆ្នាំមុន ខ្ញុំបានព្យាយាមនិយាយទៅកាន់ស្ត្រីមួយចំនួននៅឯស្ថានីយរថយន្តក្រុង ។ ខ្ញុំចង់និយាយទៅកាន់ស្ត្រីទាំងនោះដោយខ្លួនឯង ខ្ញុំចង់ប្រាប់គាត់ថា ខ្ញុំមកពីណា» ។ កម្មាភិបាលខ្មែរក្រហមបានដើរតាមក្រុមគណៈប្រតិភូគ្រប់ដំហានដែលគាត់បានទៅ ហាក់បីដូចជាអង្គរក្សតាមការពារគាត់ជាប់ ហើយក្រោយមកទើបនឹកឃើញថាកម្មាភិបាលទាំងនោះជាចារកិច្ចខ្មែរក្រហមដែលតាមយកការណ៍ពីគាត់ ហើយមិនឲ្យគាត់និយាយទៅកាន់ប្រជាជន ។ ហ្កុនណា បឺយស្រ្តម បានបន្ថែមទៀតថា «ខ្ញុំមិនបានសួរស្ត្រីទាំងនោះច្រើនទេ ហើយគាត់ហាក់បីដូចជាភារែកមិនចង់និយាយដែរ» ។*

*ហ្កុនណា បានឈរថតរូបនៅកន្លែងដែលគាត់ធ្លាប់បានឈរថតកាលពីមុន ។ នេះជាការធ្វើតាមអ្វីដែលគាត់ធ្លាប់ធ្វើដោយអារម្មណ៍មួយដែលមិនអាចបរិយាយបាន ។*

*យើងបានមកដល់វិថីសំខាន់ក្នុងក្រុងកំពង់ចាមទាំងអស់គ្នា ។*

ហ៊ុនណា បាននិយាយថា «អ្នកដឹងទេ ខ្ញុំមិនដែលគិតយ៉ាងនេះទេ ពេលដែលខ្ញុំបានមកកាន់ទីនោះដំបូង ។ ពីមុននៅទីនេះគ្មានយានជំនិះសាធារណៈ គ្មានមនុស្សអង្គុយនៅចំណតរថយន្តក្រុងទេ ។ ប្រជាពលរដ្ឋនៅទីកន្លែងណាដែលខ្មែរក្រហមឲ្យគេនៅប៉ុណ្ណោះ ។ ប្រជាពលរដ្ឋមិនអាចធ្វើដំណើរទៅកន្លែងណាមួយដែលគេចង់ទៅបានទេ ហើយត្រូវរស់នៅដោយពឹងលើខ្មែរក្រហម» ។ គាត់បានបន្តទៀតថា «ហេតុអ្វីកាលនោះខ្ញុំមិនបានគិតពីបញ្ហានេះ» ។

នេះជាការដឹងមុខមាត់ពិតរបស់ខ្មែរក្រហមក្រោយពេលដែលគាត់មកដល់ប្រទេសកម្ពុជានៅពេលនេះ ។

មុននឹងធ្វើដំណើរទៅកាន់ទីណាមួយ រដ្ឋាភិបាលស៊ុយអែដមានការប្រុងប្រយ័ត្នជានិច្ចចំពោះគណៈប្រតិភូដែលត្រូវធ្វើទស្សនកិច្ចទៅកាន់ប្រទេសដែលមានអំពើប្រល័យពូជសាសន៍ ហើយបានធ្វើការទូន្មានថា សូមប្រយ័ត្ន ហើយមិនត្រូវជឿទាំងស្រុងនូវអ្វីដែលត្រូវបានបង្ហាញទេ ។ ហ៊ុនណា បាននិយាយថា «យើងតែងប្រាប់គ្នាថាត្រូវពិចារណានូវអ្វីដែលយើងបានឃើញ ។ ប៉ុន្តែទីបញ្ចប់យើងបានធ្លាក់ចូលក្នុងអន្ទាក់» ។ ហ៊ុនណា ត្រូវបានខ្មែរក្រហមមិនឲ្យឃើញនូវអ្វីដែលគាត់ចង់ឃើញ ។ គាត់បានសរុបសេចក្តីថាចំណុចវិជ្ជមានរបស់បដិវត្តន៍បានលុបលើសេចក្តីអាក្រក់ ។

## សិក្ខាសាលានៅកំពង់ចាម ៖ សុំខមាទោសតាមវប្បធម៌ខ្មែរ

កាលពីថ្ងៃព្រហស្បតិ៍ មានព្រះសង្ឃ បុរស នារី កុមារា កុមារី និងមនុស្សគ្រប់វ័យបានមកជុំគ្នានៅក្រោមតង់កៅស៊ូក្នុងបរិវេណវត្តបឹងកុក ខេត្តកំពង់ចាម ដើម្បីស្តាប់ ហ៊ុនណា រៀបរាប់កាលពីពេលដែលគាត់មកធ្វើទស្សនកិច្ចនៅទីនេះក្នុងរបបខ្មែរក្រហម ។ នេះជាការនិយាយទៅកាន់សាធារណជនលើកទីពីរនៃដំណើរទស្សនកិច្ចរបស់គាត់ក្នុងដំណើរត្រឡប់មកកម្ពុជានៅពេលនេះ ។ បដាពណ៌សធំៗដែលមានរូបលោក ហ៊ុនណា ត្រូវបានព្យួរព្រោងព្រាតតាមដើមឈើ ដែលយោលយោកទៅមកតាមខ្យល់បក់ ។

រូបថតដែលមានរូបលោក បឺយស្រ្តម ថតនៅពីមុខស្ថានីយរថយន្តក្រុងកាលពី៣០ឆ្នាំមុន ត្រូវបានគេព្យួរនៅខាងក្រៅបរិវេណវត្តដើម្បីទាក់ទាញអ្នកដំណើរទាំងឡាយ ។ នគរបាលពីរបីនាក់កំពុងនៅជ្រកក្រោមម្លប់ដើមឈើនៅជិតតង់កៅស៊ូ ដែលមិនអាចមើលឃើញ ហ៊ុនណា ច្បាស់ប៉ុន្មានទេ តែអាចឮសំឡេងគាត់និយាយបាន ។ បរិយាកាសបានប្រព្រឹត្តទៅដោយការយោគយល់ ហើយមានអត្ថន័យបំផុត ។

នៅអំឡុងពេលពិភាក្សាលោក ហ៊ុនណា បាននិយាយទៅកាន់ប្រជាជនខ្មែរពីហេតុផលដែលគាត់មកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយនិងហេតុផលដែលគាត់គាំទ្រខ្មែរក្រហមកាលពីដំហានដំបូង ដោយបានយកចំណុចមនោគមន៍វិជ្ជារបស់ម៉ៅនិយមដែលធ្វើឲ្យគាត់គាំទ្ររបបនោះ ។ គាត់បាននិយាយប្រាប់អ្នកស្តាប់ដោយលម្អិតពីដំណើរទស្សនកិច្ចរបស់គាត់កាលពីពេលនោះដោយបានប្រាប់ទាំងអស់នូវកន្លែងដែលគាត់បានទៅដល់ និងអ្វីដែលគាត់បានឃើញដូចជា ក្មេងៗកំពុងញញឹមមករកគាត់ ប្រជាជនកំពុងធ្វើការក្នុងវាលស្រែ និងការហូបរួម ។ ហ៊ុនណា បានពន្យល់ពីអ្វីដែលគាត់មិនបានយកចិត្តទុកដាក់ដូចជាផ្លូវដ៏ស្ងាត់ជ្រងំ អវត្តមានព្រះសង្ឃនៅលើដងផ្លូវ និងវត្តអារាម និងភាពស្ងាត់ជ្រងំនៃទីក្រុងទាំងឡាយបន្ទាប់ពីជម្លៀសប្រជាជនចេញ ។

អ្នកចូលរួមមានចិត្តអន្ទះសាចង់សួរលោក ហ៊ុនណា ជាច្រើនសំណួរ ។ ដំណើរទស្សនកិច្ចរបស់គាត់នៅពេលនេះបានបង្កឲ្យមានការពិភាក្សាអំពីព្រឹត្តិការណ៍ផ្សេងទៀតជុំវិញរបបខ្មែរក្រហមកាលពីមុននិងពេលបច្ចុប្បន្ន ។ អ្នកចូលរួមម្នាក់សូមឲ្យលោក ហ៊ុនណា ពន្យល់ឲ្យបានក្បោះក្បាយអំពីមនោគមន៍វិជ្ជាម៉ៅនិយម ហើយអ្នកភូមិម្នាក់ទៀតចង់ដឹងពីទស្សនៈរបស់លោកអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលកំពុងតែដំណើរការនេះ ។ ព្រះសង្ឃមួយអង្គបានសួរគាត់ដោយលើកទឹកចិត្តគាត់ឲ្យចូលរួមក្នុងដំណើរការសាលាក្តីខ្មែរក្រហម ដើម្បីបង្ហាញនូវភ័ស្តុតាងទៅកាន់សាលាក្តី ។ ចំណែកព្រះសង្ឃមួយអង្គទៀតបានថ្លែងអំណរគុណលោក ហ៊ុនណា ហើយសំណូមពរឲ្យសាលាក្តីខ្មែរក្រហមដំណើរការឲ្យបានលឿនជាងនេះ ។

ម្យ៉ាងវិញទៀត អ្នកចូលរួមផ្សេងទៀតនៅតែមិនអស់ចិត្តចំពោះ ហ៊ុនណា ដែលមិនបានដឹងនូវអ្វីដែលបានកើតឡើងពេលដែលគាត់បានមកធ្វើទស្សនកិច្ចក្នុងរបបខ្មែរក្រហម ។ ព្រះសង្ឃមួយអង្គបានសួរថា «តើហេតុអ្វីបានជាលោកមិនឃើញការសម្លាប់មនុស្សពេលដែលលោកនៅក្នុងប្រទេសនេះ?» ព្រះសង្ឃរូបនេះបានបន្តសំណួរទៀតថា «ហេតុអ្វីបានជាលោកមិនឃើញការធ្វើ

*ទារុណកម្ម?"*

ទីបញ្ចប់លោក ហ៊ុនណា បានធ្វើការសុំខមាទោសដល់ប្រជាជនខ្មែរពីអ្វីដែលគាត់បានគាំទ្ររបបខ្មែរក្រហម ។ គាត់មានការសោកស្តាយយ៉ាងខ្លាំងនូវអ្វីដែលគាត់បានធ្វើខុស ។

**ឆ្ពោះទៅរកការបង្រួបបង្រួមជាតិ ៖ ការសុំខមាទោសដោយទឹកចិត្តស្មោះត្រង់**

សិក្ខាសាលានេះបន្តឲ្យមានការពិភាក្សាយ៉ាងច្រើនពីសំណាក់អ្នកភូមិនិងព្រះសង្ឃ ប៉ុន្តែក៏បានផ្តល់ដល់ប្រជាជនកម្ពុជាទាំងឡាយនូវអ្វីដែលគាត់មិនបានឃើញនូវការសុំខមាទោសដោយស្មោះអស់ពីដួងចិត្តពីថ្នាក់ដឹកនាំទាំងឡាយដែលធ្លាប់គាំទ្រខ្មែរក្រហម ។ ខណៈពេលដែលកម្មាភិបាលថ្នាក់ក្រោមខ្មែរក្រហមធ្វើការសុំខមាទោសអំពីកំហុសរបស់ខ្លួនលោក ហ៊ុនណា គឺជាអ្នកនយោបាយជាន់ខ្ពស់ដំបូងបង្អស់ដែលទទួលខុសត្រូវនូវអ្វីដែលគាត់បានធ្វើ ។ លើសពីនេះទៅទៀត ការសុំខមាទោសរបស់លោក បីយស្រ្តូមក៏ប្រហែលជាទង្វើលើកទីមួយដែលប្រជាជនកម្ពុជាបានទទួលជាសាធារណៈពីសំណាក់ជនបរទេសម្នាក់ ។

អតីតប្រមុខរដ្ឋខ្មែរក្រហមលោក ខៀវ សំផន និងបងធំទីពីរគឺលោក នួន ជា ធ្លាប់បានធ្វើការសុំទោសជាសាធារណៈដល់ប្រជាជនកម្ពុជាកាលពីឆ្នាំ១៩៩៨ ប៉ុន្តែថ្នាក់ដឹកនាំទាំងពីររូបនេះមិនដែលទទួលខុសត្រូវនូវអ្វីដែលខ្លួនបានប្រព្រឹត្តទេ ។

ក្នុងសន្និសីទកាសែតមួយកាលពីឆ្នាំ១៩៩៨ ខៀវ សំផន បានអំពាវនាវដល់ប្រជាជនកម្ពុជាដោយពោលពាក្យថា «រឿងកន្លងហួសឲ្យវាហួសទៅចុះ» និងសំណូមឲ្យបំភ្លេចរឿងរ៉ាវកាលពីអតីតកាល ហើយទីបញ្ចប់គាត់នៅតែមិនទទួលខុសត្រូវនូវអ្វីដែលគាត់បានធ្វើដដែល ។ ជាការពិតណាស់ថាជាគំនិតចង់ឲ្យមានការរីកចម្រើនខាងសេដ្ឋកិច្ចដែលមានលក្ខណៈមិនច្បាស់លាស់របស់ ខៀវ សំផន បណ្តាលឲ្យប្រជាពលរដ្ឋរាប់លាននាក់បាត់បង់ជីវិតនៅអំឡុងឆ្នាំ១៩៧៥ ដល់ ១៩៧៩ ។ លោក ឆាំង យុ បានបកស្រាយថា «ការសុំទោសរបស់ ខៀវ សំផន បានបន្តឲ្យមានការខឹងសម្បាពីសំណាក់ប្រជាជនកម្ពុជា ព្រោះគ្មាននរណាជឿគាត់ទេ» ។

ហ៊ុនណា បានទទួលខុសត្រូវនូវអ្វីដែលគាត់បានពិចារណាខុស ហើយគាត់ក៏មិនបានបន្ទោសនរណាម្នាក់ដែរ តែបានបន្ទោសខ្លួនឯងដែលងប់ងុលមើលមិនឃើញខុសត្រូវ ។ គាត់បានសុំខមាទោសនៅថ្ងៃអង្គារ និងម្តងទៀតនៅថ្ងៃព្រហស្បតិ៍ ។ ហ៊ុនណា បានប្រាប់ប្រជាជនកម្ពុជាថា គាត់បានបន្ទោសខ្មែរក្រហមដែលបានបិទបាំងគណៈប្រតិភូ តែទីបញ្ចប់គាត់បានបន្ទោសខ្លួនឯង ។ គាត់បាននិយាយថា «យើងបានពាក់វ៉ែនតាម៉ៅនិយម ដូច្នេះយើងមើលឃើញតែអ្វីដែលគេឲ្យយើងឃើញប៉ុណ្ណោះ» ។

កាលពីថ្ងៃព្រហស្បតិ៍ នៅពេលដែលសួរថាតើមនោគមន៍វិជ្ជាម៉ៅនិយមមានឥទ្ធិពលលើការពិចារណារបស់គាត់យ៉ាងដូចម្តេច? ហ៊ុនណា បានបញ្ជាក់នូវជំនឿរបស់គាត់ថាមនោគមន៍វិជ្ជា «មិនបានបង្ខំមកលើខ្ញុំទេ ប៉ុន្តែវាបានធ្វើឲ្យខ្ញុំជឿ» ។

ហ៊ុនណា បានសារភាពថា «តាមរយៈរឿងរ៉ាវរបស់ជនភៀសខ្លួនដែលបានឮពីមុន និងដំណើរទស្សនកិច្ចរបស់យើងគឺសមល្មមឲ្យយើងអាចបោះបង់ការគាំទ្ររបស់យើងបានចំពោះរបបខ្មែរក្រហម» ។ បើតាមប្រសាសន៍របស់លោក ឆាំង យុ បានឲ្យដឹងថា ការសុំខមាទោសក្នុងសង្គមខ្មែរមានអត្ថន័យជ្រាលជ្រៅជាងក្នុងវប្បធម៌បស្ចិមប្រទេស ។ ក្នុងភាសាខ្មែរពាក្យថា សុំអភ័យទោស គឺមានន័យថា «មនុស្សម្នាក់បានស្នើទៅមនុស្សម្នាក់ទៀតឲ្យបន្ថយទោសដល់ខ្លួន សូមអភ័យទោសនូវអ្វីដែលខ្ញុំបានធ្វើចំពោះអ្នក» ។

លោក ឆាំង យុ បានពន្យល់ទៀតថា «ការសុំអភ័យទោសដែលបានធ្វើឡើងដោយជនបរទេសក៏នាំមកនូវអត្ថន័យដ៏ជ្រាលជ្រៅផងដែរ ។ នោះហាក់បីដូចជាចៅហ្វាយម្នាក់ធ្វើការសុំទោសទៅកាន់កូនចៅ និងការសុំទោសរបស់ស្តេចចំពោះប្រជារាស្រ្តឲ្យលើកលែងទោស» ។ លោក ឆាំង យុ បានបញ្ចប់សេចក្តីដោយពោលពាក្យថា «នេះជាសកម្មភាពដ៏គួរឲ្យកោតសរសើររបស់លោក ហ៊ុនណា» ។ ជារឿងដែលមិនគួរជឿសោះដែល ហ៊ុនណា បីយស្រ្តូម នឹងត្រូវឃើញលោក ខៀវ សំផន ផ្ទាល់ភ្នែកពេលដែលគាត់ធ្វើដំណើរទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃទី៨ ខែធ្នូ ខាងមុខនេះដើម្បីទៅចូលរួមសវនាការអង្គបុរេជំនុំជម្រះលើករណី ខៀវ សំផន ពេលដែលគាត់មកទស្សនាប្រទេសកម្ពុជានៅពេលនេះ ។

**សារ៉ា ចូនឌីកឃិន**

# ការផ្សះផ្សាចិត្តរបស់ ហ្គុនណា ប៊ីយស្ត្រម

នៅខែសីហា ឆ្នាំ១៩៧៨ ហ្គុនណា ប៊ីយស្ត្រម បានធ្វើដំណើរមកកាន់កម្ពុជាប្រជាធិបតេយ្យជាមួយនឹងគណៈប្រតិភូស៊ុយអែដជាច្រើននាក់ទៀត ។ នៅក្នុងដំណើរទស្សនកិច្ចនេះ ហ្គុនណា ត្រូវបានអញ្ជើញឲ្យទៅទស្សនាកន្លែងជាច្រើនក្នុងព្រះរាជាណាចក្រកម្ពុជារួមមាន ភ្នំពេញ ក្រុងព្រះសីហនុ សៀមរាប បាត់ដំបង និងទីតាំងផ្សេងៗទៀត ។ លើសពីនេះទៅទៀត គាត់ត្រូវបានអញ្ជើញឲ្យទៅមើលមន្ទីរពេទ្យ រោងចក្រកៅស៊ូ សហករណ៍ វត្តអារាម ការដ្ឋានការងារនិងការធ្វើការនៅតាមស្រែចម្ការ ។ ប៉ុន្តែរាល់ពេលដែល ហ្គុនណា ធ្វើដំណើរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់ត្រូវបានទាហានខ្មែរក្រហមតាមការពារនិងបង្ហាញផ្លូវជាប់ជានិច្ចជាពិសេសគាត់ត្រូវបានអនុញ្ញាតឲ្យចូលសំណេះសំណាលជាមួយ ប៉ុល ពត ផ្ទាល់ ។ នៅពេលនោះ ហ្គុនណា បានដឹងថា អ្វីដែលខ្មែរក្រហមបានបង្ហាញគាត់គឺសុទ្ធតែបានរៀបចំយ៉ាងប្រុងប្រយ័ត្នជាមុនរួចស្រេច ដើម្បីបង្ហាញពីភាពអស្ចារ្យ និងការជឿនលឿនផ្នែកសង្គមនិងនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ហើយធ្វើយ៉ាងណាកុំឲ្យគាត់បានដឹងពត៌មានអំពីការកាប់សម្លាប់ ការបង្អត់អាហារ ការធ្វើពលកម្មបាក់កម្លាំង និងការឈឺស្លាប់របស់ប្រជាជនរាប់ម៉ឺននាក់នៅទូទាំងប្រទេស ។ ប៉ុន្តែតាមសម្តីរបស់ ហ្គុនណា នាពេលបច្ចុប្បន្នបានរៀបរាប់ថា ការជម្លៀសប្រជាជនចេញពីទីក្រុងជាចំណុចមួយដែលគាត់មិនអាចយល់បានអំពីគោលគំនិតរបស់មេដឹកនាំខ្មែរក្រហម ព្រោះគាត់គិតថាវាជាការខ្ជះខ្ជាយធនធានសេដ្ឋកិច្ចរបស់កម្ពុជា ។ នៅពេលដែលគាត់បានទៅទស្សនានៅមន្ទីរពេទ្យ គាត់ក៏បានសង្កេតឃើញដែរថា ថ្វីដ្បិតតែរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមានឧបករណ៍ទំនើបមួយចំនួននៅក្នុងមន្ទីរពេទ្យក៏ដោយ ក៏គាត់ចាប់អារម្មណ៍ថាអវត្តមានអ្នកជំងឺនៅក្នុងមន្ទីរពេទ្យគឺជារឿងមួយដែលចម្លែក និងមិនសមហេតុផល ទោះបីជាគាត់ជាអ្នកសិក្សាអំពីទ្រឹស្តីកុម្មុយនីស្តយ៉ាងច្រើនក៏ដោយ ប៉ុន្តែនៅក្នុងឱកាសផ្សេងទៀត ហ្គុនណា បានកោតសរសើរខ្មែរក្រហម ។ នៅពេលដែលគាត់បានឃើញការទទួលទានរួមគ្នានៅក្នុងរោងបាយសហករណ៍ ចំណាប់អារម្មណ៍ដំបូងរបស់គាត់គឺថា ខ្មែរក្រហមបានរកឃើញដំណោះស្រាយដ៏មហិមាមួយចំពោះវិបត្តិខ្វះខាតម្ហូបអាហារ ។ ហេតុនេះការដឹកជញ្ជូនស្រូវឡើងលើនាវាដែលគាត់បានឃើញនៅកំពង់សោមបានធ្វើឲ្យគាត់គិតឃើញថា កម្ពុជាមិនត្រឹមតែបានដោះស្រាយចំពោះការខ្វះខាតអាហារប៉ុណ្ណោះទេ ថែមទាំងអាចនាំចេញស្បៀង



ហ្គុនណា ប៊ីយស្ត្រម

អាហារទៅក្រៅប្រទេសថែមទៀត ។

មុនពេលដែល ហ្គុនណា បានមកដល់កម្ពុជាប្រជាធិបតេយ្យ នៅឆ្នាំ១៩៧៨ គាត់និងគណៈប្រតិភូស៊ុយអែដបានទទួលព័ត៌មានខ្លះៗអំពីការកាប់សម្លាប់និងអំពើឃោរឃៅរបស់កម្ពុជាប្រជាធិបតេយ្យដែរ ពីព្រោះពេលនោះនៅតាមព្រំដែនមានជនភៀសខ្លួនជាច្រើននាក់បានជម្លៀសខ្លួន និងបោះជំរំនៅទីនោះ ហើយជនភៀសខ្លួនបានរៀបរាប់អំពីបទពិសោធន៍របស់ខ្លួននៅក្នុងការរស់នៅក្នុងសហករណ៍របស់ខ្មែរក្រហមទៅកាន់អ្នកកាសែតអន្តរជាតិទៀត ។ ទោះជាយ៉ាងនេះក៏ដោយ នៅពេលនោះ ហ្គុនណា គិតថាអត្ថបទទាំងឡាយដែលបានរៀបរាប់អំពីភាពឃោរឃៅរបស់ពួកកុម្មុយនីស្តនិយមដ៏បរិសុទ្ធថ្លៃថ្នូររបស់ខ្មែរក្រហម គឺគ្រាន់តែជាការឃោសនាបង្កាច់បង្ខូចរបស់ពួកមូលធននិយមនិងពួកសេរីនិយមប៉ុណ្ណោះ ប៉ុន្តែការយល់ឃើញបែបនេះមិនមែនជាកំហុសមួយធ្ងន់ធ្ងរដែល ហ្គុនណា បានធ្វើនោះទេ សូម្បីតែបញ្ញវន្តដ៏ល្បីល្បាញខាងសង្គម និងទស្សនវិជ្ជា ឈ្មោះ ណោម ឆមស្គី ក៏មិនជឿទៅលើការសន្និដ្ឋានអំពីចំណុចអវិជ្ជមានរបស់កម្ពុជាប្រជាធិបតេយ្យដែលពឹងផ្អែកទៅលើការនិយាយតគ្នាពីមាត់មួយទៅមាត់មួយរបស់ជនភៀសខ្លួនដែលគ្មានភស្តុតាងជារូបធាតុច្បាស់លាស់ដែរ ។ ម្យ៉ាងទៀតសូម្បីតែនៅក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំនៅខែមករា ឆ្នាំ១៩៧៩ ក៏ពិភពលោកទាំងមូល មិនបានទទួលស្គាល់ជាផ្លូវការថាមានអំពើប្រល័យពូជសាសន៍នៅកម្ពុជាកើតឡើងដែរ ។ ឧទាហរណ៍ ខ្មែរក្រហមត្រូវបានអនុញ្ញាតឲ្យរក្សាអាសនៈរបស់កម្ពុជានៅក្នុងអង្គការសហប្រជាជាតិរហូតដល់ឆ្នាំ១៩៩៣ ។ បច្ចុប្បន្ន បើសិនជាយើងមើលត្រឡប់ទៅក្រោយវិញ យើងឃើញថា អ្វីដែល ហ្គុនណា និង ណោម ឆមស្គី បានគិតគឺខុសទាំងស្រុង ។

នៅពេលដែល ហ្គុនណា ត្រឡប់ទៅកាន់ស៊ុយអែដវិញ ហ្គុនណា បានថតរូបរាប់រយសន្លឹក ចំពោះអ្វីដែលគាត់បានឃើញនៅកម្ពុជា ហើយគាត់បានពោលថា គាត់បានចាប់ចិត្តជិតអារម្មណ៍និងស្រឡាញ់ប្រទេសកម្ពុជា ។ ចំពោះផ្នែកនយោបាយ សង្គមនិងសេដ្ឋកិច្ច ហ្គុនណា មានទស្សនៈគាំទ្រចំពោះកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែនៅក្នុងរយៈពេល៣០ឆ្នាំក្រោយមកនេះ ហ្គុនណា និងមិត្តភក្តិរបស់គាត់ដែលបានរួមដំណើរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានត្រិះរិះពិចារណាជាច្រើនលើកច្រើនសា និងសរសេរអត្ថបទជារូបភាព និងសៀវភៅ និងអត្ថបទកាសែតអំពីភាពត្រឹមត្រូវរបស់ខ្មែរក្រហម អំពើប្រល័យពូជសាសន៍ កុម្មុយនីស្តនិយម សីលធម៌ និងសច្ចធម៌ ។ មិត្តភក្តិរបស់គាត់នៅតែប្រកាន់ជំហរគាំទ្រខ្មែរក្រហមរហូតដល់បច្ចុប្បន្ន ប៉ុន្តែ ហ្គុនណា បានផ្លាស់ប្តូរទស្សនៈរបស់គាត់ពីការគាំទ្រងប់ងុលចំពោះភាពត្រឹមត្រូវនៃកុម្មុយនីស្តនិយម ទៅការវិភាគរកចំណុចអាក្រក់របស់លទ្ធិនេះ និងទីបំផុតទៅការទទួលស្គាល់ថាលទ្ធិកុម្មុយនីស្តនិយមបានបង្កឲ្យមានការស្លាប់បាត់បង់ជីវិតមនុស្សរាប់លាននាក់នៅក្នុងសតវត្សរ៍២០ ។ ការស្លាប់បាត់បង់ជីវិតនេះមានទំហំធំជាងការបាត់បង់ជីវិតនៅក្នុងសង្គ្រាមលោកលើកទី១ និងទី២បូកបញ្ចូលគ្នាទៅទៀត ។ សព្វថ្ងៃ ហ្គុនណា ទទួលស្គាល់ថា កម្ពុជាប្រជាធិបតេយ្យនិងលទ្ធិកុម្មុយនីស្តនិយមរបស់ខ្មែរក្រហម ជាលទ្ធិនយោបាយជ្រុលនិយម ឆ្កួតលេលាគ្មានហេតុផល និងជាអ្វីដែលមនុស្សជាតិត្រូវចៀសវាង ។ គាត់បានបង្ហាញពីការសោកស្តាយចំពោះការគាំទ្ររបស់គាត់ទៅលើខ្មែរក្រហមនៅក្នុងទសវត្សរ៍៧០ ហើយគាត់បានសុំទោសទៅកាន់ប្រជាជនកម្ពុជាចំពោះទង្វើរបស់គាត់នេះ ។

ហ្គុនណា ក៏ដូចជាអ្នកបង្កើតទ្រឹស្តីកុម្មុយនីស្តនិយមដ៏ល្បីល្បាញទាំងឡាយដូចជា កាល់ម៉ាក្ស លេនីន ហ្វ្រីដទ្រិក អេិនជេលដែរ គឺស្អប់ខ្ពើមចំពោះជំងឺសង្គម និងសេដ្ឋកិច្ចរបស់លទ្ធិមូលធននិយមនិងសេរីនិយមដែលបង្កឲ្យមានប្រជាជនរាប់លាននាក់នៅលើពិភពលោករស់នៅលំបាកវេទនា គ្មានអាហារគ្រប់គ្រាន់និងគ្មានផ្ទះសម្បែងត្រឹមត្រូវ ហើយធ្វើឲ្យមនុស្សមួយចំនួនតូចមានទ្រព្យសម្បត្តិហូរហៀរ ។ កុម្មុយនីស្តនិយមចង់បានសមភាពផ្នែកសេដ្ឋកិច្ច យុត្តិធម៌សង្គម គ្មានការជិះជាន់ គ្មានអំពើពុករលួយនិងការបង្ខិតបង្ខំ ហើយប្រជាជនថែរក្សាគ្នាទៅវិញទៅមកនិងចាត់ទុកគ្នាថាជាសមាជិកនៃគ្រួសារតែមួយ ។ ហ្គុនណា គាំទ្រគោលគំនិតបែបនេះនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែគាត់មិនបានគាំទ្រអំពើប្រល័យពូជសាសន៍ និងការកាប់សម្លាប់ឡើយ ។

ក៏ប៉ុន្តែ ការជឿជាក់ងប់ងុលទៅលើមនោគមន៍វិជ្ជាមួយអាចធ្វើឲ្យមនុស្សម្នាក់មើលរំលងលើចំណុចខ្សោយ និងបញ្ហាទាំងឡាយដែលលទ្ធិមួយអាចបង្កឲ្យមាន ។ នៅក្នុងប្រវត្តិសាស្ត្ររបស់លទ្ធិ

កុម្មុយនីស្តនិយម ពិសេសមុនទសវត្សរ៍៧០ ដែលខ្មែរក្រហមបានឡើងកាន់អំណាច គេសង្កេតឃើញមានការកាប់សម្លាប់ជាច្រើនដោយមេដឹកនាំកុម្មុយនីស្តទៅលើប្រជាជនរបស់ខ្លួន។ ឧទាហរណ៍នៅទសវត្សរ៍២០និង៣០ នៅសហភាពសូវៀត មេដឹកនាំសហភាពសូវៀតបានកាប់សម្លាប់និងបង្អត់អាហារប្រជាជនជាច្រើនលាននាក់។ ម៉ៅ សេទុង ក្រោយពីបានរុញច្រានកងទ័ពរបស់ ស៊ុនយ៉ាត់សេន ចេញពីចិនដីគោក គាត់ក៏បានដឹកនាំប្រទេសចិនទាំងមូល។ នៅក្នុងការដឹកនាំនេះ ម៉ៅ សេទុង បានអនុវត្តផែនការសំខាន់ៗពីរ ទី១) គឺចលនាមហាលោតផ្លោះមហាអស្ចារ្យនៅទសវត្សរ៍៥០ ក្នុងគោលបំណងកែប្រែប្រទេសចិនឲ្យក្លាយទៅជាប្រទេសជឿនលឿនមួយក្នុងរយៈពេលដ៏ខ្លី និងដើម្បីកសាងប្រទេសចិនពីភាពខ្ទេចខ្ទាំក្រោយពីសង្គ្រាមជាច្រើនឆ្នាំ ក្នុងនោះ ម៉ៅ សេទុង បានបង្កើតជាការងារនៅក្នុងសហករណ៍ លុបបំបាត់ទ្រព្យសម្បត្តិឯកជននិងធ្វើការងារដោយដៃដើម្បីសម្រេចគោលដៅនេះ។ ប៉ុន្តែវាបានបង្កឲ្យមានគ្រោះទុរ្ភិក្ស និងការស្លាប់បង់ជីវិតរបស់ប្រជាជនចិនជាច្រើនលាននាក់។ នៅទសវត្សរ៍៦០និង៧០ ម៉ៅ សេទុង បានបង្កើតជាចលនាថ្មីមួយទៀត ដែលមានឈ្មោះថាបដិវត្តន៍វប្បធម៌។ នៅក្នុងចលនានេះ ម៉ៅ សេទុង មានបំណងចង់ឲ្យប្រទេសចិនមានភាពស្អាតស្អំទាំងផ្នែកសង្គម សេដ្ឋកិច្ច វប្បធម៌ និងប្រវត្តិសាស្ត្រ។ គាត់បានលុបបំបាត់ចោលអ្វីទាំងអស់ដែលគាត់យល់ថាមានលក្ខណៈប្រតិកិរិយាចំពោះសង្គមកុម្មុយនីស្តចិន និងបំផ្លាញចោលទ្រព្យសម្បត្តិផ្នែកវិចិត្រសិល្បៈ ដូចជារូបគំនូរ រូបចម្លាក់ គម្ពីរធម៌ ទ្រឹស្តីទស្សនវិជ្ជារបស់បញ្ញវន្តដ៏ល្បីល្បាញរបស់ចិន ហើយបានបញ្ជូនអ្នកចេះដឹង អ្នកនយោបាយ គ្រូពេទ្យ គ្រូបង្រៀន សិល្បករ និងកវីជាច្រើននាក់ទៅកាន់ជំរំអប់រំខ្លួននៅតំបន់ស៊ីបេរី។ ចលនាបដិវត្តន៍របស់ ម៉ៅ សេទុង បានធ្វើឲ្យមានភាពរង្គោះរង្គើផ្នែកនយោបាយ ភាពអសន្តិសុខក្នុងប្រទេស ជម្លោះផ្ទៃក្នុង និងការមិនទុកចិត្តគ្នារវាងមេដឹកនាំធំៗ។ ជាលទ្ធផល មនុស្សរាប់លាននាក់បានស្លាប់បាត់បង់ជីវិត។ ចលនាទាំងពីររបស់ចិន (មហាលោតផ្លោះ មហាអស្ចារ្យ និងបដិវត្តន៍វប្បធម៌) ត្រូវបានប្រើប្រាស់ដោយខ្មែរក្រហមក្នុងពេលជាមួយគ្នា និងក្នុងសភាពកាន់តែជ្រុលនិយមជាង។ ហ្គុនណា គួរតែបានអង្កេតឃើញថាខ្មែរក្រហមបានដើរតាមគន្លងខុសឆ្គងពីដំបូងមក។

សរុបមក អ្វីដែលជាបទពិសោធន៍របស់ ហ្គុនណា គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងបទពិសោធន៍របស់ប្រជាជនកម្ពុជាជាច្រើននាក់នៅក្នុងទសវត្សរ៍៥០និង៦០។ ភាពស្រដៀងគ្នានោះ ដោយសារតែមានការគាបសង្កត់ និងភាពអយុត្តិធម៌នៅក្នុងសង្គម ការកេងប្រវ័ញ្ចរបស់ពួកអ្នកមានមកលើអ្នកក្រ ទើបធ្វើឲ្យបញ្ញាជននិងកូនសិស្សមួយចំនួនស្វែងរកមធ្យោបាយថ្មីមួយដែលអាចលុបបំបាត់ចោលនូវភាពអយុត្តិធម៌ទាំងនេះ។ អ្វីដែលមេដឹកនាំខ្មែរក្រហម ដូចជា ប៉ុល ពត, ខៀវ សំផន បានយល់ឃើញថាជាដំណោះស្រាយគឺការអនុវត្តតាមលទ្ធិកុម្មុយនីស្តនិយម ដែលពេលនោះកំពុងតែមានប្រជាប្រិយភាពនៅលើពិភពលោកនិងការគាំទ្រផ្នែកនយោបាយពីប្លុកខាងកើត។ នៅប្រទេសអឺរ៉ុបមួយចំនួន រួមទាំងប្រទេសបារាំង និងប្រទេសស៊ុយអែដមានការធ្វើបាតុកម្មជាច្រើន ធ្វើឡើងដោយកូនសិស្សដើម្បីគាំទ្រលទ្ធិកុម្មុយនីស្ត ដែលក្នុងពេលនោះ ប៉ុល ពត និង ខៀវ សំផន កំពុងតែទទួលការអប់រំ និងបើកចំហគំនិតចំពោះដំណោះស្រាយទាំងឡាយដែលអាចមាន។ ហ្គុនណា ក៏បានឆ្លងកាត់នូវបទពិសោធន៍ដូចគ្នានេះដែរ។ ប៉ុន្តែព្រឹត្តិការណ៍ទាំងនេះពុំអាចសម្រាលទោសរបស់ខ្មែរក្រហមចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើប្រជាជនកម្ពុជាបានឡើយ។ កុម្មុយនីស្តនិយមគឺជាទ្រឹស្តី ចំណែកឯអំពើប្រល័យពូជសាសន៍ជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ។ មេដឹកនាំម្នាក់មិនអាចកាប់សម្លាប់ប្រជាជនស្លូតត្រង់ដើម្បីបំពេញគោលគំនិតមួយដែលខ្លួនឯងយល់ឃើញថាត្រឹមត្រូវសម្រាប់ប្រជាជនមួយក្រុមទៀតបានឡើយ។ ចំពោះ ហ្គុនណា ដែលមិនមែនជាអ្នកនយោបាយ និងគ្រាន់តែជាជនកុម្មុយនីស្តផ្នែកទ្រឹស្តីមួយរូប គាត់គ្មានកំហុសទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់ខ្មែរក្រហមឡើយ។ លើសពីនេះគាត់ពុំបានដឹងថា ខ្មែរក្រហមបានកាប់សម្លាប់ប្រជាជនខ្លួនឯងទេ។ អ្វីដែលគាត់សោកស្តាយគឺការជឿជាក់ដ៏ស្មោះស្ម័គ្ររបស់គាត់ចំពោះលទ្ធិកុម្មុយនីស្តនិយមដែលធ្វើឲ្យគាត់មិនអាចគិតឃើញថា ជនកុម្មុយនីស្តមួយរូបដែលតស៊ូដើម្បីប្រជាជនជាបងប្អូនអាចប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតរបស់មនុស្សជាតិដូច្នេះឡើយ។ **អេង កុកថាយ**

# កំហុសកាលពីសាមសិបឆ្នាំមុន

លោក ហ្គុនណា បឺយស្ត្រម ជាភ្ញៀវបរទេសម្នាក់ក្នុងចំណោមភ្ញៀវដ៏តិចតួចដែលធ្វើដំណើរមកទស្សនកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនាឆ្នាំ១៩៧៨ បានដកគោលជំហររបស់ខ្លួនចេញពីការជឿជាក់ និងគាំទ្ររបបខ្មែរក្រហមតាំងពីសាមសិបឆ្នាំមុន ហើយបានសម្រេចចិត្តវិលត្រឡប់មកប្រទេសកម្ពុជាវិញជាលើកដំបូងដើម្បីនិយាយពាក្យ «សុំទោស» ទៅកាន់ប្រជាជនខ្មែរចំពោះការគាំទ្ររបស់គាត់ក្នុងរបបដ៏ឃោរឃៅដែលបណ្តាលឲ្យប្រជាជនជាងមួយលានប្រាំពីរសែននាក់បានស្លាប់យ៉ាងអាណោចអាធ័មជាទីបំផុតក្នុងអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩ ។ ជាងនេះទៅទៀត ទោះបីជាមានភាពខុសគ្នារវាងវប្បធម៌ និងសាសនាក៏ដោយក៏ ហ្គុនណា នៅតែមានជំនឿចិត្តថានឹងអាចមានការផ្សះផ្សាក្នុងប្រទេសកម្ពុជាដែរ ។ យ៉ាងណាមិញ ហ្គុនណា បានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃ «ការអត់ឱនទោស» ដែលត្រូវបានចាត់ទុកថាជាធាតុផ្សំមួយដែលមិនអាចខ្វះបានសម្រាប់ការផ្សះផ្សាជាតិ ។ ហ្គុនណា បាននិយាយជាមួយលោក លី សុខឃាង និស្សិតថ្នាក់បណ្ឌិតផ្នែកការសិក្សាអន្តរជាតិ និងវិទ្យាសាស្ត្រសង្គមនៃមហាវិទ្យាល័យខូវិនទ្រី ចក្រភពអង់គ្លេស ដោយធ្វើការពន្យល់អំពីការរំពឹងទុក និងការសម្រេចចិត្តរបស់គាត់ក្នុងការវិលត្រឡប់មកវិញនេះ ។ ខាងក្រោមនេះគឺជាការសន្ទនារវាងលោក ហ្គុនណា និងលោក លី សុខឃាងៈ

**លោកធ្លាប់ធ្វើការគាំទ្ររបបខ្មែរក្រហមអស់រយៈពេលប៉ុន្មានឆ្នាំមកនេះ ដូច្នេះខ្ញុំចង់សួរលោកថាតើហេតុអ្វីបានជាលោកជឿជាក់ទៅលើរបបនេះ?**

នៅពេលនោះខ្ញុំគិតថា ខ្មែរក្រហមគឺជាអ្នកប្រយុទ្ធដើម្បី



ហ្គុនណា បឺយស្ត្រម កំពុងឈរមើលការតាំងពិព័រណ៍នៅទួលស្លែង

សេរីភាព ហើយគេបានកំពុងតែប្រយុទ្ធប្រឆាំងទៅនឹងសហរដ្ឋអាមេរិក និងរបប លន់ នល់ ។ យើងគិតថាខ្មែរក្រហមពិតជាសង្គមប្រជាធិបតេយ្យមួយដោយប្រជាជនទាំងអស់មានភាពស្មើគ្នាម្យ៉ាងវិញទៀត មានសហករណ៍ដ៏អស្ចារ្យ ប្រពន្ធ័ធារាសាស្ត្រ ហើយអ្វីៗទាំងអស់ពឹងផ្អែកទៅលើខ្លួនឯងដែលមិនមែនជាជំនួយបរទេស ។ អាស្រ័យហេតុនេះហើយ ទើបយើងមានការជឿជាក់ទៅលើខ្មែរក្រហម ។

**តើលោកអាចធ្វើការពន្យល់អំពីលទ្ធិម៉ៅបានទេ?**

របបខ្មែរក្រហមជាកំណែទម្រង់ថ្មីដ៏ហួសហេតុមួយ ហើយខ្ញុំគិតថាប្រសិនបើខ្ញុំជាអ្នកកាន់លទ្ធិម៉ៅវិញ នោះខ្ញុំអាចនិយាយបានថាខ្មែរក្រហមបានយល់ខុសអំពីលទ្ធិម៉ៅហើយ ។ បើតាមខ្ញុំគិតលទ្ធិម៉ៅតែងតែដឹកនាំទៅរកអំណាចផ្តាច់ការ ប៉ុន្តែចំពោះខ្មែរក្រហមវិញខ្លាំងក្លាជាងហ្នឹងទៅទៀត ។ ខ្មែរក្រហមបានគិតថា គេអាចរំលងដំណាក់កាលខ្លះនៃដំណើរការបដិវត្តន៍ដោយឈានទៅរកលទ្ធិកុម្មុយនីស្តតែម្តង ។ តាមខ្ញុំគិត ដោយសារតែខ្មែរក្រហមឈានទៅមុខខ្លាំងហួសហេតុពេក ទើបជាហេតុធ្វើឲ្យក្លាយទៅជាឆាកប្រយុទ្ធដ៏សាហាវឃោរឃៅបំផុត ។

ខ្ញុំចាប់អារម្មណ៍ខ្លាំងណាស់ចំពោះការថ្លែងសុន្ទរកថារបស់លោកនៅក្នុងសិក្ខាសាលា និងនៅសហគមន៍អ៊ីស្លាមក្នុងខេត្តកំពង់ចាម ។ តើលោកគិតថាប្រជាជនមានសេចក្តីសប្បាយរីករាយទេពេលដែលលោកនិយាយពាក្យ «សុំទោស» ទៅកាន់ពួកគាត់?

ខ្ញុំយល់ឃើញដូច្នោះដែរ ។ ខ្ញុំមិនបានដឹងថា វប្បធម៌ខ្មែរយ៉ាងណានោះទេ ក៏ប៉ុន្តែខ្ញុំមិនគិតថា ការនិយាយពាក្យសុំទោស គឺមិនតំណាងឲ្យអ្វីទាំងអស់ ប៉ុន្តែវាគឺជារឿងដ៏ធំមួយសម្រាប់ខ្ញុំ ហើយមើលទៅប្រជាជនភាគច្រើនទទួលយកការសុំទោសនេះ ។

**តើប្រតិកម្មរបស់ប្រជាជនកម្ពុជាចំពោះពាក្យថា «សុំទោស» នេះមានអ្វីខ្លះ ហើយតើលោកគិតថាប្រជាជនទាំងអស់មានអារម្មណ៍ស្រុះស្រួលចំពោះពាក្យនេះដែរឬទេនៅពេលដែលគាត់ស្តាប់ឮសម្តីចេញពីមាត់របស់លោកដោយផ្ទាល់?**

ខ្ញុំមិនបានដឹងច្បាស់អំពីវប្បធម៌នៃការនិយាយ «សុំទោស» នៅក្នុងប្រទេសកម្ពុជានោះទេ ប៉ុន្តែខ្ញុំដឹងថា មានការងារខ្លះដែលខ្ញុំបានធ្វើខុសហើយ ខ្ញុំពិតជាសុំទោសចំពោះកំហុសទាំងអស់នោះ ។ ខ្ញុំសង្ឃឹមថា ប្រសិនបើខ្ញុំនិយាយនោះវានឹងអាចជួយឲ្យប្រជាជនមានអារម្មណ៍ធូរស្បើយជាងមុន ។ ចំពោះប្រតិកម្មរបស់ប្រជាជននៅសហគមន៍អ៊ីស្លាមកាលពីម្សិលមិញមានលក្ខណៈខុសគ្នាបន្តិចដោយប្រជាជនឆាប់ទទួលយកការសុំទោសនេះលឿនពេក គាត់គួរតែគិតឲ្យបានយូរបន្តិច ។

**តើលោកគិតថា នេះគឺជាដំណើរការនៃការផ្សះផ្សា ឬការរួមរស់ជាមួយគ្នា?**

ខ្ញុំគិតថាការអត់ឱនទោសខ្លះមានសារសំខាន់ណាស់ ពីព្រោះខ្ញុំមិនគិតថាអ្នកអាចកាត់ទោសឧក្រិដ្ឋជនដែលប្រព្រឹត្តបទល្មើសទាំងអស់នោះទេ យ៉ាងណាមិញគេគួរតែទទួលខុសត្រូវ ។ គេគួរតែព្យាយាម ប៉ុន្តែវាមិនអាចមានការកាត់ទោសខ្មែរក្រហមទាំងអស់ក្នុងភូមិមួយៗបានទេ ព្រោះធ្វើបែបនេះគឺគ្មានថ្ងៃបញ្ចប់ឡើយ ។ ប៉ុន្តែប្រសិនបើអ្នកចង់អត់ឱនទោសឲ្យខ្មែរក្រហម ដំបូងគេត្រូវតែនិយាយពាក្យថា «ខ្ញុំធ្វើខុស» ជាមុនសិន ។ ប៉ុន្តែដើម្បីឲ្យគេ (ខ្មែរក្រហម) និយាយពាក្យថា «ខ្ញុំធ្វើខុស» គេចាំបាច់ត្រូវការជំនឿចិត្ត ដែលថាគេ



ពិព័រណ៍ឋាននរកកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៨ នៅសារមន្ទីរទួលស្លែង

ពិតជាត្រូវបានលើកលែងទោសមែន អ៊ីចឹងទើបម្នាក់ៗនឹងមិនគិតថាវាមានបុព្វហេតុអាក្រក់ជារៀងរហូត ។ ប្រសិនបើខ្ញុំនិយាយពាក្យថា «សុំទោស» ទៅកាន់ប្រជាជន នោះជារឿងងាយស្រួលមួយសម្រាប់ខ្ញុំ ពីព្រោះខ្ញុំមិនបានរស់នៅទីនេះទេ ប៉ុន្តែចំពោះឧក្រិដ្ឋជនទាំងនោះគេរស់នៅក្នុងទឹកដីកម្ពុជា ដូច្នោះពួកគេមិនអាចមកនិយាយប្រាប់ថា ខ្ញុំជាខ្មែរក្រហម ខ្ញុំបានធ្វើកំហុសឆ្គងខ្លះ ហើយខ្ញុំពិតជាចង់សុំទោសណាស់នោះទេ ។ ខ្មែរក្រហមគេត្រូវតែជឿជាក់ថា ប្រជាជននឹងអត់ឱនទោសឲ្យគេ ដូច្នេះទើបគេអាចដឹងពីរបៀបដើម្បីរួមរស់ក្នុងស្ថានភាពខុសប្លែកគ្នានេះ ។ យ៉ាងណាមិញ ខ្ញុំមិនមែនជាអ្នកជំនាញខាងវប្បធម៌របស់ប្រជាជនកម្ពុជានោះទេ ។

**តើលោកគិតថា ការផ្សះផ្សាអាចកើតឡើងរវាងប្រជាជនដែលកាន់សាសនា និងវប្បធម៌ផ្សេងគ្នាដែរឬទេ?**

ខ្ញុំគិតថាការផ្សះផ្សាជាតិគឺតែងតែងមានជានិច្ច ។ គ្រប់វប្បធម៌ និងសាសនាទាំងឡាយសុទ្ធតែមានគោលគំនិតមួយដើម្បីដោះស្រាយនៅពេលដែលធ្វើអ្វីមួយខុសឆ្គង ។ គ្រប់ពេលដែលយើងធ្វើខុស ឬមួយក៏បន្ទំគេ នោះមានន័យថា យើងបានឃ្លាតឆ្ងាយពីព្រះទៅហើយ តែនៅពេលដែលយើងធ្វើអ្វីមួយត្រឹមត្រូវ នោះយើងកំពុងតែនៅជិតព្រះ ហើយពេលដែលយើងជិតស្លាប់ យើងគួរតែចូលទៅជិតព្រះ ។ គ្រប់ពេលដែលយើងនិយាយពាក្យពិត និង «សុំទោស» នោះគឺយើងបានចូលទៅជិតព្រះហើយ ។ នេះជាគោលគំនិតមួយនៅញូវហ្សេឡែន ហើយក៏ជាគោលគំនិតមួយដែរសម្រាប់ប្រទេសស៊ុយអែដ ប៉ុន្តែខ្ញុំគិតថា គំនិតនេះតែងតែត្រូវបានយកមកប្រើប្រាស់ជានិច្ចនៅពេលដែលយើងបានធ្វើអ្វីមួយខុសឆ្គង ។

**តើលោកគិតថា សំណងអាចជំនួសការអត់ឱនទោសបានឬទេ?**

ខ្ញុំគិតអ៊ីចឹងដែរ ប៉ុន្តែយើងមិនអាចបញ្ជាឲ្យប្រជាជនអនុគ្រោះទោសឲ្យនោះទេ ។ គេត្រូវតែមានឱកាសស្តាប់ និងខឹងជាមុនសិន ។ ប្រជាជនត្រូវតែមានអារម្មណ៍ថា អ្វីៗមួយចំនួនត្រូវបានដោះស្រាយ ដូចជាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយស្ថិតក្នុងទំនាក់ទំនងបែបនេះ ប្រសិនបើយើងមិនអត់ឱនទោស នោះគំនុំនឹងដក់ជាប់ក្នុងខួរក្បាលរបស់យើងដដែល ។

**ប្រសិនបើប្រជាជនកម្ពុជាអត់ឱនទោសឲ្យលោក តើលោកអាចបំភ្លេចចោលកំហុសឆ្គងនោះដែរឬទេ?**

វាប្រហែលជាអាច ប៉ុន្តែខ្ញុំមិនដឹងច្បាស់នោះទេ វាស្ថិតនៅលើការសម្រេចចិត្តរបស់ខ្ញុំ ។ ទោះបីជាមានកំហុសឆ្គងមួយកាលពីសាមសិបឆ្នាំមុន ប៉ុន្តែអ្វីៗគឺបានកន្លងផុតទៅហើយ ។ ប្រហែលជាយើងអាចលាងជម្រះខ្លួនយើងបាន ខ្ញុំមានអារម្មណ៍ថាថ្ងៃណាមួយខ្ញុំនឹងអាចធ្វើបាន ។ ទាំងនេះគឺជាអ្វីដែលខ្ញុំអាចធ្វើទៅបាន ខ្ញុំមិនអាចធ្វើអ្វីឲ្យច្រើនជាងនេះទៀតទេ ។ អ៊ីចឹងខ្ញុំត្រូវតែកែប្រែ ឬក៏កំហុស ឬមួយក៏ធ្វើអ្វីមួយក៏ដោយតាមតែអ្នកគិត ពីព្រោះខ្ញុំមិនអាចធ្វើអ្វីបានច្រើនជាងនេះទៀតទេ ។

**ក្នុងនាមជាអ្នកចិត្តសាស្ត្រមួយរូប តើលោកអាចពិពណ៌នាអំពីរបៀបដែលអ្នកនៅរស់ពីរបបខ្មែរក្រហមដោះស្រាយជាមួយនឹងជំងឺផ្លូវចិត្តដែរឬទេ?**

ខ្ញុំមិនមែនជាអ្នកជំនាញខាងបញ្ហានោះទេ ប៉ុន្តែនេះគឺហៅថា «ការជាសះស្បើយពីជំងឺផ្លូវចិត្ត» ខ្ញុំធ្លាប់ធ្វើការជាមួយមនុស្សដែលមានជំងឺផ្លូវចិត្ត ហើយអ្វីដែលខ្ញុំបានដឹងនោះ គឺអ្នកត្រូវការនិយាយអំពីរឿងទាំងនោះចេញមកក្រៅ ហើយប្រហែលជាអ្នកយំខ្លាំងណាស់ ។ គេត្រូវការព្យាបាលដោយទឹកភ្នែក ប្រហែលគេនិយាយរឿងដ៏ឈឺចាប់នោះជាច្រើនដង ហើយមានអ្នកចាំស្តាប់រឿងទាំងនោះ ដោយទទួលស្គាល់ថារឿងនេះគឺជាការពិត បន្ទាប់ពីគេបាននិយាយរឿងទុក្ខសោកនេះបន្តបន្ទាប់ទៀត គេនឹងអាចយំតិចជាងរាល់ដង ។ គេគួរតែទទួលជំនួយព្យាបាលពីអ្នកជំនាញជាងនេះ ។ ខ្ញុំបានឮថាមានប្រជាជនខ្មែរមួយចំនួនមានលក្ខណៈបែបនេះ ហើយគេពិតជាអាចជាសះស្បើយមែន ។ តែប្រហែលជាដំណាក់កាលនៃការព្យាបាលរបស់ខ្មែរមានលក្ខណៈខុសគ្នាពីលោកខាងលិច ។

**កន្លងមកនេះ តើការធ្វើទស្សនកិច្ចមួយនេះឈានទៅដល់ការរំពឹងទុករបស់លោកដែរឬទេ?**

វាគឺហួសពីការគិតរបស់ខ្ញុំទៅទៀត ពីព្រោះវាមានប្រយោជន៍ និងឱកាសជាច្រើនក្នុងការនិយាយពាក្យ «សុំទោស» នោះខ្ញុំអាចទំនាក់ទំនងជាមួយប្រជាជនជាច្រើន ។ ចំពោះប្រតិកម្មរបស់គាត់គឺពិតជាល្អណាស់ ។ ខ្ញុំគិតថាប្រជាជនមានសិទ្ធិខឹងនឹងខ្ញុំ ហើយប្រហែលជាអាចវាយប្រហារខ្ញុំ ។ ប៉ុន្តែគេមិនធ្វើដូច្នេះទេ ខ្ញុំគិតថាប្រជាជនខ្មែរពិតជាមនុស្សដ៏អស្ចារ្យមែន ។ **លី សុខឃាង**

# ហ្គ្រានណា ជួបជាមួយ ប៉ុល ពត និង អៀង សារី

នៅពេលដែលយើងទៅដល់ប្រទេសកម្ពុជា យើងបានលើកសំណើមួយចំនួនលើសពីកាលវិភាគដែលបានរៀបចំ ។ យើងសុំសម្រាកនៅសហករណ៍ពីរឬបីយប់ មិនមែនគ្រាន់តែទៅមើលពីរ-បីម៉ោងទេ ។ ខ្មែរក្រហមបដិសេធ ។ យើងសុំសម្ភាសន៍ ខៀវ ប៉ុណ្ណារី ប្រពន្ធរបស់ ប៉ុល ពត និងជាប្រធានសមាគមនារី ។ ពេលខ្លះខ្ញុំសង្ស័យថាសមាគមទាំងប៉ុន្មានដែលខ្មែរក្រហមបាននិយាយប្រាប់យើងនោះ មិនមានរូបរាងពិតប្រាកដទេ ។ កាលនោះយើងមិនដឹងសោះថា ខៀវ ប៉ុណ្ណារី មានជំងឺធ្ងន់ធ្ងរ ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងជួបគាត់ ។ យើងក៏បានសុំសម្ភាសន៍ ប៉ុល ពត ហើយមិនបានទទួលចម្លើយភ្លាមៗទេ ។ ខ្មែរក្រហមប្រាប់យើងឲ្យផ្ញើសំណួរទៅមុន ។ យើងស៊ាំនឹងទម្លាប់បែបនេះទៅហើយ ពីព្រោះកុម្មុយនីស្តវៀតណាមនិងចិនក៏អនុវត្តដូចគ្នាដែរ ។ បណ្តាមេដឹកនាំកុម្មុយនីស្តទាំងនោះចង់ត្រៀមចម្លើយទុកជាមុន និងមិនចង់ជាប់កុននិយាយអ្វីដែលមិនគួរនិយាយ ។

ពីរ-បីថ្ងៃក្រោយមក ខណៈពេលដែលស្ត្រីពីរនាក់នៅក្នុងក្រុមរបស់យើងចេញដើរលេងនៅក្នុងទីក្រុង រថយន្តហ្ស៊ីបមួយមកដល់ដោយមានមគ្គុទ្ទេសក៍របស់យើងនៅក្នុងនោះ ។ មគ្គុទ្ទេសក៍ប្រាប់យើងឲ្យរៀបចំខ្លួនដើម្បីទៅជួប ប៉ុល ពត ក្នុងរយៈពេលពីរ-បីម៉ោងខាងមុខ ។ យើងនិយាយថា ស្ត្រីពីរនាក់ទៀតមិននៅផ្ទះទេ ប៉ុន្តែគាត់ប្រាប់យើងកុំឲ្យបារម្ភ ។ មួយនាទីក្រោយមកខ្មែរក្រហមដឹកស្ត្រីទាំងពីរនាក់មកដល់ផ្ទះវិញ ។ ស្ត្រីទាំងពីរមិនយល់ទាល់តែសោះថាហេតុអ្វីក៏គាត់ត្រូវហៅឡើងឡានដឹកត្រឡប់មកផ្ទះវិញ ពីព្រោះអ្នកបើកឡាននិងកងសន្តិសុខខ្មែរក្រហមនិយាយតែភាសាខ្មែរ ។

រថយន្តដឹកយើងទៅវិមានប្រធានាធិបតី ។ បទសម្ភាសន៍ចាប់ផ្តើមដោយ ប៉ុល ពត អានចម្លើយនៅលើក្រដាសឆ្លើយតបទៅនឹងសំណួរដែលយើងបានផ្ញើឲ្យ ។ គាត់មានបុកពាផ្លូវការជាទីបំផុត ប៉ុន្តែចម្លើយរបស់គាត់គ្មានអ្វីថ្មីទាល់តែសោះ ។ គាត់ឆ្ងៀតពេលនិយាយអំពី«ភ្នាក់ងារ» នៅក្នុងប្រទេសកម្ពុជាដែលបំផ្លិចបំផ្លាញបដិវត្តន៍ ។ យើងកាត់យល់ថាគាត់និយាយអំពីវៀតណាម ក៏ប៉ុន្តែពេលដែលគាត់បន្តនិយាយមិនល្អប្រឆាំងនឹងកម្មាភិបាលនៅក្នុងជួរបក្ស ខ្ញុំយល់ថានោះគឺជាសញ្ញានៃការមិនទុកចិត្តគ្នា ។ រដ្ឋមន្ត្រីក្រសួងការបរទេស អៀង សារី ក៏មានវត្តមាននៅក្នុងអង្គប្រជុំនោះដែរ ប៉ុន្តែគាត់មិនបញ្ចេញយោបល់ឬកាត់ប្រសាសន៍របស់ ប៉ុល ពត ទេ ។ ប៉ុល ពត និយាយជាភាសាខ្មែរ ហើយអ្នកបកប្រែបកទៅជាភាសាបារាំង ។ យើងសួរគាត់អំពីពាក្យចចាមអារ៉ាមទាំងឡាយគាត់បដិសេធចោលទាំងអស់ ។

បន្ទាប់ពីបទសម្ភាសន៍ជាផ្លូវការដែលគណៈប្រតិភូយើងបានថតសម្រាប់ចាក់ផ្សាយនៅទូរទស្សន៍ស៊ុយអែដ យើងត្រូវបានអញ្ជើញទៅទទួលទានអាហារពេលល្ងាចនៅក្នុងបន្ទប់ជាប់នោះ ។ តាមដែលខ្ញុំចាំ ម្ហូបដែលយើងទទួលទាន គ្រាំ ត្រី និងបាយ ។ ក្នុងពេលទទួលទានអាហារ យើងអាចនិយាយដោយសេរីនិងចំហជាងមុន ហើយ អៀង សារី ក៏ចូលរួមក្នុងកិច្ចសន្ទនាដែរ ។ កិច្ចសន្ទនាគឺអំពីការឃោសនានយោបាយរបស់ចក្រពត្តិប្រឆាំងនឹងខ្មែរក្រហម និងអំពីមូលហេតុដែលនាំឲ្យបដិវត្តន៍កម្ពុជាខុសប្លែកពីបដិវត្តន៍ដទៃ ។ ប៉ុល ពត នៅតែថ្លែងសុន្ទរកថាច្រើនជាងបញ្ចេញយោបល់របស់គាត់ ។ ត្រង់នេះធ្វើឲ្យគាត់គ្មានអ្វីខុសប្លែកអំពីមេដឹកនាំកុម្មុយនីស្តផ្សេងទៀតដែលខ្ញុំធ្លាប់បានជួបទេ គឺរបៀបតែមួយ ។ នៅអំឡុងពេលបាយ ដោយធុញទ្រាន់នឹងស្តាប់ការបកប្រែភាសាបារាំងដែលគាត់ខ្លួនឯងក៏ចេះដែរនោះ ប៉ុល ពត ក៏សុំឲ្យបញ្ឈប់ការបកប្រែ ក៏ប៉ុន្តែគាត់នៅតែឆ្លើយជាភាសាខ្មែរ ទោះជាគាត់អាចនិយាយភាសាបារាំងបានក៏ដោយ ។

ចន្លោះពេលនោះ ខ្ញុំទៅបន្ទប់ទឹកជាមួយ អៀង សារី ។ ពេលដែលយើងនៅតែពីរនាក់ អៀង សារី និយាយភាសាបារាំង ។ គាត់ប្រាប់ខ្ញុំថាគាត់បានទទួលសំណើពីស្ថានីយទូរទស្សន៍លេខ២ របស់ស៊ុយអែដ សុំមកធ្វើទស្សនកិច្ចនិងថតភាពយន្តឯកសារនៅប្រទេសកម្ពុជា ។ គាត់សួរខ្ញុំថាតើគាត់គួរអនុញ្ញាតដែរឬទេ ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំយល់ថាការបើកឲ្យអ្នកកាសែតចូលមកគឺជាការ

ប្រសើរ ។ ខ្ញុំព្យាយាមប្រាប់គាត់ថា ការបិទមិនឲ្យអ្នកសារព័ត៌មានចូលមកក្នុងប្រទេសកម្ពុជានឹងបង្កើតឲ្យមានការមន្ទិលសង្ស័យថាគាត់មានអ្វីដែលលាក់បាំង ។ ខ្ញុំមិនដឹងថាគាត់ស្តាប់ខ្ញុំឬអត់ទេ ។

នៅតាមផ្លូវត្រឡប់មកផ្ទះសំណាក់របស់យើងវិញ ខ្មែរក្រហមសួរខ្ញុំថាតើខ្ញុំយល់ឃើញយ៉ាងម៉េចចំពោះ«បងទី១» ។ នេះជាលើកទីមួយដែលខ្ញុំបានឮពាក្យ«បងទី១» ខ្ញុំមានការភ្ញាក់ផ្អើលចំពោះពាក្យនេះនិងចំពោះសំណួរ ។ តាំងពីដើមទីមកបដិវត្តន៍កម្ពុជាខុសប្លែកពីបដិវត្តន៍ចិន វៀតណាម និងកូរ៉េ ត្រង់ថាគ្មានការលើកទឹកចិត្តឲ្យប្រជាជនគោរពបូជាមេដឹកនាំ ។ នៅក្នុងដំណើរទស្សនកិច្ចទាំងមូល យើងមិនបានឃើញរូបថតរបស់ ប៉ុល ពត នៅកន្លែងណាមួយទាល់តែសោះ ។ តាមពិតមេដឹកនាំខ្មែរក្រហមច្រើនតែមិនបញ្ចេញមុខនិងឈ្មោះ ។ ប្រជាជនកម្ពុជាជាច្រើនមិនដែលដឹងទាល់តែសោះថា ប៉ុល ពត ជានរណា? ក៏ប៉ុន្តែប្រហែលជាខ្មែរក្រហមមានគម្រោងឲ្យមានការគោរពបូជាថ្នាក់ដឹកនាំ ។ ការពិតដែលថាខ្មែរក្រហមទុកជីវិតឲ្យ វ៉ាន់ ណាត នៅគុកទួលស្លែងឲ្យគូររូប របស់ ប៉ុល ពត មានន័យថាបដិវត្តន៍មានគម្រោងឃោសនាឲ្យមានការគោរពបូជា ប៉ុល ពត ។

ដូច្នេះ តើខ្ញុំឆ្លើយយ៉ាងម៉េច? ប៉ុល ពត មិនដែលបង្ហាញភាពអស្ចារ្យទាល់តែសោះ ។ គាត់និយាយយឺតៗ ហើយអ្វីដែលគាត់បាននិយាយផ្តល់ព័ត៌មានតិចតួចបំផុត ។ ក្នុងអំឡុងពេលជួបប្រជុំកាម៉េរ៉ាវីដេអូថតយើងរហូត ហើយអាហារពេលល្ងាចក៏មានលក្ខណៈជាផ្លូវការ ។ ដូច្នេះខ្ញុំមិនអាចនិយាយថាគាត់អស្ចារ្យបានទេ ។ ខ្ញុំឆ្លើយតាមរបៀបគួរសមអំពីសមិទ្ធផលបដិវត្តន៍របស់គាត់ ។

មនុស្សជាច្រើនសួរគ្នាថាតើ ប៉ុល ពត មានជំងឺវិកលចរិតឬអត់? ជួនកាលខ្ញុំឃើញមនុស្សពិភាក្សាគ្នាអំពីថាតើជំងឺវិកលចរិតរបស់គាត់ស្ថិតនៅក្នុងប្រភេទមួយណា ។ មានអ្នកខ្លះសួរខ្ញុំថា ពេលដែលខ្ញុំជួបជាមួយ ប៉ុល ពត តើខ្ញុំមានសម្គាល់ឃើញថាគាត់មានសភាពមិនប្រក្រតីដែរឬទេ? ខ្ញុំយល់ថាគាត់មើលទៅខុសប្រក្រតីបើនិយាយឲ្យសាមញ្ញ ។ ក៏ប៉ុន្តែគាត់ត្រូវតែប្រឈមមុខនឹងតុលាការនិងទទួលខុសត្រូវចំពោះអ្វីដែលគាត់បានធ្វើ ។ ខ្ញុំជឿជាក់ថា គាត់គិតថាខ្លួនគាត់មានសារសំខាន់ខណៈដែលការពិតគាត់មិនសូវសំខាន់ ។ នេះមិនមែនជាការសរុបសេចក្តីចេញអំពីការជួបប្រជុំរវាងខ្ញុំនិងគាត់ទេ ក៏ប៉ុន្តែផ្អែកទៅលើព័ត៌មានផ្សេងៗទៀត ។ ភាពមិនប្រក្រតីទាំងនេះចាប់ផ្តើមដំបូងបង្អស់ បន្ទាប់មកវានាំទៅដល់ការចាត់ទុកថាអ្នកដែលប្រឆាំងនឹងខ្លួនជាសត្រូវហើយចោទប្រកាន់ប្រជាជនថាជាភ្នាក់ងារបរទេស ។ ការមិនទុកចិត្តនេះស្រដៀងទៅនឹងរបបដឹកនាំរបស់ ស្តាលីន នៅសហភាពសូវៀត ។ ទាំង ស្តាលីន ទាំង ប៉ុល ពត មើលឃើញសត្រូវនៅគ្រប់ទីកន្លែងទាំងអស់និងមិនអាចអត់ឱនចំពោះអ្នកដែលប្រឆាំងនឹងខ្លួនទោះជាក្នុងរូបភាពណាក៏ដោយ ។ ខ្ញុំគិតថាអំណាចធ្វើឲ្យមនុស្សដើរខុស ហើយនៅទីបំផុត ប៉ុល ពត ចង់ឲ្យប្រជាជនគោរពបូជាគាត់និងមានបំណងដាក់តាំងរូបសំណាកដ៏ធំសម្បើមរបស់គាត់នៅវត្តភ្នំ ។ នៅពេលដែលកងទ័ពវៀតណាមកំពុងតែសម្រុកចូលទីក្រុងភ្នំពេញនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ ប៉ុល ពត និយាយប្រាប់សម្តេចសីហនុ និងភ្ញៀវរបស់គាត់ អំពីការវាយរំលំវៀតណាម និងបន្តនិយាយរាប់ម៉ោងអំពីគម្រោងការដ៏សែនឆ្លាតរបស់គាត់ ។ គាត់បានបាត់ទំនាក់ទំនងជាមួយនឹងការពិតអស់ទៅហើយ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**



# សិក្ខាសាលា និងការតាំងពិព័រណ៍រូបថតនៅទីក្រុងភ្នំពេញ

នៅខែមេសា ឆ្នាំ១៩៧៨ លោក ហ្គុនណា បឺយស្ត្រម បានមកដល់កម្ពុជា ដែលក្នុងដំណើរទស្សនកិច្ចរយៈពេល១៨ថ្ងៃនៅទីជនបទនៃប្រទេសនេះមានការអញ្ជើញពី ប៉ុល ពត និងគណៈប្រតិភូរបស់គាត់ ។ ហ្គុនណា និងគណៈប្រតិភូ៣នាក់ផ្សេងទៀតមកពីសហគមន៍មិត្តភាពកម្ពុជា-ស៊ុយអែដ បានធ្វើដំណើរតាមយន្តហោះពីទីក្រុងប៉េកាំងមកកាន់ទីក្រុងភ្នំពេញ រួមជាមួយនឹងក្រុមរបាំរូម៉ានីមួយក្រុមបានមកចុះចតនៅព្រលានយន្តហោះពោធិ៍ចិនតុងដែរ ។ នៅក្នុងទីក្រុងដ៏ស្ងាត់ជ្រងំនេះ ក្រុមគណៈប្រតិភូបានទទួលការស្វាគមន៍ពីសំណាក់កម្មាភិបាលខ្មែរក្រហមពីរបីនាក់ បន្ទាប់មកខ្មែរក្រហមបាននាំក្រុមនេះធ្វើដំណើរទស្សនកិច្ចរយៈពេល១៨ថ្ងៃជុំវិញទីជនបទនៃប្រទេសកម្ពុជា ។

ក្រុមគណៈប្រតិភូដែលអមដំណើរដោយអ្នកបើករថយន្តនិងកម្មាភិបាលខ្មែរក្រហមនាំផ្លូវម្នាក់ទៀតបានទៅទស្សនាសាលារៀន មន្ទីរពេទ្យ និងរោងចក្រជាច្រើន ។ គណៈប្រតិភូបានឃើញប្រជាជនកម្ពុជាស្ទូងស្រូវនៅវាលស្រែ និងបានជួបជាមួយប្រជាជនទាំងនោះ ហើយបានថតរូបគេដែលកំពុងញញឹមសើចសប្បាយរីករាយនិងមានសុខភាពល្អ ។

ជនជាតិស៊ុយអែដបានអះអាងថា គ្មានការធ្វើទារុណកម្ម គ្មានការអត់ឃ្លាននិងមិនមានភាពក្រីក្រទេ ។ ក្រុមគណៈប្រតិភូត្រូវបានខ្មែរក្រហមអនុញ្ញាតឲ្យដើរដោយសេរីនៅក្នុងទីក្រុងដ៏ស្ងាត់ជ្រងំ ហើយជាញឹកញាប់បានស្នាក់នៅផ្ទះដែលប្រជាជនបោះបង់ចោល និងសម្រាកនៅលើគ្រែរបស់ប្រជាជនដែលខ្មែរក្រហមបង្ខំជម្លៀសចេញពីផ្ទះ ។ ខ្មែរក្រហមបានជប់លៀងឲ្យក្រុមគណៈប្រតិភូនិងទទួលទានអាហារពេលល្ងាចនៅក្នុងព្រះបរមរាជវាំងរួមជាមួយ ប៉ុល ពត និង អៀង សារី ដែលជាមេខ្លោងនៅពីក្រោយការសម្លាប់រង្គាល ។

នៅថ្ងៃអាទិត្យនេះ ហ្គុនណា បានត្រឡប់មកប្រទេសកម្ពុជាសាជាថ្មី នឹងជាលើកដំបូងចាប់តាំងពីគណៈប្រតិភូរបស់គាត់បាន



សិក្ខាសាលានៅវិទ្យាស្ថានជាតិអប់រំ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨




ភ្ញៀវចូលរួមពិធីបើកពិព័រណ៍ ឋាននរកក

មកធ្វើទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជាកាលពី៣០ឆ្នាំមុន ។ នៅព្រឹកនេះ ហ្គុនណា បាននិយាយទៅកាន់ប្រជាជនកម្ពុជានិងជនបរទេសជាង៣០០នាក់ នៅឯវិទ្យាស្ថានជាតិអប់រំ ហើយពេលល្ងាចនៅវិទ្យាស្ថានរ៉េយ៉ំក្នុងទីក្រុងភ្នំពេញ ។ នៅអំឡុងពេលជជែកពិភាក្សាក្នុងសិក្ខាសាលា ហ្គុនណា បានរៀបរាប់យ៉ាងលម្អិតអំពីដំណើរទស្សនកិច្ចរបស់គាត់មកប្រទេសកម្ពុជានៅឆ្នាំ១៩៧៨ ដោយបានពន្យល់ពីអ្វីដែលគាត់បានធ្វើ និងមិនបានធ្វើ ហើយបានបដិសេធ មិនឃើញ និងជាចុងក្រោយបានសុំខមាទោសដោយផ្ទាល់ចំពោះប្រជាជនកម្ពុជាសម្រាប់ការវិនិច្ឆ័យប្រទ្បំដ៏ធ្ងន់ធ្ងររបស់គាត់ ។

ការពិភាក្សាគ្នានៅក្នុងសិក្ខាសាលានេះ គឺជាលើកដំបូងដែលនិយាយពីដំណើរទស្សនកិច្ចរបស់ ហ្គុនណា នៅក្នុងឋាននរករស់ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយកម្មវិធីប្រវត្តិសាស្ត្ររស់នៅទីក្រុងស្តុកខូម ប្រទេសស៊ុយអែដ ។ ទាក់ទងជាមួយសិក្ខាសាលានេះ ការតាំងពិព័រណ៍រូបភាពពីឆ្នាំ១៩៧៨របស់ ហ្គុនណា បឺយស្ត្រម បានបើកនៅថ្ងៃនេះផងដែរ ទាំងនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងវិទ្យាស្ថានរ៉េយ៉ំក្នុងទីក្រុងភ្នំពេញ ។

## ឃើញ ប៉ុមិនឃើញ

នៅអំឡុងពេលបើកសិក្ខាសាលានៅព្រឹកនេះ ហ្គុនណា បានរៀបរាប់ប្រាប់ដល់អ្នកស្តាប់អំពីទីក្រុងខ្មោច សាលារៀន មន្ទីរពេទ្យ និងរោងចក្រដែលគាត់បានទៅមើល និងអាហារពេលល្ងាចដែលគាត់បានបរិភោគនៅក្នុងព្រះបរមរាជវាំង ។ ហ្គុនណា បានសារភាពថា «យើងបានចាប់អារម្មណ៍លើការឃោសនារបស់ខ្មែរក្រហមមួយចំនួន ផ្អែកលើភាពខ្លាំងដោយមិនទទួលជំនួយពីបរទេស និងផ្អែកលើផលដំណាំ» ។ គាត់ក៏បាននិយាយសរសើរគោលការណ៍ហូបបាយរួមរបស់ខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៨ផងដែរ ។

បឺយស្ត្រម បានពន្យល់ប្រាប់ទៅដល់អ្នកស្តាប់កាលពីព្រឹកថា «ខ្ញុំគិតថាវាគឺជាដំណោះស្រាយដ៏ប្រសើរបំផុតចំពោះបញ្ហាខ្វះម្ហូបអាហារនៅក្នុងប្រទេសតតិយលោកមួយនេះ» ។ អំឡុងពេលដែលកំពុងបង្ហាញរូបភាពនារីកម្ពុជាមួយរូបដ៏ស្រស់ស្អាតកំពុងញញឹម ហ្គុនណា បានប្រាប់ដល់អ្នកស្តាប់ថា កន្លែងនេះ និងរូបថតមួយនេះហើយដែល «ធ្វើឲ្យគាត់មានគំនិតគាំទ្រខ្មែរក្រហម» ។

ហ្គុនណា បានពន្យល់ប្រាប់អ្នកស្តាប់ថា ប៉ុន្តែនេះមិនមែនមានន័យថាគាត់មិនឆ្ងល់នៅពេលនោះទេ ។ គាត់មិនបានគាំទ្រការ



ម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាស្ថានរ៉េយ៉ំ


ហ្គុនណា បឺយស្ត្រម ផ្តល់បទសម្ភាសន៍នៅវិទ្យាស្ថានរ៉េយ៉ំ

ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងមិនបានគិតថាក្មេងៗ ដែលធ្វើការនៅក្នុងរោងចក្រត្រូវកាន់ឧបករណ៍ដ៏គ្រោះថ្នាក់បែបនេះទេ ។ គាត់ក៏បានសួរសំណួរទាក់ទងនឹងការពិតនៃមន្ទីរពេទ្យនិងសាលារៀនដែលគាត់បានទៅមើល ក្រោយមកក៏ឆ្ងល់ថាតើមនុស្សដែលគ្មានការអប់រំអាចធ្វើការទាំងអស់នៅក្នុងផ្នែកវេជ្ជសាស្ត្រ និងផ្នែកគណិតវិទ្យាដោយរបៀបណា ។

ប៉ុន្តែក្រោយមក ហុនណា មិនបានយកចិត្តទុកដាក់នឹងចម្ងល់ទាំងនោះរបស់គាត់ទេ ហើយប្រានចោលជន្ទួសមកវិញដោយជឿថាបដិវត្តន៍នេះល្អច្រើនជាងអាក្រក់ ។ ហុនណា បានពន្យល់ទៅកាន់ប្រជាជនកម្ពុជាដ៏ច្រើនលើសលប់កាលពីពេលព្រឹកថា «វាដូចជាសមីការគណិតវិទ្យាដែរ ខ្ញុំតែងតែសុំទោសខ្មែរក្រហមដោយជឿជាក់ថាបដិវត្តន៍នៅទីនេះនៅក្មេងខ្ចី ហើយខ្ញុំគិតថាខ្មែរក្រហមនឹងអាចសិក្សាពីវាថែមទៀត» ។

ប៉ុន្តែ ហុនណា ក៏មិនខ្វល់ពីការសង្ស័យទាំងនេះដែរ ។ ហុនណា បានប្រាប់រឿងសម្ងាត់ថា «ថ្ងៃនេះខ្ញុំនៅតែមិនជឿថាអ្វីដែលយើងពុំពីជនភៀសខ្លួនគួរតែគ្រប់គ្រាន់ដើម្បីប្រឆាំងនឹងខ្មែរក្រហម» ។ គាត់ក៏បានសារភាពនៅវិទ្យាស្ថានវៃយំក្នុងទីក្រុងភ្នំពេញកាលពីយប់ថ្ងៃអង្គារថា គាត់មិនដែលគិតពីការពិតថា គាត់មិនឃើញមានព្រះសង្ឃនៅក្នុងប្រទេសកាន់ព្រះពុទ្ធសាសនានេះទេ ។ គាត់បានប្រាប់អ្នកស្តាប់ថា «ប៉ុន្តែខ្ញុំគិតថា នេះជាអ្វីដែលតែងតែកើតឡើងនៅពេលដែលអ្នកបាត់បង់ការគិត និងនៅពេលមនោគមន៍វិជ្ជាមួយចំនួនក្លាយជារឿងសំខាន់ជាងការពិត» ។

គាត់បានបន្ទោសខ្មែរក្រហមមួយផ្នែកសម្រាប់ការបំភ័ន្តគណៈប្រតិភូ ប៉ុន្តែចុងក្រោយគាត់បានបន្ទោសខ្លួនឯង ។ «យើងពាក់វ៉ែនតាម៉ៅនិយមទៅហើយ ដូច្នេះយើងឃើញអ្វីដែលខ្មែរក្រហមចង់ឲ្យឃើញដែរប៉ុណ្ណោះ» ។

រឿងរ៉ាវរបស់គាត់គឺជាករណីចាស់ បញ្ឈាក់ពីភាពលម្អៀងដែលខាងផ្នែកចិត្តសាស្ត្រប្រើដើម្បីពិពណ៌នាពី «ទំនោរការរបស់មនុស្សក្នុងការស្វែងរក ឬពន្យល់ព័ត៌មាននៅក្នុងវិធីសាស្ត្រដោយបញ្ជាក់ពីការយល់ឃើញអ្វីមួយមុនពេលវិនិច្ឆ័យ នឹងដើម្បីជៀសវាងព័ត៌មានដែលផ្ទុយពីការយល់ឃើញពីមុន» ។ គាត់លើកទឹកចិត្តឲ្យអ្នកស្តាប់គិតទៅដល់អ្វីដែលពួកគេឃើញ និងឮ ទោះបីជាឥឡូវគាត់កំពុងតែស្នើឲ្យប្រជាជនកម្ពុជាចោទជាសំណួរទៅគាត់ ។

## ការវិលត្រឡប់មកវិញ

នៅរយៈពេល៦ខែបន្ទាប់ពីដំណើរទស្សនកិច្ចរបស់គាត់នៅសម័យខ្មែរក្រហម ហុនណា យល់ថាគាត់មានកំហុស ។ ក្រោយមកគាត់បានសរសេរអត្ថបទឲ្យទស្សនាវដ្តីស៊ុយអែដដ៏ធំមួយដោយនិយាយថា គាត់បានធ្វើខុស ។ គាត់មិនដែលនឹកគិតថានឹងវិលត្រឡប់មកប្រទេសកម្ពុជាទេ រហូតដល់មានអ្នកកាសែតម្នាក់សុំឲ្យគាត់លើកយកពីចំណុចដែលថាតើគាត់ជឿរបបខ្មែរក្រហមដោយរបៀបណា? នៅក្នុងសម្តីរបស់ ហុនណា សំណួរនិងចម្លើយដែលខុះចន្លោះរបស់គាត់ «មិនមែនជាបញ្ហាធំដែលគាត់គិតថា វាបានកប់បាត់ទៅវិញទេ» ។ បន្ទាប់ពីបរិភោគអាហារពេលល្ងាច ហុនណា ដែលធ្វើការខាងផ្នែកថ្នាំញៀន បានប្រៀបធៀបដំណើរទស្សនកិច្ចរបស់គាត់មកប្រទេសកម្ពុជាថា ដូចជាដំណាក់កាលដែលអ្នកញៀនថ្នាំធ្វើឡើងនៅអំឡុងពេលកំពុងបន្សាប ។ ដំណើរទស្សនកិច្ចរបស់ខ្ញុំមកប្រទេសកម្ពុជា ហុនណា និយាយថា «វាប្រៀបដូចជាជំហានទី៨នៅក្នុងដំណើរការនេះ ។ ដូចជាអ្នកញៀនថ្នាំញៀនផ្សេងទៀតដែរ ដែលខ្ញុំបានបង្កើតបញ្ជីឈ្មោះមនុស្សទាំងអស់ដែលខ្ញុំគួរតែកែប្រែឡើងវិញ ហើយឥឡូវសម្រាប់ជំហានទី៩ ខ្ញុំបានត្រឡប់មកទីនេះដើម្បីធ្វើការកែប្រែវាសាឡើងវិញ» ។

ហុនណា សង្ឃឹមថា ដំណើរទស្សនកិច្ចរបស់គាត់ត្រឡប់មកប្រទេសកម្ពុជា អាចបំផុសគំនិតអំពីឥទ្ធិពលរបស់មេដឹកនាំដ៏យង់ឃ្នងដើម្បីធ្វើឲ្យមានការយល់ដឹងពីសារសំខាន់នៃការវិនិច្ឆ័យទៅលើអ្វីមួយ ដោយលើកឲ្យមានការពិភាក្សាអំពីរឿងខ្មែរក្រហមក្នុងចំណោមក្មេង និងមនុស្សចាស់ ក៏ដូចជាការផ្សព្វផ្សាយលទ្ធិប្រជាធិបតេយ្យនិងសេរីភាពផងដែរ ។ «ខ្ញុំមិនអាចកែប្រែដំណើរទស្សនកិច្ចនេះឲ្យដូចដើមបានទេ ឥឡូវនេះខ្ញុំអាចព្យាយាមត្រឹមតែធ្វើឲ្យអ្វីមួយត្រឹមត្រូវប៉ុណ្ណោះ ។ ហើយដូចជាអ្វីដែលខ្ញុំបាននិយាយនៅពេលនេះខ្ញុំសុំទោស» ។

ក្នុងរយៈពេល១៨ថ្ងៃបន្ទាប់ ហុនណា នឹងធ្វើដំណើរទៅកាន់ជនបទ និងទៅមើលទីកន្លែងដែលគាត់បានថតរូប និយាយនិងជួបប្រជាជនកម្ពុជានៅតាមផ្លូវក្នុងឆ្នាំ១៩៧៨ ។

**សារ៉ា ចូន ឌីកឃិន**

# ប្រវត្តិជីវិតរបស់ឪពុកម្តាយខ្ញុំ

នាងខ្ញុំឈ្មោះ ជា ធីតា ជានិស្សិតនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានឪពុកឈ្មោះ ជា ឌឿន ជាគ្រូបង្រៀននៅវិទ្យាល័យពាមរក៍ និងម្តាយឈ្មោះ សេង ស៊ាម ជាកសិករ មានស្រុកកំណើតនៅភូមិប្រាសាទកើត ឃុំបន្ទិចប្រាសាទ ស្រុកពាមរក៍ ខេត្តព្រៃវែង ។ ទោះបីជាខ្ញុំមិនបានឆ្លងកាត់របបនេះក៏ដោយ ក៏ខ្ញុំបានស្តាប់ឮតាមរយៈការរៀបរាប់របស់ឪពុកម្តាយខ្ញុំដែរ ។

ក្រោយថ្ងៃរំដោះ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនដែលរស់នៅទីក្រុងភ្នំពេញឲ្យទៅរស់នៅទីរួមខេត្តនិងទីជនបទ ។ នៅតាមផ្លូវ ដោយសារគ្មានកង់និងម៉ូតូសម្រាប់ដឹកជញ្ជូនអីវ៉ាន់ ឪពុកខ្ញុំបានរែកអង្ករ បង្វេចខោអាវ ចាន ឆ្នាំង ចំណែកម្តាយខ្ញុំទូលអីវ៉ាន់ ពបងប្រុសខ្ញុំ និងដឹកដៃបងខ្ញុំម្នាក់ទៀត ។ ពេលធ្វើដំណើរឪពុកម្តាយខ្ញុំបានឃើញមនុស្សស្លាប់តាមផ្លូវនិងតាមប្រាំងទន្លេជាច្រើន ហើយពេលខ្លះគាត់ឃើញសាកសពអណ្តែតទឹកឡើងស្អុយរលួយ ដែលអ្នកទាំងនេះភាគច្រើនស្លាប់ដោយសារតែប្រឆាំងនឹងបញ្ជារបស់អង្គការ ។ ពេលនោះ ដោយសារការស្រេកឃ្លានខ្លាំងពេក ឪពុកខ្ញុំបានទៅដួសទឹកនៅក្បែរសាកសពនោះយកមកហូប ។ ធ្វើដំណើររយៈពេលពីរយប់ ទើបគាត់មកដល់ស្រុកកំណើតនៅខេត្តព្រៃវែង ។ នៅទីនេះ ប្រជាជននៅក្នុងភូមិមិនសូវរាប់អានឪពុកម្តាយរបស់ខ្ញុំទេ សូម្បីតែអ៊ំខ្ញុំក៏មិននិយាយរកឪពុកម្តាយខ្ញុំដែរ ព្រោះគាត់យល់ថាគ្រួសារខ្ញុំជាអ្នកចំណូលថ្មី ។ ឪពុកម្តាយខ្ញុំត្រូវអង្គការចាត់តាំងឲ្យរស់នៅទួលមួយកន្លែង ហើយព្រឹកឡើងទើបបញ្ជូនឲ្យទៅរៀនសូត្រនៅឃុំស្តី-ក ស្រុកបាភ្នំ ដោយមានតែក្រមាមួយនិងខោអាវដែលពាក់នៅជាប់ខ្លួនប៉ុណ្ណោះ ។ នៅយប់មួយបន្ទាប់ពីប្រជុំចប់ អង្គការក៏បញ្ជូនឪពុកខ្ញុំនិងប្រជាជនផ្សេងទៀតដែលមានមុខងារជាមន្ត្រីរាជការ គ្រូបង្រៀន ប៉ូលិស ជាដើមឲ្យទៅរស់នៅក្នុងជំរំខ្វែងគង់ ដែលទីនេះមានលក្ខណៈដូចជាគុកពីព្រោះប្រជាជនគ្មានសិទ្ធិសេរីភាពអាចដើរទៅកន្លែងណាឆ្ងាយបានទេ ហើយថែមទាំងបង្ខំឲ្យធ្វើការស្ទើរតែគ្មានពេលឈប់សម្រាកទៀត ។ ដូច្នេះមានពេលខ្លះ ដោយសារជំងឺធ្ងន់ពេក និងពិបាកការងារ ឪពុកខ្ញុំ ធ្វើការមិនបានតាមផែនការរបស់អង្គការទេ ប៉ុន្តែខ្មែរក្រហមក៏មិនយកទោសពៃរ៍ដែរ ។ នៅយប់មួយពេលដែលមិត្តរួមការងារនៅក្នុងកងម្នាក់ដែលជាអតីតទាហាននៅសម័យ លន់ នល់ រើសបានកូនទាងាប់មួយដែលគេបោះចោលកាលពីពេលថ្ងៃយកមកអាំងហូប ឪពុកខ្ញុំក៏ចូលទៅសុំគេហូបដែរ ពេលនោះស្រាប់តែទាហានខ្មែរក្រហមមកទាន់ ក៏បានយកស្នូកកាំភ្លើងមកវាយចំក្បាលឪពុកខ្ញុំបណ្តាលឲ្យពករហូតមកដល់សព្វថ្ងៃនេះ ។



ក្រុមគ្រួសាររបស់ធីតា ថតក្នុងឆ្នាំ១៩៩១

មួយរយៈក្រោយមក ប្រជាជននៅក្នុងកងរបស់គាត់ជាច្រើននាក់ចាប់ផ្តើមឈឺ និងស្លាប់ជាបន្តបន្ទាប់ដោយសារពុំមានអាហារហូបគ្រប់គ្រាន់ ។ រយៈពេល២០ថ្ងៃក្រោយមក ទើបទាហានខ្មែរក្រហមបញ្ជូនអ្នកដែលមានសមាសភាពជាគ្រូបង្រៀនឲ្យត្រឡប់មកមូលដ្ឋានវិញ ។ ចំណែកអ្នកដែលជាទាហាននិងគ្រូពេទ្យត្រូវ

នៅធ្វើការបន្តទៀត ។ ប៉ុន្តែអ្នកទាំងនោះភាគតិចណាស់ដែលអាចរស់រានមានជីវិតបាន ។ មួយរយៈក្រោយមក ដោយសារតែឪពុករបស់ខ្ញុំខំធ្វើការ ដើម្បីកុំឲ្យអង្គការស្តីបន្ទោស ខ្លួនរបស់គាត់ក៏ចាប់ផ្តើមហើម ។ ឃើញដូច្នេះ ម្តាយរបស់ខ្ញុំចង់ឈប់សម្រាកណាស់ដើម្បីមើលថែទាំគាត់ ប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាតទេដោយបញ្ជូនគាត់ឲ្យទៅធ្វើការនៅតាមកងចល័ត ដូចជាដកសំណាប និងបោចកំប្លោកដើម្បីយកដីធ្វើជាថ្នាលព្រោះស្រូវ ។ ដោយសារតែឪពុកម្តាយរបស់ខ្ញុំមានការងារធ្វើរៀងៗខ្លួន ដូច្នេះហើយបងប្រុសខ្ញុំត្រូវទុកឲ្យយាយចាស់ៗ និងម៉ែដោះនៅក្នុងភូមិ២-៣នាក់មើលថែទាំ ។ ចំណែកឯបងខ្ញុំម្នាក់ទៀតត្រូវប្រធានកងចាត់ឲ្យទៅឃ្វាលគោ និងកើបអាចម៍គោដាក់ក្នុងស្រែ ។

ក្រោយពីឪពុកខ្ញុំបានជាសះស្បើយពីជំងឺ គាត់ក៏ត្រូវអង្គការចាត់តាំងឲ្យយកទូកទៅដឹកជញ្ជូនស្រូវមកទុកនៅឃ្លាំងអ្នកលឿងដើម្បីបែងចែកបន្តទៅសង្កាត់បន្ទិចប្រាសាទ ។ ថ្ងៃមួយស្រាប់តែមានភ្លៀងធ្លាក់យ៉ាងខ្លាំង ហើយមេឃចាប់ផ្តើមងងឹតស្ទើរមើលមិនឃើញ ធ្វើឲ្យកងទាំងអស់មិនអាចជញ្ជូនស្រូវទាន់ពេលវេលាព្រោះខ្លាចទឹកស្រូវអស់ ពេលនោះឪពុកខ្ញុំត្រូវនៅដេកយាមទូកទាំងអត់អាហារ ។ ដោយសារតែភាពស្រេកឃ្លាន គាត់បានយកពោតឆៅ៣-៤ផ្លែមកហូបដើម្បីចម្អែតក្រពះ ។ នៅយប់នោះ ពេលឪពុកខ្ញុំកំពុងដេកលើទូក ស្រាប់តែគាត់ឮសូរសំឡេងជើងមនុស្សដើរនៅជុំវិញគាត់ និងឃើញស្រមោលធ្លុខ្មៅដែលស្លៀកពាក់ឯកសណ្ឋានជាទាហានមកតាមដានគាត់ ។ ឪពុករបស់ខ្ញុំភ័យខ្លាចយ៉ាងខ្លាំងព្រោះខ្លាចអង្គការយកគាត់ទៅសម្លាប់ ។

នៅឆ្នាំ១៩៧៦ ឪពុកម្តាយរបស់ខ្ញុំបានលួចចាប់មាន់ខ្លួនឯងយកមកស្ងោរ និងយកអង្ករដែលអង្គការចែកឲ្យមកដាំបាយហូប ។ ប៉ុន្តែទោះបីជាអង្គការមិនសូវតឹងតែងក៏ដោយ ក៏គាត់មិនហ៊ានហូបដោយបើកចំហដែរ ដោយគាត់បានប្រើបងប្រុសខ្ញុំដែលមានអាយុ១០ឆ្នាំឲ្យនៅចាំមើលសភាពការណ៍នៅក្រោមផ្ទះព្រោះអង្គការមិនអនុញ្ញាតឲ្យហូបលួចលាក់ទេ ប្រសិនបើមានអ្វីហូបត្រូវយកទៅ ដាក់ជាសមូហភាពរួម ។ នៅរដូវប្រាំងប្រជាជននៅក្នុងសហករណ៍ទាំងអស់ត្រូវបានអង្គការបែងចែកឲ្យធ្វើស្រែប្រាំង ដាំដំណាំ លើកទំនប់ និងជីកប្រឡាយ និងនៅរដូវវស្សាស្រីៗត្រូវបុកអង្ករ និងអុំអង្ករ ចំណែកប្រុសៗត្រូវទៅរកខ្យង ។ ក្រៅពីការងារទាំងនេះ ឪពុកខ្ញុំត្រូវអង្គការបញ្ជាឲ្យធ្វើការយប់បន្ថែមទៀត ដូចជាប្រឡេះគ្រាប់ពោត វាយបំបែកពោត រួចអុំយកគ្រាប់ដោយធ្វើឲ្យបានពីរទៅបីបាវក្នុងមួយយប់ដើម្បីផ្គត់ផ្គង់ខាងរោងបាយ ។ មិនយូរប៉ុន្មាន បងប្រុសរបស់ខ្ញុំដែលទើបតែមានអាយុ២ឆ្នាំនៅមណ្ឌលកុមារក៏ចាប់ផ្តើមក្តៅខ្លួន និងរីងថ្កាម ។ ម្តាយខ្ញុំព្រួយបារម្ភពីជំងឺរបស់គាត់ណាស់ ហើយក៏ប្រញាប់ទៅប្រាប់អង្គការដើម្បីសុំបញ្ជូនគាត់ទៅព្យាបាលនៅមន្ទីរពេទ្យ ។ ដោយសារតែថ្នាំដែលប្រើប្រាស់ពុំសូវមានប្រសិទ្ធភាព ព្រោះលេបតែថ្នាំអាចម៍ទន្សាយ បណ្តាលឲ្យគាត់ស្លាប់នៅទីនោះ ។ ឪពុកខ្ញុំក៏បានយកសពគាត់ទៅកប់នៅខាងក្រោយផ្ទះ ហើយនិយាយប្រាប់ខ្ញុំថា បងខ្ញុំស្លុតណាស់ បើសិនគាត់នៅរស់ ពេលនេះគាត់នឹងក្លាយជាគ្រូបង្រៀនដូចគាត់អ៊ីចឹង ។


អ្នកភូមិកំពុងឈរមើលការតាំងពិព័រណ៍រូបថតនៅខេត្តកំពង់ចាម

ថ្ងៃមួយប្រធានឃុំបានជ្រើសរើសប្រុសៗនៅក្នុងភូមិចំនួន៤នាក់ ក្នុងនោះក៏មានឈ្មោះឪពុកខ្ញុំដែរ ឲ្យទៅ

គាស់មើមក្តួចនៅខេត្តកំពង់ចាម យកមកធ្វើជាថ្នាំសម្លាប់សត្វល្អិតបំផ្លាញស្រូវក្នុងស្រែ ។ មុនពេលចេញដំណើរ ឪពុករបស់ខ្ញុំបានដឹកសម្ភារៈនិងស្បៀង និងរបស់ប្រើប្រាស់មួយចំនួនសម្រាប់ហូបនៅទីនោះដូចជាដ័រសម្រាប់ប៉ះកង់ បាវសម្រាប់ដាក់មើមក្តួច អង្ករត្រីប្រឡាក់ ពោតទុំ ចាន និងឆ្នាំង ។ ដោយសារកង់របស់គាត់បែកនៅកណ្តាលផ្លូវ គាត់ក៏ត្រូវដេកនៅភ្នំតាងិលមួយយប់ ។ រយៈពេល២ថ្ងៃក្រោយមក ឪពុករបស់ខ្ញុំក៏បានទៅដល់កន្លែងគាស់មើមក្តួច ។ ទោះបីជាលំបាកបន្តិចដោយត្រូវក្រោកពីព្រលឹមទៅព្រៃដើម្បីដើររកគាស់មើមក្តួចក៏ដោយ ក៏គាត់បានហូបគ្រប់គ្រាន់ដែរ ។ ក្រោយពីគាស់មើមក្តួចម្នាក់ៗបានប្រមាណជា៣០ទៅ៤០គីឡូក្រាម ក្រុមរបស់គាត់ក៏វិលត្រឡប់មកភូមិវិញ ។ ពេលមកដល់គាត់មិនបានឈប់សម្រាកទេ ព្រោះប្រធានឃុំបានបញ្ជាឲ្យប្រមូលមើមក្តួចទាំងអស់យកមកបុកឲ្យហ្មត់និងល្អិត រួចហើយយកទៅចំហុយដើម្បីយកចំហាយទៅប្រើសម្រាប់ធ្វើជាថ្នាំសម្លាប់សត្វល្អិតនៅក្នុងស្រែ ។

ឆ្នាំ១៩៧៧ នៅដើមរដូវប្រាំង អង្គការបានចាត់តាំងឪពុកខ្ញុំនិងប្រុសៗនៅក្នុងមូលដ្ឋានឲ្យទៅភ្ជួរស្រែនៅភូមិចាក់ខ្វាញ់រយៈពេល១ខែដែលមានចម្ងាយប្រមាណ៥គីឡូម៉ែត្រពីភូមិ ។ ឪពុកខ្ញុំត្រូវក្រោកទៅភ្ជួរស្រែតាំងពីម៉ោង៤ព្រឹក រហូតដល់ម៉ោង១១កន្លះទើបឈប់សម្រាកហូបបបរជាមួយត្រកួនស្ងោរ និងអំបិល ។ នៅព្រឹកមួយពេលដែលឪពុកខ្ញុំកំពុងដឹកគោ និងលីនង្គ័លទៅភ្ជួរស្រែស្រាប់តែគាត់បានធ្វើឲ្យជ្រុះផាលនង្គ័លនៅតាមផ្លូវដោយពុំដឹងខ្លួន ។ ពេលទៅដល់ស្រែ ឪពុកខ្ញុំភិតភ័យយ៉ាងខ្លាំង ព្រោះខ្លាចអង្គការចោទប្រកាន់ថាជាសេអ៊ីអា ម្យ៉ាងទៀតគាត់ជាប្រជាជនថ្មីដែលជាមុខសញ្ញារបស់អង្គការកំពុងតាមដានទៀត ដូច្នេះគាត់បានចងគោទុក រួចរាវរកផាលនង្គ័ល ។ ប៉ុន្តែឪពុកខ្ញុំសំណាងណាស់ ព្រោះគាត់បានរកឃើញផាលនង្គ័លនោះវិញ ។ នៅទីនេះទោះបីជាគាត់បានឃើញ ហឿន ដែលនៅក្នុងក្រុមរបស់គាត់បាត់ខ្លួនដោយសារតែគាត់ត្អូញត្អែរអំពីសម្ភូរត្រកួនមានឈ្លើងក៏ដោយ ក៏គាត់និងក្រុមរបស់គាត់នៅតែហ៊ានលួចដើរពីការដ្ឋានដែលមានចម្ងាយប្រមាណ៥គីឡូម៉ែត្រត្រឡប់មកភូមិវិញ ដើម្បីគាស់ដំឡូងយកទៅដុតហូប ។ រយៈពេល១ខែក្រោយមក ដោយសារការនឿយហត់ និងស្រេកឃ្លានខ្លាំងពេក គាត់ក៏មិនសូវគិតពីរឿងនឹកប្រពន្ធកូនឡើយ ។ ចំណែកម្តាយរបស់ខ្ញុំវិញមិនត្រូវបានអង្គការចាត់តាំងឲ្យធ្វើការងារធ្ងន់ទេ ព្រោះគាត់ទើបតែសម្រាលកូនខ្ចី ។ ដូច្នេះម្តាយខ្ញុំបានប្រើបងប្រុសឲ្យហែលឆ្លងទឹកព្រែកទៅយករបបអាហារមកឲ្យគាត់ហូប ថែមទាំងដើរស្ទូចត្រីយកមកធ្វើម្ហូបថែមទៀត ។

ក្រោយការរំដោះនៅឆ្នាំ១៩៧៩ ឪពុកម្តាយរបស់ខ្ញុំមិនបានរត់ទៅណាទេដោយគាត់នៅរស់នៅក្នុងភូមិដដែល ។ ក្រោយមកដោយសារតែឪពុករបស់ខ្ញុំជាមនុស្សរៀនបានខ្ពស់ និងធ្លាប់ធ្វើជាគ្រូបង្រៀន គាត់ក៏ត្រូវបានជ្រើសរើសឲ្យធ្វើជាគណៈឃុំបន្ទិចប្រាសាទ ។ នៅឆ្នាំ១៩៨០ គាត់បានផ្លាស់ប្តូរមកធ្វើជានាយកវិទ្យាល័យពាមរក៍វិញ ។ នៅឆ្នាំ១៩៨៧ ឪពុករបស់ខ្ញុំបានផ្លាស់មុខងារមកធ្វើជាគណៈស្រុកពាមរក៍ ទទួលបន្ទុកខាងផែនការវប្បធម៌ ។ ដោយសារតែការងារនេះតម្រូវឲ្យគាត់ទៅធ្វើការឆ្ងាយមិនសូវមានពេលទំនេរនៅផ្ទះ គាត់ក៏សម្រេចចិត្តមកធ្វើជាគ្រូបង្រៀន និងជាទីប្រឹក្សាឃុំបន្ទិចប្រាសាទវិញរហូតដល់សព្វថ្ងៃនេះ ។

**ថា ធីតា**

# សេចក្តីប្រកាសរកប្អូនប្រុស

នាងខ្ញុំឈ្មោះ នាក់ ហោង សព្វថ្ងៃរស់នៅភូមិភ្នំតូច ឃុំស្តេចគង់ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកខ្ញុំឈ្មោះ សោម យេន (ស្លាប់) និងម្តាយឈ្មោះ អ៊ុន សឹម (ស្លាប់) ។ ខ្ញុំមានបងប្អូនពីរនាក់ គឺខ្ញុំនិងប្អូនប្រុសម្នាក់ទៀតឈ្មោះ នាក់ ធី (បាត់ខ្លួន) ។ ខ្ញុំសូមស្វែងរកប្អូនប្រុសឈ្មោះ នាក់ ធី ដែលបាត់ខ្លួនពេលធ្វើជានិរសារនៅព្រំដែនវៀតណាមនៅមុនឆ្នាំ១៩៧៥ ។ នៅពេលនោះ ធី ទើបតែមានអាយុប្រហែលជា១៤ឬ១៥ឆ្នាំប៉ុណ្ណោះ រួចបានចេញពីផ្ទះទៅធ្វើជានិរសារជាមួយមីងឈ្មោះ ពៅ ជាអ្នកនាំចូល ។ ក្រោយមកខ្ញុំក៏បាត់ដំណឹង ធី រហូត ។

ប្រសិនបើប្អូនបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនណាស្គាល់ ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ព័ត៌មានមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១៧ ៩២៩ ៩៦១ ឬមេភូមិភ្នំតូចឈ្មោះ មិន ឈុំ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ **សូមអរគុណ**



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 108, December 2008 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.